# ការឃ្លាំមើលការអភិវឌ្ឍនៅកម្ពុជា

ឆ្នាំទី៧ ចេញផ្សាយលើកទី ១ - ខែមករា ឆ្នាំ២០១១





ការវិភាគលើច្បាប់ស្តីពីហិរញ្ញវត្ថុ
សំរាប់ការគ្រប់គ្រងឆ្នាំ២០១០ (ច្បាប់ថវិកាជាតិ)
(ទំព័រ ០១)

ល័ក្ខខ័ណ្ឌជំនួយនៃកម្មីសម្បទានបរទេស
ចំពោះប្រទេសកម្ពុជា
(ទំព័រ ១៣)

ផលប៉ះពាល់នៃការធ្លាក់ចុះសេដ្ឋកិច្ចទៅលើគ្រួសារ និងសហគមន៍
និងតម្រូវការចាំបាច់នូវគោលនយោបាយឆ្លើយតប
(ទំព័រ ២១)

អ្នកផ្ទុកមេរោគអេដស៍ដែលត្រូវបង្ខំឱ្យទៅ
នៅភូមិទួលសំបូរៈ ការអំពាវនាវសុំជំនួយដើម្បីបន្តរស់
(ទំព័រ ២៩)

ការបោះពុម្ពផ្សាយនេះ
បានទទួលការឧបត្ថម្ភថវិកាពីម្ចាស់ជំនួយនៃ
វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia
ផ្ទះលេខៈ ៩-១១, ផ្លូវលេខ ៤៦៧
សង្កាត់ទួលទំពូង១, ភ្នំពេញ, កម្ពុជា

## ការឃ្លាំមើលការអភិវឌ្ឍនៅកម្ពុជា

បោះពុម្ពនៅ ខែមករា ឆ្នាំ២០១១

ការបោះពុម្ពផ្សាយនេះ បានទទួលការឧបត្ថម្ភថវិកាពីម្ចាស់ជំនួយនៃ

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

**បញ្ជាក់៖**

មតិយោបល់ និងសេចក្តីសន្និដ្ឋានទាំងឡាយគឺជាមតិផ្ទាល់របស់អ្នកនិពន្ធ ដោយមិនឆ្លុះបញ្ចាំងនូវទស្សនៈ និងគោលជំហររបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ទាំងអស់ឡើយ ។

**© វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**

# បុព្វកថា

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា រួមមានអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ ដែលមានបទពិសោធន៍ក្នុងការផ្តល់ជំនួយមនុស្សធម៌ និងជំនួយអភិវឌ្ឍន៍ដល់ប្រទេសកម្ពុជា។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាបង្កើតឡើងដើម្បីចែករំលែកព័ត៌មាន ពិភាក្សាដោញដោល និងតស៊ូមតិលើបញ្ហាជាអាទិភាពនានា ដែលប៉ះពាល់ដល់ការអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា មានតួនាទីយ៉ាងសំខាន់នៅក្នុងការលើកឡើងនូវចំនុចសំខាន់នានាដែលប៉ះពាល់ដល់ដំណើរការអភិវឌ្ឍន៍ និងការផ្លាស់ប្តូរសេដ្ឋកិច្ចសង្គម និងនយោបាយដែលមានទៅលើប្រជាជនកម្ពុជា។

ការបោះពុម្ពទស្សនាវដ្តីការឃ្លាំមើលការអភិវឌ្ឍនៅកម្ពុជា ផលិតដោយគម្រោងគោលនយោបាយអភិវឌ្ឍន៍នៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា។ ទស្សនាវដ្តីនេះ មានបំណងគូសបញ្ជាក់នូវទស្សនៈរបស់អង្គការសង្គមស៊ីវិលទៅលើ: ១) គោលនយោបាយអភិវឌ្ឍន៍នានារបស់រាជរដ្ឋាភិបាល ២) ការអនុវត្តនូវគោលនយោបាយទាំងនោះ ៣) ការចែករំលែកព័ត៌មាន និង ៤) ជំរុញការពិភាក្សាក្នុងចំណោមសាធារណជន និស្សិត អង្គការសង្គមស៊ីវិល អ្នកធ្វើគោលនយោបាយ និង ដៃគូអភិវឌ្ឍន៍ ថាតើការអនុវត្តនូវកម្មវិធី និងគោលនយោបាយទាំងឡាយ ជួយដល់ការកាត់បន្ថយភាពក្រីក្រ និងកិច្ចអភិវឌ្ឍន៍នៅកម្ពុជាយ៉ាងដូចម្តេច។

ប្រធានបទនៅក្នុងទស្សនាវដ្តី ការឃ្លាំមើលការអភិវឌ្ឍនៅកម្ពុជានេះ ត្រូវបានសរសេរ និងលើកឡើងដោយ: លោក ហម ហាក់ ប្រធានកម្មវិធីទំនាក់ទំនង និងបោះពុម្ព (អង្គការមេឌីខាំ) (អ្នកផ្ទុកមេរោគអេដស៍ដែលបង្ខំឱ្យទៅនៅភូមិទួលសំបូរ: ការអំពាវនាវសុំជំនួយដើម្បីបន្តរស់) និងបុគ្គលិកវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ដែលក្នុងនោះរួមមាន: លោក លាង រ័ត្នមាណា (ល័ក្ខខ័ណ្ឌជំនួយនៃកម្ចីសម្បទានបរទេសចំពោះប្រទេសកម្ពុជា) (វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា) កញ្ញា ចាន់ សុខយ៉េង (ផលប៉ះពាល់នៃការធ្លាក់ចុះសេដ្ឋកិច្ចទៅលើគ្រួសារ និងសហគមន៍ និងតម្រូវការចាំបាច់នូវគោលនយោបាយឆ្លើយតប) លោក វ៉ា សុធី និង លោក ជា គឹមសុង (ការវិភាគលើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០ (ច្បាប់ថវិកាជាតិ)។

សូមថ្លែងអំណរគុណផងដែរដល់បុគ្គលិកដទៃទៀតនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ដែលក្នុងនោះរួមមាន: លោក ខាំ វ៉ាន់ដា មន្ត្រីគម្រោងគោលនយោបាយអភិវឌ្ឍន៍ និង លោក ជា គឹមសុង ប្រធានកម្មវិធីបញ្ហាអភិវឌ្ឍន៍ ក្នុងការសម្របសម្រួលដំណើរការផលិត និង លោក ខាំ ស៊ីងួន នាយកប្រតិបត្តិរង ក្នុងការត្រួតពិនិត្យរួមលើខ្លឹមសារ និងដំណើរការបោះពុម្ព និង លោក ភួន យូ មន្ត្រីទំនាក់ទំនង និងការផ្សព្វផ្សាយ ក្នុងការរៀបចំរចនាទស្សនាវដ្តីនេះ។

ការបោះពុម្ពនេះ នឹងមិនអាចលេចជារូបរាងបាននោះទេ បើគ្មានការជួយឧបត្ថម្ភពីម្ចាស់ជំនួយនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា សំរាប់ការផលិតឡើងទាត់នូវទស្សនាវដ្តីការឃ្លាំមើលការអភិវឌ្ឍនៅកម្ពុជា។

យើងខ្ញុំសូមស្វាគមន៍នូវរាល់មតិយោបល់បែបស្ថាបនាទាំងឡាយ ដើម្បីកែលម្អការបោះពុម្ពផ្សាយទស្សនាវដ្តីឃ្លាំមើលការអភិវឌ្ឍនៅលេខក្រោយៗទៀត។ យើងខ្ញុំសង្ឃឹមថា ខ្លឹមសារ និងអនុសាសន៍ដែលបានលើកឡើងនៅក្នុងអត្ថបទនីមួយៗ នឹងបានជាព័ត៌មានដែលមានប្រយោជន៍ស្ថាបនាសម្រាប់ការពិចារណាផ្នែកគោលនយោបាយ។

លោក ឈិត សំអាត

នាយកប្រតិបត្តិ
វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

# ការវិភាគលើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង(ច្បាប់ថវិកាជាតិ)ឆ្នាំ២០១០[១]

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGO Forum on Cambodia) បានចាប់ផ្តើមធ្វើការងារលើថវិកាជាតិ នៅក្នុងឆ្នាំ២០០៦ ដោយមានគោលបំណងដើម្បីជំរុញឱ្យមានកិច្ចពិភាក្សាក្នុងចំណោមអ្នកពាក់ព័ន្ធគ្រប់រូបដោយផ្ទាល់ ឬដោយប្រយោល ទៅនឹងថវិកាជាតិ រាប់បញ្ចូលទាំងមន្ត្រីរដ្ឋាភិបាល សមាជិក សមាជិការដ្ឋសភា សារព័ត៌មាន សាស្ត្រាចារ្យ និងនិស្សិតមហាវិទ្យាល័យ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងប្រជាពលរដ្ឋខ្មែរគ្រប់រូប។ លទ្ធផលវិភាគនេះ ត្រូវបានរៀបចំឡើងបង្ហាញជូនសមាជិក សមាជិករដ្ឋសភា និងព្រឹទ្ធសភានៅក្នុងសិក្ខាសិលាដែលរៀបចំដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា កាលពីខែវិច្ឆិកា ឆ្នាំ ២០០៩ មុនពេលច្បាប់នេះត្រូវបានពិភាក្សា និងអនុម័តដោយរដ្ឋសភា។

## សេចក្តីសង្ខេប

ច្បាប់ថវិកាឆ្នាំ២០១០ បង្ហាញថារាជរដ្ឋាភិបាលកម្ពុជា រំពឹងថានឹងប្រមូលចំណូលបានចំនួនជិត ២ពាន់លាន ដុល្លារអាមេរិក ក្នុងការប្រតិបត្តិនៅឆ្នាំ២០១០។ ការចំណាយនូវប្រាក់ចំណូល ដែលទទួលបានពីពន្ធ កំរៃថ្លៃឈ្នួលផ្សេងៗ និងប្រាក់ពិន័យ ដែលបង់ដោយប្រជាពលរដ្ឋ និងក្រុមហ៊ុន ព្រមទាំងជំនួយឥតសំណង និងប្រាក់កម្ចីពីដៃគូអភិវឌ្ឍន៍ គឺជាឧបករណ៍ដ៏មានសក្តានុពលបំផុតរបស់ រាជរដ្ឋាភិបាលកម្ពុជាដើម្បីសម្រេចគោលដៅ និងវត្ថុបំណង ដែលបានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

ច្បាប់ថវិកាឆ្នាំ២០១០ ត្រូវឆ្លើយតបទៅនឹងបញ្ហាប្រឈមជាច្រើន។ ក្នុងកំឡុងពេល តម្លៃអាហារដែលចាប់ឡើងថ្លៃនៅក្នុងឆ្នាំ២០០៨ កំពុងបន្តឡើងថ្លៃខ្ពស់ មានគ្រួសារជាច្រើនដែលប្រាក់ចំណូលរបស់ខ្លួនបានធ្លាក់ចុះដោយសារតែការបាត់បង់ការងារ និងការខ្វះខាតការងារក្នុងវិស័យសំណង់ កាត់ដេរសំលៀកបំពាក់ និងវិស័យទេសចរណ៍។ ការស្រាវជ្រាវនាពេលថ្មីៗនេះដែលធ្វើឡើងដោយសមាគមសេដ្ឋកិច្ចកម្ពុជាបង្ហាញថា ការសម្រេចបានក្នុងការកាត់បន្ថយភាពក្រីក្រនាពេលថ្មីៗនេះកំពុងត្រូវបានដើរថយក្រោយវិញ ដោយសារតែគ្រួសារនៅជនបទជាច្រើន កំពុងជួបប្រទះនឹងអសន្តិសុខស្បៀង ការកាត់បន្ថយការចំណាយលើសុខភាព ខ្ចីប្រាក់ដើម្បីចំណាយលើសុខភាព ការចំណាយប្រើប្រាស់ប្រចាំថ្ងៃ និងសងបំណុលចាស់។ បន្ទាប់មក ការកើនឡើងនៃបំណុលធ្វើឱ្យគ្រួសារទាំងនេះក្លាយជាគ្រួសារងាយរងគ្រោះនៅក្នុងពេលអនាគតដ៏ឆាប់ខាងមុខដោយសារតែគ្រួសារទាំងនេះមានឱកាសតិចតួចក្នុងការសងបំណុលទាំងនេះវិញ។

**ការអភិវឌ្ឍជាវិជ្ជមាននៅក្នុងច្បាប់ថវិកាឆ្នាំ២០១០ មានដូចជា:**

- ការកើនឡើងខ្លាំងនូវកញ្ចប់ថវិកាចំពោះវិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទដែលលើកកម្ពស់ក្តីសង្ឃឹមឱ្យមានការអភិវឌ្ឍបន្ថែមទៀតក្នុងការថែរក្សា និងពង្រីកហេដ្ឋារចនាសម្ព័ន្ធជនបទដូចជា ផ្លូវថ្នល់ ការផ្គត់ផ្គង់ទឹក និងប្រព័ន្ធធារាសាស្ត្រ ដែលចាំបាច់សម្រាប់ដំណើរឆ្ពោះទៅរកទីផ្សារ និងទិន្នផលកាន់តែខ្ពស់។
- ការបង្កើតពន្ធលើរថយន្តទំនើប និងការបង្កើតពន្ធលើអចលនទ្រព្យអត្រា ០,១% នឹងបង្កើនប្រាក់ចំណូលរបស់រាជរដ្ឋាភិបាល។ ពន្ធលើអចលនទ្រព្យនៅអត្រា ០,១% លើដី ផ្ទះ អគារ និងសំណង់ផ្សេងៗ ត្រូវបានរំពឹងថានឹងលើកកម្ពស់ការវិនិយោគដែលមានផលិតភាព និងបង្អាក់ទៅដល់ ឬកាត់បន្ថយការទិញដីស្តុកទុកសម្រាប់លក់យកចំណេញ និងដែលមិនមានការប្រើប្រាស់សម្រាប់ផលិតកម្ម។

**បញ្ហាសម្រាប់ការពិចារណាក្នុងការអនុវត្តច្បាប់ថវិកា២០១០ និងវិភាជន៍ថវិកាឆ្នាំ២០១១:**

- វិភាជន៍កញ្ចប់ថវិកាចរន្តសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា និង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្ថិតនៅក្រោម

[១] ដោយសារការបោះពុម្ពទស្សនាវដ្តីនេះត្រូវបានពន្យាពេល ដូច្នេះចំនុចមួយចំនួនដែលមានការវិវឌ្ឍន៍ត្រូវបានធ្វើបច្ចុប្បន្នកម្ម ដើម្បីឱ្យលទ្ធផលនៃការវិភាគនេះ នៅតែមានសុពលភាពសម្រាប់ការពិចារណាដោយភាគីពាក់ព័ន្ធ។

កំណើនជាមធ្យម ហើយគួរតែបង្កើនឱ្យបានខ្ពស់ជាងនេះនៅក្នុងច្បាប់ថវិកានៅឆ្នាំក្រោយ បើផ្អែកលើតម្រូវការលើកកម្ពស់គុណភាពអប់រំ។

- បញ្ហាស្រដៀងគ្នានេះដែរ ត្រូវបានលើកឡើងសម្រាប់កញ្ចប់ថវិកាចរន្តដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយសារតែមានតម្រូវការពិតប្រាកដមួយ ដើម្បីលើកកម្ពស់សេវាផ្សព្វផ្សាយកសិកម្ម និងការស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្ម។

យោងតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ កន្សោមអាទិភាព (Priority Mission Groups) និងគម្រោងប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ (Merit Based Pay Initiative) មានសារៈសំខាន់សម្រាប់ការធ្វើកំណែទម្រង់ស៊ីវិលទូទាំងប្រទេស។ ការបង្កកនូវកន្សោមអាទិភាព និងប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារដូចដែលបានបញ្ជាក់នៅក្នុងសេចក្តីថ្លែងហេតុភ្ជាប់ជាមួយ សេចក្តីព្រាងច្បាប់អាចមានផលប៉ះពាល់ជាអវិជ្ជមានលើវឌ្ឍនៈភាព របៀបវារៈកំណែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា[២]។

ព័ត៌មាន និងសំណូមពរចំពោះវិភាជន៍ថវិកាតាមវិស័យក៏ត្រូវបានផ្តល់ជូនដោយអង្គការមិនមែនរដ្ឋាភិបាលសំខាន់ៗ មួយចំនួនដែលធ្វើការក្នុងវិស័យសុខាភិបាល អប់រំ និង វិមជ្ឈការ និងវិសហមជ្ឈការ ដែលរួមមានអង្គការមេឌីខាំ (MEDiCAM) អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP) និងអង្គការភាពជាដៃគូសង្គមស៊ីវិលកម្ពុជា (CCSP)។

## សេចក្តីផ្តើម: ច្បាប់ថវិកាឆ្នាំ២០១០ ត្រូវឆ្លើយតបទៅនឹងបញ្ហាប្រឈមជាច្រើន

ច្បាប់ថវិកាជាតិ គឺជាឧបករណ៍ដ៏មានសារៈសំខាន់បំផុតរបស់រាជរដ្ឋាភិបាល ដើម្បីសម្រេចបាននូវកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ ឆ្នាំ ២០០៨ និង២០០៩ គឺជា ឆ្នាំដ៏លំបាកសម្រាប់ប្រជាពលរដ្ឋជាច្រើន ជាពិសេសប្រជាពលរដ្ឋក្រីក្រ និងសហគមន៍ងាយរងគ្រោះ។

**រូបភាពទី១: មុខទំនិញជ្រើសរើសមួយចំនួនឆ្នាំ២០០៧-២០០៩ (គិតជារៀលក្នុង ១ គ.ក)**




*ប្រភព: វិទ្យាស្ថានជាតិស្ថិតិ ២០០៩*

វិបត្តិស្បៀងអាហារដែលបានចាប់ផ្តើមនៅដើមឆ្នាំ ២០០៨ មានឥទ្ធិពលអវិជ្ជមានដល់លទ្ធផលដែលទទួលបានពីការកាត់បន្ថយភាពក្រីក្រកន្លងមកដូច ដែលអាចឃើញ នៅក្នុងរូបទី១ ដែលតម្លៃទំនិញភាគច្រើនបានបន្តមានថ្លៃខ្ពស់ ជាពិសេស ដែលធ្វើឱ្យប្រពលរដ្ឋក្រីក្រដែល ចំណាយ ៨៣% នៃប្រាក់ចំណូលរបស់ខ្លួន លើម្ហូបអាហារ ជួបការលំបាក។ នៅពេលដែលយុវជន និងយុវតី កំពុងឈានជើងចូលទៅក្នុងទីផ្សារការងារវិបត្តិហិរញ្ញវត្ថុដែលកើតឡើងនៅចុងឆ្នាំ២០០៨ បណ្តាលឱ្យមានការបាត់បង់ការងារច្រើនជា ពិសេសនៅ ក្នុងវិស័យសំណង់ និងឧស្សាហកម្មកាត់ដេរ[៣] និងបណ្តាលឱ្យគ្រួសារជាច្រើនមានការថយចុះនូវប្រាក់ចំណូលជាខ្លាំង។ ជាងនេះទៅទៀត គ្រួសារ ដែលបង្កបង្កើនផលដំណាំកៅស៊ូ ដំឡូងមី សណ្តែកសៀង

[២] គិតមកដល់ខែតុលា ឆ្នាំ២០១០ រាជរដ្ឋាភិបាលកម្ពុជា ដោយមានការសម្របសម្រួលជាមួយនឹងដៃគូអភិវឌ្ឍន៍ បានអនុវត្តនូវប្រព័ន្ធលាភការថ្មីដែលជំនួសប្រព័ន្ធទាំងពីរដែលត្រូវបានបញ្ចប់ ដើម្បីធានាប្រសិទ្ធភាពនៃការបំពេញការងារ របស់មន្ត្រីរាជការស៊ីវិល ដែលធ្វើការលើកម្មវិធីកំណែទម្រង់សំខាន់ៗ។ ប្រព័ន្ធថ្មី នោះមានឈ្មោះថា ចំណាយប្រតិបត្តិការអាទិភាព (Priority Operation Cost-POC) ដែលមានការកំណត់អត្រាប្រាក់បៀវត្សយ៉ាងច្បាស់លាស់ សម្រាប់មន្ត្រីដែលចូលរួមក្នុងក្របខ័ណ្ឌនេះ។

[៣] យោងតាម UNCT : ការធ្លាក់ចុះសេដ្ឋកិច្ចសាកលៈ ឱកាស ឬវិបត្តិ (វិច្ឆិកា ២០០៩)។ ការងារចំនួន ៦៣.០០០ បានបាត់បង់នៅក្នុងវិស័យកាត់ដេរ។

និងពោត ជួបឧបសគ្គជាខ្លាំង ដោយសារតែការកើនឡើងលើការចំណាយក្នុងអំឡុងពេលដាំដុះ ហើយតម្លៃអន្តរជាតិធ្លាក់ចុះក្នុងអំឡុងពេលប្រមូលផលកន្លងមក។

ពីព្រោះយន្តការដោះស្រាយ តាមបែបប្រពៃណី (លក់កម្លាំងពលកម្ម និងចំណាកស្រុក) មិនមានដោយសារតែវិបត្តិហិរញ្ញវត្ថុការសិក្សាថ្មីៗនេះ ដែលធ្វើឡើងដោយសមាគមសេដ្ឋកិច្ចកម្ពុជាបង្ហាញថាលទ្ធផលដែលទទួលបានពីការកាត់បន្ថយភាពក្រីក្រកំពុងតែដើរថយក្រោយវិញ ដោយសារតែគ្រួសារនៅជនបទជាច្រើនកំពុងជួបប្រទះនឹង អសន្តិសុខស្បៀង កាត់បន្ថយការចំណាយលើសុខភាព ខ្ចីប្រាក់ដើម្បីចំណាយលើសុខភាព ការចំណាយប្រើប្រាស់ប្រចាំថ្ងៃ និងសងបំណុលចាស់។ ការកើនឡើងនៃបំណុលអាចធ្វើឱ្យគ្រួសារ ទាំងនេះក្លាយជាគ្រួសារងាយរងគ្រោះនៅក្នុងពេលអនាគត ដ៏ឆាប់ខាងមុខ ដោយសារតែគ្រួសារទាំងនេះមានឱកាសតិចតួចក្នុងការសងបំណុលទាំងនេះ។

តាមរយៈថវិកាជាតិ ដោយរួមមានជំនួយអភិវឌ្ឍន៍ រាជរដ្ឋាភិបាលគួរផ្តល់អាទិភាពលើតម្រូវការរបស់ប្រជាពលរដ្ឋងាយរងគ្រោះបំផុត និងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់អ្នកទាំងនោះ ដើម្បីធ្វើឱ្យងើបឡើងវិញពីវិបត្តិហិរញ្ញវត្ថុ និងមានភាពប្រសើរឡើងនៅក្នុងឆ្នាំ ២០១០។ សមាសធាតុសំខាន់សម្រាប់ការងើបឡើងវិញពីវិបត្តិហិរញ្ញវត្ថុ រួមមានការផ្តល់សំណាញ់សុវត្ថិភាពសង្គម សេវាសុខភាពសមរម្យរក្សាឱ្យកុមារ និងយុវជននៅសាលារៀន និងវិនិយោគលើវិស័យកសិកម្ម និងការអភិវឌ្ឍជនបទ បន្តកំណែទម្រង់របស់រាជរដ្ឋាភិបាល។ ការវិភាគតួរលេខរបស់ច្បាប់ថវិកាឆ្នាំ២០១០ ខាងក្រោម និងសំណូមពរដែលធ្វើឡើងជូនសមាជិកសភាសម្រាប់សម័យប្រជុំពេញអង្គរបស់សភាលើសេចក្តីព្រាងច្បាប់ថវិកា២០១០ ដែលបានប្រព្រឹត្តទៅនៅថ្ងៃច័ន្ទ ទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ត្រូវបានធ្វើឡើងដោយ យោងលើស្ថានភាពលំបាក និងបញ្ហា ប្រឈមនានា ដែលក្រុមប្រជាជនក្រីក្រ និងងាយរងគ្រោះបាន និងកំពុងជួបប្រទះ។

### ចំណូលថវិកាជាតិឆ្នាំ២០១០

ច្បាប់ថវិកាឆ្នាំ២០១០ ជាឧបករណ៍ដ៏សំខាន់បំផុតតែមួយគត់របស់រាជរដ្ឋាភិបាល ដើម្បីសម្រេចបាននូវទស្សនៈវិស័យរបស់ខ្លួន ដូចដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ សម្រាប់ឆ្នាំសារពើពន្ធ ២០១០ រាជរដ្ឋាភិបាលកម្ពុជារំពឹងថានឹងទទួលបានចំនួល ១.៩៧៦.៨ លានដុល្លារសហរដ្ឋអាមេរិក នៅក្នុងឆ្នាំនេះ ដែលមានការកើនឡើង ១២ ភាគរយ បើប្រៀបធៀបទៅនឹងចំណូលរំពឹងទុកក្នុងច្បាប់ថវិកាឆ្នាំ២០០៩។

ភាគច្រើននៃចំណូលថវិកាជាតិឆ្នាំ២០១០ ត្រូវប្រមូលពីក្នុងប្រទេស ដែលទទួលបានពីពន្ធលើតម្លៃបន្ថែម (៤៣២ លានដុល្លារសហរដ្ឋអាមេរិក) និងពន្ធផ្សេងៗ ថ្លៃឈ្នួល និងការផាកពិន័យបង់ដោយអ្នកប្រើប្រាស់ និងក្រុមហ៊ុន។ ទាំងចំណូលក្នុងស្រុក និងចំណូលពីពាណិជ្ជកម្មអន្តរជាតិ គឺជាចំណូលពន្ធស្ថិតនៅក្រោមខ្ទង់ចំណូលចរន្តរបស់រដ្ឋ។ ចំណូលមកពីប្រភពខាងក្រៅ[៤] ដែលដាក់បញ្ចូលទៅក្នុងច្បាប់ថវិកាមាន ២៥ ភាគរយនៃចំណូលដែលបានរំពឹងទុក ហើយថវិកាមួយផ្នែកនេះ ត្រូវបានប្រើសម្រាប់ចំណាយមូលធន (គម្រោងផែនការវិនិយោគសាធារណៈក្រោមក្រសួងពាក់ព័ន្ធនីមួយៗរបស់រាជរដ្ឋាភិបាល) នៃថវិកាជាតិ។

រាជរដ្ឋាភិបាលកម្ពុជាប្រមូលចំណូលទាំងនេះ ដើម្បីផ្តល់ទំនិញ និងសេវាសាធារណៈ និងដើម្បីកសាង និងអភិវឌ្ឍន៍ប្រទេសដូចមាន ចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

**ការអភិវឌ្ឍជាវិជ្ជមានចំពោះចំណូល ដែលមាននៅក្នុងច្បាប់ថវិកា២០១០នេះគឺ:**

១. ការបង្កើនអត្រាពន្ធផ្លូវចំពោះយានយន្ត ជាពិសេសជាមួយនឹងកំណើនខ្ពស់បំផុតទៅលើរថយន្តទេសចរណ៍ទំនើប និងដែលមានកំលាំងសេះខ្ពស់ និង

២. ការកំណត់ពន្ធលើអចលនទ្រព្យដែលមានអត្រា ០.១ ភាគរយ[៥] ក្នុងនោះមាន ដី ផ្ទះ អគារ និងសំណង់ផ្សេងៗ ដែលសង់ភ្ជាប់នឹងដីនោះ ដែលមានតម្លៃលើសពី ១០០ លានរៀល (ឬប្រហែល ២៤.០០០ ដុល្លារសហរដ្ឋ អាមេរិក)។ តម្លៃ

---

[៤] ចំណូលនេះគឺបានប្រភពមកពីហិរញ្ញប្បទានក្រៅប្រទេសដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ ឬម្ចាស់ជំនួយ។

### រូបភាព ២: ចំណែកនៃចំណូលថវិកាជាតិ តាមប្រភពសំខាន់ៗ នៅក្នុងច្បាប់ថវិកាឆ្នាំ២០១០




*ប្រភព: ច្បាប់ថវិកា ២០១០*

អចលនទ្រព្យត្រូវកំណត់តាមតម្លៃទីផ្សារ ដោយគណៈកម្មការវាយតម្លៃអចលនទ្រព្យ ដែលបង្កើតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មូលដ្ឋានគិតពន្ធនេះ គឺគិតតាមតម្លៃ ទីផ្សារនៃអចលនទ្រព្យទាំងនេះ ដោយកាត់បន្ថយនូវទឹកប្រាក់ចំនួន ១00 លានរៀល។ ទោះជាយ៉ាងណា ក៏មានការលើកលែងមួយចំនួនផងដែរ ចំពោះការយកពន្ធនេះ ក្នុងនោះរួមមានដីធ្លីកសិកម្ម អចលនទ្រព្យរដ្ឋ អចលនទ្រព្យ ដែលជាកម្មសិទ្ធិរបស់សហគមន៍ សម្រាប់គោលដៅសុទ្ធសាធខាងសាសនា និងសប្បុរសធម៌ ឬមិនសំដៅប្រាក់ចំណេញអចលនទ្រព្យជាកម្មសិទ្ធិរបស់បេសកកម្មការទូត ឬកុងសុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារកិច្ចសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលផ្សេងៗ។ វេទិកានៃអង្គការ មិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា សូមស្វាគមន៍ចំពោះការចេញឱ្យប្រើនូវច្បាប់ប្រមូលពន្ធលើអចលនទ្រព្យនេះ ដោយរំពឹងថានឹងជំរុញការវិនិយោគ និងបង្កើនផលិតភាពប្រើប្រាស់ដីធ្លី និងរារាំងការកាន់កាប់ដីទុកទំនេរ សម្រាប់លក់។

### ចំណាយចរន្តរបស់ក្រសួងអាទិភាព

ច្បាប់ថវិកាត្រូវចែកចេញជាពីរផ្នែកគឺថវិកាចរន្តដែលត្រូវផ្តល់ហិរញ្ញប្បទានដោយប្រភពធនធានក្នុងស្រុក និងផ្នែកមូលធននៃថវិកាដែលពឹងផ្អែកយ៉ាងខ្លាំងលើហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ (២៥ ភាគរយ នៃចំណូលសរុបពីប្រភពខាងក្រៅ)។ ការវិភាជន៍ថវិកានៅក្នុងច្បាប់ថវិកាឆ្នាំ២០១០ សម្រាប់ចំណាយចរន្ត (ដូចជា ប្រាក់ខែ ប្រាក់ឧបត្ថម្ភ ចំណាយលើការ ថែទាំបន្ទាប់បន្សំ ចំណាយប្រតិបត្តិការផ្សេងៗ) បង្ហាញរូបភាពចំរុះមួយសម្រាប់វិស័យការងាររបស់ក្រសួង ដែលត្រូវបានចាត់ថ្នាក់ថាជាក្រសួងអាទិភាពនៅក្នុង ឆ្នាំកន្លងមក។

តារាងទី ១ ខាងក្រោមនេះបង្ហាញថា ការបែងចែកថវិកាទៅឱ្យក្រសួងសុខាភិបាល ក្រសួងយុត្តិធម៌ និងក្រសួងអភិវឌ្ឍន៍ជនបទ បានកើនឡើង***លើមធ្យមភាគ*** (គូសចំណាំដោយពណ៌ប្រផេះ)។ ការវិភាជន៍ថវិកានេះជាការបែងចែកគួរឱ្យកោតសរសើរ និងស្របតាម តម្រូវការដែលបានទទួលស្គាល់គឺដើម្បី:

(១) ***លើកកម្ពស់ការផ្តល់សេវាថែទាំសុខភាព*** ជាពិសេសអង្គការ MEDiCAM បានផ្តល់អនុសាសន៍ថា កញ្ចប់ថវិកាគួរតែផ្តល់សេវាគាំពារសុខភាពមាតា និងទារកដោយឥតគិតថ្លៃ ដូចជា សេវាថែទាំសង្គ្រោះបន្ទាន់ ការផ្តល់សេវាសម្រាល ដោយឆ្មបជំនាញតាមមណ្ឌលសុខភាព ការថែទាំការឆ្លងមេរោគនៅពេលទារកទើបនឹងប្រសូត្រ និងការផ្តល់អាហារូបត្ថម្ភ សម្រាប់មាតា និងទារក។

[៥] ពន្ធនេះនឹងយកលើអចលនទ្រព្យដែលស្ថិតនៅក្នុងភូមិសាស្ត្ររដ្ឋបាលរាជធានី និងខេត្ត។

ប្រសិនបើគ្មានកញ្ចប់ថវិកាសម្រាប់សេវាទាំងអស់នេះទេ ប្រទេសកម្ពុជានឹងពុំមានលទ្ធភាពសម្រេច គោលដៅអភិវឌ្ឍន៍ សហសវត្សរ៍ ចំនុចទី៤ និងទី៥ទេ។

(២) ***លើកកម្ពស់ការបំពេញតួនាទីរបស់ប្រព័ន្ធតុលាការ***

(៣) ***ថែទាំ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធជនបទឲ្យមានផ្លូវថ្នល់ ការផ្គត់ផ្គង់ទឹកស្អាត និងធារាសាស្ត្រតាមទីជនបទ ដែលត្រូវការ*** ជាចាំបាច់សម្រាប់ផ្ដល់លទ្ធភាពបានប្រសើរដល់ការដឹកជញ្ជូនទៅកាន់ទីផ្សារ និងផលិតកម្មកសិកម្មប្រកបដោយទិន្នផលខ្ពស់។ ទាំងក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹកមានអាណត្តិសំខាន់មួយនៅក្នុងវិស័យនេះ និងចូលរួមចំណែកដល់ការវិនិយោគសាធារណៈនៅតាមតំបន់ទីជនបទដែលផ្ដល់ផលប៉ះពាល់ជាវិជ្ជមានពីការវិនិយោគនេះចំពោះកសិករខ្នាតតូច។

**តារាងទី ១: ចំណាយចរន្តតាមប្រភេទ និងតាមក្រសួងពាក់ព័ន្ធដែលបានជ្រើសរើស គិតជាលានដុល្លារ**

| | **ច្បាប់ថវិកាឆ្នាំ ២០០៩** | **ការអនុវត្តថវិកា ២០០៩** | **ច្បាប់ថវិកា ឆ្នាំ២០១០** | **ភាគរយនៃ ការអនុវត្តថវិកា ២០០៩** | **បំរែបំរួល ២០១០/២០០៩** |
|---|---|---|---|---|---|
| **ចំណាយចរន្តសរុប** | **១.០៦៤** | **១.១៥៣** | **១.២២៧** | **១០៨.៤%** | **១៥%** |
| **ក. រដ្ឋបាលទូទៅ** | **១៤៩** | **២០០** | **១៦៩** | **១៣៤.៥%** | **១៤%** |
| *រដ្ឋសភាជាតិ* | ២៥ | ២៥ | ២៨ | ១០០.០% | ១២% |
| *ក្រសួងយុត្តិធម៌* | ៧ | ៧ | ៩ | ១០០.១% | ៣០% |
| *អាជ្ញាធរសវនកម្មជាតិ* | ២ | ២ | ២ | ៩៨.១% | -១% |
| **ខ. ការពារជាតិ និងសន្តិសុខ** | **២១៩** | **៣១៩** | **២៨១** | **១៤៦.០%** | **២៨%** |
| **គ. វិស័យសង្គមកិច្ច** | **៣៩០** | **៤២៣** | **៤៤៦** | **១០៨.៥%** | **១៤%** |
| *ក្រសួងសុខាភិបាល* | ១២៣ | ១៣១ | ១៤៦ | ១០៦.៣% | ១៩% |
| *ក្រសួងអប់រំ យុវជន និងកីឡា* | ១៨១ | ១៩២ | ២០១ | ១០៦.០% | ១១% |
| *ក្រសួងកិច្ចការនារី* | ៦ | ៦ | ៧ | ៩៨.៩% | ៩% |
| *ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ* | ១៣ | ២២ | ១៤ | ១៧៦.០% | ១៣% |
| **ឃ. វិស័យសេដ្ឋកិច្ច** | **៨៨** | **៩៧** | **១០២** | **១១០.០%** | **១៦%** |
| *ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ* | ១៩ | ២០ | ២១ | ១០៦.០% | ១៤% |
| *ក្រសួងអភិវឌ្ឍន៍ជនបទ* | ១៦ | ១៦ | ២០ | ១០០.៤% | ៣០% |
| *ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់* | ៦ | ៦ | ៧ | ១០២.៤% | ១២% |
| *ក្រសួងធនធានទឹក និងឧតុនិយម* | ៨ | ៨ | ៩ | ៩៩.៥% | ១៧% |
| **៩៩. ចំណាយ (ចរន្ត) មិនទាន់បែងចែក** | **២១៨** | **១១៤** | **២២៨** | **៥២.៤%** | **៥%** |
| **ថវិកាផ្ដល់បន្ថែមដល់ខេត្ត-ក្រុង/ឃុំ-សង្កាត់** | **៤២** | **៤២** | **៦២** | **១០០.០%** | **៤៧%** |
| **ថវិកាត្រៀមបម្រុង/ចំណាយមិនបានគ្រោងទុក** | **១៤៥** | **១៤៤** | **១០០** | **៩៩.៨%** | **-៣១%** |

*ប្រភព: ច្បាប់ថវិកា ២០១០ និងឯកសារគ្រប់គ្រងថវិកាឆ្នាំ២០១០*

ចំនុចជាអវិជ្ជមាននៅក្នុងតារាងទី១បង្ហាញថាក្រសួងមួយចំនួន ដែលត្រូវបានចាត់ថ្នាក់ជាក្រសួងអាទិភាពនៅឆ្នាំចាស់ ទទួលបាន កំណើនតិចជាង កំណើនជាមធ្យមសម្រាប់ថវិកាចរន្តរបស់ខ្លួនដូចជា: ថវិកាចរន្តរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកិច្ចការនារី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងដែនដី នគរូបនីយកម្ម

និងសំណង់។

កំណើនថវិកាទាបចំពោះវិស័យអប់រំកំពុងក្លាយជាបញ្ហាប្រឈមមួយសម្រាប់វិស័យ នៅក្នុងការធ្វើឱ្យប្រសើរឡើងនូវគុណភាព អប់រំនាពេលបច្ចុប្បន្ន ដែលទាមទារឱ្យមានគ្រូបង្រៀនដែលមានសមត្ថភាព និងសម្ភារៈឧបទ្ទេសត្រឹមត្រូវ ដែលការចំណាយទាំងពីរ នេះបានមកពីថវិកាចរន្ត។ លើសពីនេះ កំណើនថវិកាសម្រាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺទាបជាងការរំពឹងទុកបើគេ ពិនិត្យមើលពីតម្រូវការឱ្យមានការវិនិយោគនៅក្នុងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មទៅកាន់កសិករ។ ចំនុចវិជ្ជមានគឺថាក្រសួង អាទិភាពបីស្ថិតនៅក្នុងចំណោមក្រសួងដែលបានទទួលកំណើនលើសពីកំណើន ជាមធ្យមដែលខ្ពស់ជាងគេចំនួន១០ ក្នុងនោះរួមមាន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងយុត្តិធម៌ និងក្រសួងសុខាភិបាល។

នៅក្នុងតារាងនេះដែរ ក៏បានបង្ហាញថាវិស័យការពារជាតិ និងសន្តិសុខ និងផ្នែករដ្ឋបាលទូទៅ បានចំណាយ លើសពី ថវិកាចរន្តដែលបានវិភាជន៍នៅក្នុងការប៉ាន់ស្មានការអនុវត្តថវិកាឆ្នាំ២០០៩ ហើយភាគរយដែលទទួលបានសម្រាប់វិស័យនេះ មានភាគរយខ្ពស់ជាងវិស័យសេដ្ឋកិច្ច និងសង្គម។ ការចំណាយលើសនៅក្នុងវិស័យរដ្ឋបាលទូទៅនេះគឺ បណ្តាលមកពីការចំណាយលើសនៅក្នុងក្រសួងមិនមែនអាទិភាព រួមមានទីស្តីការគណៈរដ្ឋមន្ត្រី (២០៦.៤ ភាគរយ) ក្រសួងមហាផ្ទៃ-រដ្ឋបាលទូទៅ (១៩៥ភាគរយ) និងគណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត (១៧២.៣ ភាគរយ)។ ការចំណាយលើសនេះ ភាគច្រើនបានមកពីការចំណាយមិនបានគ្រោងទុក (សូមមើលផ្នែក ការចំណាយមិនបានត្រៀមទុកខាងក្រោម)។ ការចំណាយលើសនេះ ត្រូវបានគេមើលឃើញថាកើតមានជាដដែលស្ទើរជារៀងរាល់ឆ្នាំក្នុងរយៈពេល ៤ឆ្នាំ ចុងក្រោយនេះ ឬចាប់តាំងពីចាប់ផ្តើមកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ក្នុងឆ្នាំ ២០០៥ (សូមមើលតារាង ២ ខាងក្រោម)។

**តារាង ២: ចំណាយចរន្តជាក់ស្តែង ជាភាគរយនៃថវិកាវិភាជន៍ នៅក្នុងច្បាប់ថវិកា ២០០៦-២០០៩**

| ក្រសួងពាក់ព័ន្ធ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩e |
|---|---|---|---|---|
| ទីស្តីការគណៈរដ្ឋមន្ត្រី | ១៧៣.៤% | ១៩០.៨% | ១៩១.0% | ២០៦.៤% |
| ក្រសួងមហាផ្ទៃ-ផ្នែករដ្ឋបាលទូទៅ | ១៩១.១% | ១៦០.២% | ១៣៥.៣% | ១៥៥.0% |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១៨៥.២% | ១៧២.៨% | ១៣០.៥% | ១១៤.1% |
| គណៈកម្មការជាតិរៀបចំការបោះឆ្នោត | ១១៣.0% | ១០៧៣.៥% | ៦៧៧.៩% | ១៧២.៣% |
| ក្រសួងការពារជាតិ | ១០៥.៤% | ១១៦.៣% | ១៤៧.២% | ១៥១.២% |
| ក្រសួងមហាផ្ទៃ-ផ្នែកសន្តិសុខសាធារណៈ | ១០៨.៨% | ១៣០.២% | ១៤០.១% | ១៣៧.0% |
| ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ៣៣៩.៣% | ៣៤៧.៥% | ៨០៩.៧% | ២៩១.៧% |

*ប្រភព: ឯកសារថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០១០ ភាគ១*

**ថវិកាបន្ថែមផ្តល់ជូនបណ្តាខេត្ត វិស័យការពារជាតិ និងសន្តិសុខប្រព័ន្ធសុវត្ថិភាពសង្គម គម្រោងប្រាក់លាភការ**

បន្ថែមដោយផ្អែកលើលទ្ធផលការងារ និងកន្សោមអាទិភាព បន្ថែមលើពន្ធលើអចលនទ្រព្យ 0.១ ភាគរយ ដើម្បីផ្តល់ប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ថវិកាបន្ថែមដែលមានការកើនឡើងផ្តល់ជូនខេត្ត-ក្រុង/ឃុំ-សង្កាត់ បង្ហាញពីវឌ្ឍនៈភាពនៅក្នុងដំណើរការអនុវត្តប្រព័ន្ធវិមជ្ឈការ។ បើប្រៀបទៅនឹងច្បាប់ថវិកាឆ្នាំ២០០៩ ថវិកាបន្ថែមផ្តល់ជូនខេត្ត-ក្រុង/ឃុំ-សង្កាត់ កើនឡើង ៤៧% រហូតដល់ ៦២ លានដុល្លារអាមេរិក ដែលគួរត្រូវបែងចែក ដើម្បីផ្តល់មូលនិធិដល់គម្រោងនៅកម្រិតឃុំ/សង្កាត់ ដែលឆ្លើយតបទៅនឹងតម្រូវការមូលដ្ឋាន។ ទោះជាយ៉ាងណា ចាប់តាំងពីឆ្នាំ២០០៩ ខ្ទង់ថវិកាខេត្ត-ក្រុង

[៦] សេចក្តីប្រកាសព័ត៌មាន: សេចក្តីថ្លែង នៅសេចក្តីសន្និដ្ឋាននៃបេសកកម្មបុគ្គលិកមូលនិធិរូបិយវត្ថុអន្តរជាតិប្រចាំកម្ពុជា ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០០៩។

និងថវិកាឃុំ-សង្កាត់ត្រូវបានដាក់រួមបញ្ចូលគ្នា ដែលមិនអាចឱ្យធ្វើការប្រៀបធៀបបាននូវវិភាជន៍សម្រាប់ខ្ទង់ថវិកា ទាំងពីរនេះបានឡើយ។ យោងតាមសេចក្តី អំណះអំណាងរបស់ឯកឧត្តម **គាត ឈន់** នៅលើទំព័រកាសែតភ្នំពេញប៉ុស្តិ៍ កាលពីថ្ងៃទី៧ ខែតុលាឆ្នាំ២០០៩ បានឱ្យដឹងថាឃុំ/សង្កាត់ នីមួយៗ នឹងទទួលបានថវិកាជាមធ្យមប្រមាណ ២២.៣០០ដុល្លារអាមេរិកក្នុងឆ្នាំ២០១០។

ដូចដែលបានរៀបរាប់ដោយមូលនិធិរូបិយវត្ថុអន្តរជាតិ IMF[៦] ការចំណាយកើនឡើងលើ វិស័យការពារជាតិ និងសន្តិសុខ (ពី ២១៩ លានដុល្លារអាមេរិកក្នុងឆ្នាំ២០០៩ ដល់ ២៨១ លានដុល្លារអាមេរិកក្នុងឆ្នាំ២០១០) នឹងមានឥទ្ធិពលលើការចំណាយលើវិស័យអាទិភាព។ នៅក្នុងកិច្ចប្រជុំរបស់ក្រុមការងារបច្ចេកទេសស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅខែកញ្ញា ឆ្នាំ២០០៩ អ្នកតំណាងជាន់ខ្ពស់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបញ្ជាក់ថា កំណើនលើចំណាយវិស័យការពារជាតិ បណ្តាលមកពីការផ្លាស់ប្តូរប្រព័ន្ធផ្តល់ប្រាក់ឧបត្ថម្ភរបស់យោធា ដែលនាំឱ្យកំណើនចំណាយប្រហាក់ប្រហែលនឹងសេវាមន្ត្រី រាជការស៊ីវិល។ អ្នកតំណាងជាន់ខ្ពស់របស់ក្រសួងក៏ បានបញ្ជាក់បន្ថែមទៀតថា កំណើនចំណាយការពារជាតិនេះត្រូវបាន កែតម្រូវនៅពេលដែលមានតម្រូវការការពារប្រទេស។ ទោះបីជា កំណើនចំណាយនេះ មានឥទ្ធិពលមួយផ្នែកទៅលើ សេដ្ឋកិច្ចកម្ពុជា ចំណាយទាំងនេះមានលក្ខណៈជាចំណាយចរន្ត និងមិនគួរចាត់ទុកជា កញ្ចប់ថវិកាដែលសម្រាប់ប្រើប្រាស់ សម្រួលដល់សេដ្ឋកិច្ចបណ្តោះអាសន្នឡើយ។ ទោះបីជាយ៉ាងណាការប្រកាសនៅក្នុងសេចក្តីថ្លែងហេតុភ្ជាប់ជាមួយនឹងសេចក្តីព្រាងច្បាប់ថវិកាជាតិ២០១០ ដែលថាប្រាក់លាភការមុខងារសម្រាប់ទាហានដែលនឹងត្រូវកែសម្រួលនឹងធ្វើឱ្យមានការផ្លាស់ប្តូរទៅលើការចំណាយក្នុងវិស័យការពារជាតិនេះ។

សេចក្តីថ្លែងហេតុក៏បានបញ្ជាក់ផងដែរថានឹងបង្កកកន្សោមអាទិភាព និងប្រាក់លាភការផ្អែកលើការអនុវត្តការងារ ជាក់ស្តែងសម្រាប់មន្ត្រីរាជការស៊ីវិលដែលទទួលបានជំនួយគាំទ្រយ៉ាងច្រើនពីដៃគូអភិវឌ្ឍន៍។ ប្រការនេះផ្ទុយទៅនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ កថាខណ្ឌ២៥ដែលបានបញ្ជាក់ថា "*នៅក្នុងនីតិកាលទី៤របស់រដ្ឋសភា រាជរដ្ឋាភិបាល នឹងបន្តពង្រីកកម្មវិធីកន្សោមអាទិភាព និង ប្រាក់លាភការផ្អែកលើការអនុវត្តការងារជាក់ស្តែងទៅកាន់ក្រសួង/ស្ថាប័ន អាទិភាពមួយចំនួនទៀត ដើម្បីធ្វើកំណែទម្រង់កាន់តែស៊ីជំរៅ តាមវិស័យនៅទូទាំងប្រទេស* "។ តម្រូវការឱ្យមានការថ្លឹងថ្លែងប្រយ័ត្នប្រយែង និងការពិនិត្យនូវចំណាយគឺមានសារៈសំខាន់ និងចាំបាច់គួរតែមានការវាយតម្លៃឡើងវិញ នូវហានិភ័យនៃឧបសគ្គនេះ ដែលអាចបន្ថយល្បឿនកំណែទម្រង់ដែលចាំបាច់ជាបន្ទាន់ព្រោះថា "*កម្ពុជាគ្មានជំរើសអ្វីផ្សេងក្រៅពីការបន្តជំរុញអនុវត្តយ៉ាងម៉ឺងម៉ាត់ និងហ្មត់ចត់បំផុតនូវកំណែទម្រង់ទាំងឡាយដែលបានដាក់ចេញកន្លងមក...*[៧]"។ ប្រការនេះ បញ្ជាក់ឱ្យឃើញថា តម្រូវការឱ្យមានការថ្លឹងថ្លែងនូវការវិភាជន៍ថវិកាគួរតែត្រូវសម្រេចឱ្យបានខណៈដែលកំណែទម្រង់នានា ក៏ចាំបាច់ត្រូវតែបន្តស្របពេលជាមួយគ្នាដែរ។ នេះគឺជាបញ្ហាប្រឈមដែលអ្នកធ្វើសេចក្តីសម្រេចចិត្តផ្នែកគោលនយោបាយគួរ តែដោះស្រាយដោយផ្អែកលើប្រយោជន៍របស់ប្រជាពលរដ្ឋរាប់លាននាក់ដែលនឹងទទួលប្រយោជន៍ពីកំណែទម្រង់ទាំងនោះ។

ការពិភាក្សាជាច្រើនបានធ្វើឡើងស្តីពីការពង្រីកសំណាញ់សុវត្ថិភាពសង្គមនៅប្រទេសកម្ពុជា ជាមួយនឹងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍កំពុងប្តេជ្ញាចិត្តចំពោះការពង្រីកសំណាញ់សុវត្ថិភាពសង្គមនេះ។ ច្បាប់ថវិកាឆ្នាំ២០១០ ពិតជាបង្ហាញ កំណើនថវិកាសម្រាប់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចាប់ពីការបែងចែកថវិកាចំនួន ៤៤,៣លានដុល្លារ អាមេរិកនៅឆ្នាំ ២០០៩ រហូតដល់ ៥២,៦លានដុល្លារអាមេរិកនៅច្បាប់ថវិកាឆ្នាំ២០១០។ លើសពីនេះទៀត វិភាជន៍មូលធនដែលផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ទៅ កាន់ក្រសួងនេះកើនឡើងពី១៣.៦ លានដុល្លារ ទៅ ១៨.៤ លានដុល្លារ។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា នឹងធ្វើការបំភ្លឺថា ថវិកាទាំងអស់នេះ នឹងត្រូវបែងចែកដល់ការចំណាយលើប្រព័ន្ធសុវត្ថិភាព សង្គមដែរឬទេ ហើយនរណាជាអ្នកទទួលផលចំពោះចំណាយកើនឡើងនេះ។

## ចំណាយមិនបានគ្រោងទុក ឬចំណាយត្រៀមបំរុង

ដូចមានចែងនៅក្នុងមាត្រាទី ២៥ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ថវិកាចំណាយមិនបានគ្រោងទុកទាំងនេះ ត្រូវបាន

---

[៧] យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី២ (កថាខ័ណ្ឌទី៤)

បែងចែកដល់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល គឺដោយអនុវត្តតាមអនុក្រឹត្យ តាមការស្នើសុំដែលធ្វើឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងដែលស្ថិតនៅក្រៅវង្វង់នៃការត្រួតពិនិត្យរបស់រដ្ឋសភាជាតិ។

នៅក្នុងច្បាប់ថវិកាឆ្នាំ២០១០ ការបែងចែកថវិកាសម្រាប់ចំណាយមិនបានគ្រោងទុក ត្រូវបានកាត់បន្ថយអស់ ៤៤ លានដុល្លារអាមេរិក ដោយធ្លាក់ចុះពី ១៤៤.៥ លានដុល្លារ ឆ្នាំ២០០៩ ដល់ត្រឹម ១០០ លានដុល្លារអាមេរិក។ ប្រទេសកម្ពុជា មានហេតុផលល្អៗ ជាច្រើន ដើម្បីរៀបចំថវិកា ក្នុងចំនួនជាក់លាក់ មួយសម្រាប់ការចំណាយមិនបានគ្រោងទុកដែលអាចមានដូចជាៈ ថវិកាទទួលបានពីម្ចាស់ជំនួយមានបរិមាណទាបជាងការរំពឹងទុក គ្រោះទឹកជំនន់ គ្រោះរាំងស្ងួត និងគ្រោះធម្មជាតិដទៃទៀត ដើម្បីធានាដល់សន្តិសុខជាតិ និងការការពារព្រំដែនកម្ពុជា។ យ៉ាងណាមិញ ដូចដែលបានឃើញនៅក្នុងសេចក្តីសង្ខេបដាច់ដោយឡែកស្តីពីការវិភាគលើការប្រើប្រាស់ ថវិកាចំណាយមិនបានគ្រោងទុករបស់រាជរដ្ឋាភិបាលចាប់ពីឆ្នាំ ២០០៥ ដល់ឆ្នាំ២០០៩ អនុក្រឹត្យដែលអនុម័តលើការចំណាយជាក់ស្តែង ហាក់ដូចជាផ្តល់កម្រិតនៃការពន្យល់មួយចំនួនស្តីពីការប្រើប្រាស់ថវិកាទាំងនេះ។ លទ្ធផលនៃការវិភាគលើចំណាយមិនបានគ្រោងទុកនេះ បង្ហាញថា ថវិកាទាំងនេះមិនត្រឹមតែបានប្រើប្រាស់សម្រាប់ចំណាយលើ "ហេតុការណ៍ដែលមិនបានគ្រោងទុក" ដូចជា គ្រោះទឹកជំនន់ គ្រោះរាំងស្ងួត ថវិកាទទួលបានពីម្ចាស់ជំនួយមានបរិមាណទាបជាងការរំពឹងទុកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវបានចំណាយលើតម្រូវការបន្ថែមរបស់ក្រសួងដែលបានគ្រោងទុកជាមុន ដូចជាការចំណាយលើការផ្គត់ផ្គង់អង្ករដល់ក្រុមហ៊ុនឯកជនចាប់តាំងពីឆ្នាំ ២០០៣ និងចំណាយបំរើដល់ការបោះឆ្នោត។

សម្រាប់ចំណាយមិនបានគ្រោងទុកប្រចាំឆ្នាំនេះដែលមាន ៨% នៃការចំណាយចរន្តសរុប អង្គការមិនមែនរដ្ឋាភិបាលស្នើសុំឱ្យរដ្ឋសភាជាតិ ត្រួតពិនិត្យថាតើមូលនិធិទាំងនេះ អាចបែងចែកទៅដល់វិស័យអាទិភាពដែលនឹងផ្តល់ប្រយោជន៍ដល់ប្រជាពលរដ្ឋក្រីក្រ និងក្រុមងាយទទួលរងគ្រោះ។

## ចំណាយមូលធន

តារាង "គ១ ឬគ២" ស្តីពីចំណាយមូលធននៅក្នុងច្បាប់ថវិកា២០១០ បង្ហាញថា ចំណាយមូលធនសរុបនៅឆ្នាំ ២០១០ នឹងមានចំនួនដល់ ៧៦១,៣លានដុល្លារអាមេរិក ដែលកើន ១៣% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០០៩។ តារាង ៣ ខាងក្រោម ផ្តល់សេចក្តីសង្ខេបរបស់ក្រសួងពាក់ព័ន្ធដែលថវិកាទាំងអស់មាន ៩៤% នៃចំណាយមូលធនទាំងអស់នៅក្នុងច្បាប់ថវិកា ឆ្នាំ២០១០។

តារាង ៣ បង្ហាញពីកំណើនសម្រាប់ចំណាយមូលធននៅក្នុងក្រសួង ដែលចូលរួមក្នុងការអភិវឌ្ឍវិស័យកសិកម្ម និងជនបទ។ ថវិកាមូលធនរួម សម្រាប់ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួង ធនធានទឹក និងឧតុនិយម កើនឡើងដល់ ៣៨លានដុល្លារអាមេរិក ដែលគួរតែមានផលប៉ះពាល់ជាវិជ្ជមាននៅតាមតំបន់ជនបទ ដែល៩០% នៃប្រជាជនក្រីក្រ[៨] កំពុងរស់នៅ។

ដូចមានបង្ហាញនៅក្នុងការវិភាគលើការអនុវត្តច្បាប់ថវិកាពីឆ្នាំកន្លងមក (សូមមើលការវិភាគច្បាប់ថវិកានៅឆ្នាំ២០០៨ និងឆ្នាំ ២០០៩) បកស្រាយពីថវិកាដែលបានបែងចែកទាំងនេះទៅលើការចំណាយជាក់ស្តែង បានបង្ហាញថាជាបញ្ហាប្រឈមមួយ។ ចំណុចនេះ ត្រូវបានធ្វើ ការបំភ្លឺឡើងវិញម្តងទៀត តាមភាពជាក់ស្តែងដែលថា គម្រោងចំនួន ៥២ របស់ក្រសួងកសិកម្ម គម្រោងចំនួន២៥ របស់ក្រសួង ធនធានទឹក និងគម្រោងចំនួន ២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ដែលបានគ្រោងនៅក្នុងច្បាប់ថវិកាឆ្នាំ២០០៩ ហាក់ដូចជា មិនបានអនុវត្តន៍ និងត្រូវបានរំកិលទៅក្នុងច្បាប់ថវិកាឆ្នាំ២០១០[៩]។ នេះបង្ហាញថា ក្រសួងទាំងបីនេះទំនងជាចំណាយមិនអស់ នូវថវិការបស់ខ្លួនម្តងទៀតនៅឆ្នាំ២០០៩ ការលំបាកដែលបានប្រឈមនៅក្នុងការអនុវត្តគម្រោងកសិកម្មក៏ត្រូវបានរៀបរាប់លម្អិតនៅក្នុងប្រអប់ទី១ខាងក្រោម ដែលពិពណ៌នាពីបញ្ហាប្រឈមដែលក្រសួងធនធានទឹក និងឧតុនិយម បានប្រឈមក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រនៅភាគពាយ័ព្យរបស់ខ្លួន ដែលបានទទួលកម្ចីហិរញ្ញប្បទានសហប្រតិបត្តិការចំនួន២០លានដុល្លារអាមេរិក ពីធនាគារអភិវឌ្ឍន៍អាស៊ី និងថវិកាជំនួយ ឥតសំណងចំនួន

[៨] សន្ទស្សន៍អត្រានៃភាពក្រីក្រសម្រាប់កម្ពុជាមានកំរិត ៣០,១ ភាគរយ ក្នុងឆ្នាំ២០០៧ "របាយការណ៍ស្ថានភាព និងនិន្នាការនៃភាពក្រីក្រនៅកម្ពុជា-ការអង្កេតសេដ្ឋកិច្ចសង្គមនៅកម្ពុជាឆ្នាំ២០០៧" ដែលបោះពុម្ពផ្សាយដោយធនាគារពិភពលោកឆ្នាំ២០០៩។

[៩] ក្រសួងផែនការៈ កម្មវិធីវិនិយោគសាធារណៈ ២០១០-២០១២ ខែឧសភា ឆ្នាំ២០០៩។

៤លានដុល្លារអាមេរិកពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD)។

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា សូមសំណូមពរឱ្យមានតួនាទីសំខាន់របស់រដ្ឋសភាជាតិ ទៅលើការត្រួតពិនិត្យ គុណភាពនៃជំនួយគាំទ្រដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍ដល់ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកសិកម្ម និងក្រសួងធនធានទឹក និងតើត្រូវចាត់វិធានការអ្វីខ្លះ ដោយរាជរដ្ឋាភិបាលដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ ដើម្បីអនុវត្តន៍គម្រោងអភិវឌ្ឍន៍ទាំងនេះប្រកបដោយប្រសិទ្ធភាពខ្ពស់ និងទាន់ពេលវេលា។

**តារាង ៣: ចំណាយមូលធននៅក្នុងច្បាប់ថវិកាឆ្នាំ២០១០ របស់ក្រសួងពាក់ព័ន្ធដែលបានជ្រើសរើស (គិតជា លានដុល្លាអាមេរិក)**

| | ២០០៩ | ២០១០ | ភាគរយនៃការកើនឡើង /ការថយចុះក្នុងឆ្នាំ ២០១០ធៀបនឹង២០០៩ |
|---|---|---|---|
| ***ចំណាយមូលធនសរុប*** | ***៦៧៣,៨*** | ***៧៦១,៣*** | ***១៣%*** |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៤,៨ | ១៨,៤ | ២៨៥% |
| ក្រសួងមហាផ្ទៃ | ១០,៧ | ២២,៣ | ១០៩% |
| ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ៨,២ | ១៣,៨ | ៦៧% |
| ក្រសួងធនធានទឹក និងឧតុនិយម | ៤៣,៩ | ៦៧,៤ | ៥៤% |
| ក្រសួងអភិវឌ្ឍន៍ជនបទ | ១៣,៩ | ២១,០ | ៥១% |
| ក្រសួងសាធារណការ និងដឹកជញ្ជូន | ១៩៥,៥ | ២៥៤,១ | ៣០% |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៥១,២ | ៥៨,៥ | ១៤% |
| ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ៤២,៦ | ៤៣,៩ | ៣% |
| ក្រសួងសុខាភិបាល | ១២៦,០ | ១២២,៦ | -៣% |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៣៨,៧ | ៣៣,០ | -១៥% |
| សាលារាជធានីភ្នំពេញ | ១៣,០ | ១០,៥ | -១៩% |
| ក្រសួងអប់រំ យុវជន និងកីឡា | ៦៣,១ | ៤៩,២ | -២២% |

*ប្រភព: ច្បាប់ថវិកា ២០១០*

តារាង ៤ បង្ហាញថាក្រសួងកសិកម្ម និងក្រសួងអភិវឌ្ឍន៍ជនបទមិនត្រូវបានផ្តល់ហិរញ្ញប្បទានគ្រប់គ្រាន់នៅក្នុងរយៈពេល ៤ឆ្នាំកន្លងមកនេះទេ ខណៈដែលក្រសួងធនធានទឹក និងឧតុនិយមមិនត្រូវបានផ្តល់ហិរញ្ញប្បទានគ្រប់គ្រាន់សម្រាប់ឆ្នាំ ២០០៦ និង២០០៧ ហើយចាប់ផ្តើមទទួលបានអាទិភាពរបស់ខ្លួន ក្នុងឆ្នាំ ២០០៨ និង ២០០៩ (ដោយទទួលបានហិរញ្ញប្បទានពីថវិការដ្ឋ)។ ប្រសិនបើគិតតែ ហិរញ្ញប្បទានពីប្រភពខាងក្រៅពីដៃគូអភិវឌ្ឍន៍នោះ ក្រសួងចំនួន៣ បានចំណាយមិនអស់ទៅតាមថវិការបស់ខ្លួននៅក្នុងឆ្នាំ២០០៨-២០០៩។ ទោះជាយ៉ាងណា គួរកត់សំគាល់ផងដែរថា ទន្ទឹមពេលដែលថវិការដ្ឋមានសម្រាប់ក្រសួងធនធានទឹក ចុះហេតុអ្វីបានជាក្រសួងពីរទៀត ដែលចាត់ទុកថាជាក្រសួងអាទិភាព និងចូលរួមចំណែកយ៉ាងសំខាន់ដោយផ្ទាល់ទៅនឹងការកាត់បន្ថយភាពក្រីក្រ មិនត្រូវបានគាំទ្រដោយថវិការដ្ឋនេះផងដែរ។

**តារាង ៤: ចំណាយមូលធនបាន់ស្មានជាភាគរយនៃថវិកាវិភាជន៍ ២០០៦-២០០៩ សម្រាប់ក្រសួងអាទិភាព**

| ក្រសួងអាទិភាព | ២០០៦ | ២០០៧ | ២០០៨e | ២០០៩e |
|---|---|---|---|---|
| ក្រសួងសុខាភិបាល | ៦០% | ៩៥% | ១១១% | ១២២% |
| ក្រសួងអប់រំ យុវជន និងកីឡា | ១៤៣% | ៧២% | ៨៥% | ៦៩% |
| ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ | ៣០% | ៣៩% | ២៥% | ៥០% |
| ក្រសួងធនធានទឹក និងឧតុនិយម | ៤១% | ៥៣% | ១១១% | ១១២% |
| ក្រសួងអភិវឌ្ឍន៍ជនបទ | ១០១% | ៥៧% | ៣២% | ៧០% |
| ក្រសួងដែនដី និងនគរូបនីយកម្ម និងសំណង់ | ១៧៣% | ១២% | ១៧៥% | ១២៤% |
| ក្រសួងយុត្តិធម៌ | ២៩៧% | ៣៥% | 0% | 0% |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ២% | 0% | 0% | 0% |
| ក្រសួងកិច្ចការនារី | ៣១% | ២៤% | ៨២% | ៩% |

*ប្រភព: ច្បាប់ទូទាត់ថវិកា ២០០៦-២០០៧ កម្មវិធីវិនិយោគសាធារណៈ ២០០៩-២០១១ និង២០១០-២០១២*

## ប្រអប់ ១: ការសង្ខេបនៃករណីសិក្សា[១០] : "ការអនុវត្តគម្រោងប្រព័ន្ធស្រោចស្រពភាគពាយ័ព្យ"

កម្ចីហិរញ្ញប្បទានសហប្រតិបត្តិការទំហំ២០លានដុល្លារអាមេរិកពីធនាគារអភិវឌ្ឍន៍អាស៊ីត្រូវបានអនុម័តទៅលើ "គម្រោងប្រព័ន្ធស្រោចស្រពភាគពាយ័ព្យ" កាលពីខែវិច្ឆិកា ឆ្នាំ២០០៣ដែលត្រូវបានបំពេញបន្ថែមចំនួន៤ លានដុល្លាទៀតដោយជំនួយឥតសំណងពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំង។ ទោះបីជាយ៉ាងណា ការអនុវត្តគម្រោងនេះ មិនបានចាប់ផ្តើមរហូតដល់ឆ្នាំ២០០៧ និងមកដល់ពេលបច្ចុប្បន្នមូលនិធិមួយផ្នែកធំនៅមិនទាន់ត្រូវបានចំណាយនៅឡើយ។ គម្រោងនេះធ្លាប់ត្រូវបានពន្យារពេលពីរ ទៅបីឆ្នាំ ដែលធ្វើឱ្យមានការចាប់អារម្មណ៍លើមូលហេតុនៃការអនុវត្តយឺត នៅពេលដែលកម្ពុជា កំពុងតែត្រូវការ ចាំបាច់នូវទំហំវិនិយោគយ៉ាងធំដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធធារាសាស្ត្រ។ ការពន្យល់របស់រាជរដ្ឋាភិបាល និងមន្ត្រីធនាគារអភិវឌ្ឍន៍អាស៊ីចំពោះ ការអនុវត្តគម្រោងនេះយឺតរួមមាន: ១) ធម្មជាតិនៃគម្រោង, ២) ដំណើរការលទ្ធកម្មគម្រោង និង ៣) កត្តាមនុស្ស (ការពឹង ផ្អែកលើទីប្រឹក្សាខាងក្រៅ និងការផ្លាស់ប្តូរនូវបុគ្គលិកទទួលខុសត្រូវនៅក្នុងក្រសួងធនធានទឹក និងឧតុនិយម។

ការពន្យារនៅក្នុងការអនុវត្តគម្រោងធ្វើឱ្យមានការពន្យារដល់អត្ថប្រយោជន៍ដែលត្រូវទទួលបានដូចជា: ទិន្នផលខ្ពស់ជាងមុន ចំណូលបន្ថែម សម្រាប់ កសិកររាប់ពាន់នាក់ និងការកាត់បន្ថយភាពក្រីក្រ។ តាមរយៈការធ្វើសម្ភាសន៍បានឱ្យដឹងថា ៦ឆ្នាំបន្ទាប់ពីកាលបរិច្ឆេទចាប់ផ្តើមគម្រោងដែលបានស្នើ បច្ចុប្បន្នមានការប្តេជ្ញាចិត្តខ្លាំងក្លា ដោយភាគីពាក់ព័ន្ធទាំងអស់ដើម្បីពន្លឿនការអនុវត្តគម្រោងធារាសាស្ត្រដែលនៅសេស សល់ចំនួន ១០ ទៀត។ ដោយមាន បទពិសោធន៍ និងមេរៀនក្នុងរយៈពេលពីរទៅបីឆ្នាំកន្លងមក រាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្ត និងជំនឿថា គម្រោងនេះនឹងត្រូវបញ្ចប់ត្រឹមឆ្នាំ ២០១០។

[១០] លទ្ធផលនៃការសិក្សានេះគឺជាលទ្ធផលសម្រេចបានបន្ទាប់ពីការសិក្សាធ្វើឡើងដោយលោក ច័ន្ទ សុផល ដែលផ្តល់ការសិក្សាស្រាវជ្រាវដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល នៅដើមឆ្នាំ២០០៩

## ឱនភាពថវិកា - និងថវិកាសម្រួលផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច

ឱនភាពថវិការបស់ប្រទេសកម្ពុជាកើនឡើងពី ២២ លានដុល្លារសហរដ្ឋអាមេរិក ក្នុងឆ្នាំ ២០០៩ ទៅ ៤៧,៦ លានដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ ២០១០។ ដូចបានបង្ហាញនៅក្នុងច្បាប់ថវិកា ឱនភាពថវិកាដែលបានកើនឡើងនឹងត្រូវទទួលបានពីថវិកាបម្រុងរបស់រដ្ឋាភិបាលក្នុងធនាគារជាតិដែលអាចនឹងបណ្តាលឱ្យមានសម្ពាធអតិផរណា លើលុយរៀល ក្នុងឆ្នាំ ២០១០។

បញ្ហាប្រឈមដែលប្រទេសកម្ពុជាបានជួបប្រទះក្នុងឆ្នាំ ២០០៨ និង២០០៩ ដូចបានពិពណ៌នាក្នុងសេចក្តីផ្តើម បង្ហាញពីភាពសមហេតុផលនៃចំណាយសាធារណៈដែលបានកើនឡើងដើម្បីបញ្ចៀសផលប៉ះពាល់នៃវិបត្តិលើអ្នកក្រីក្រ ការធានានូវស្ថេរភាពការងារ ការផ្តល់ការបណ្តុះបណ្តាលដល់អ្នកគ្មានការងារធ្វើ។ល។ ទោះបីជាយ៉ាងណា បទពិសោធន៍ក្នុងឆ្នាំ ២០០៨ បានបង្ហាញពីផលប៉ះពាល់ជាអវិជ្ជមាននៃអតិផរណាទៅលើជនក្រីក្រ ដូច្នេះវាមានសារៈសំខាន់ណាស់ដែលច្បាប់ថវិកាក្នុងពេលអនាគតគួរតែផ្តោតទៅលើការថ្លឹងថ្លែងឱ្យមានតុល្យភាពថវិកាឱ្យបានច្រើនជាងមុន និងជៀសវាង កុំឱ្យកើតមានអតិផរណា (ដូចបានបញ្ជាក់ពីចំណុចសំខាន់៧ក្នុងយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទីពីរ) និងបន្តប្រយុទ្ធ ប្រឆាំងនឹងភាពក្រីក្រដែលជាបញ្ហាអាទិភាព ដ៏ចម្បង។ សំណូមពរចំពោះច្បាប់ថវិកាជាតិនាពេលអនាគត នៅពេលដែលធ្វើការវិភាគកញ្ចប់ថវិកានៅក្នុងច្បាប់ថវិកាឆ្នាំ២០១០ បញ្ហាមួយកើតមានឡើងលើកម្រិតនៃការបន្សុីគ្នា រវាងច្បាប់ថវិកា និងយុទ្ធសាស្ត្រចតុកោណ ព្រមទាំងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដែលត្រូវបានបង្ហាញនៅក្នុងការវិភាគច្បាប់ថវិកាឆ្នាំ២០០៨ និង ២០០៩។ ចំនុចសំខាន់ដែលអាចត្រូវធ្វើឱ្យប្រសើរឡើងនៅក្នុងការចេញសេចក្តីព្រាងច្បាប់ថវិកា និងច្បាប់ថវិកានាពេលអនាគត និងអាចឱ្យរដ្ឋសភាជាតិ និងអង្គការសង្គមស៊ីវិលត្រួតពិនិត្យបានគឺ :

- រដ្ឋសភាជាតិគួរចោទសួរទៅកាន់រាជរដ្ឋាភិបាលអំពីមូលហេតុនៃការចំណាយមិនអស់របស់ក្រសួងអាទិភាព និងការចំណាយលើសរបស់ក្រសួងមិនមែនអាទិភាព ហើយដើម្បីធ្វើឱ្យរាជរដ្ឋាភិបាលមានការទទួលខុសត្រូវចំពោះការគ្រប់គ្រងមូលនិធិសាធារណៈទាំងនេះ បើគិតដល់តួនាទី ត្រួតពិនិត្យលើថវិកាជាតិ។
- រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដែលគាំទ្រវិស័យកសិកម្មគួរធ្វើការរួមគ្នាដើម្បីធ្វើឱ្យប្រសើរឡើងដល់ការអនុវត្តថវិកាដើម្បីធ្វើយ៉ាងណាជៀសវាងការចំណាយមិនអស់ ពីព្រោះថាប្រជាពលរដ្ឋក្រីក្រ និងងាយទទួលរងគ្រោះគឺជាអ្នកទទួលប្រយោជន៍ពីគម្រោងទាំងនេះ។ រាជរដ្ឋាភិបាលគួរផ្តល់អាទិភាពប្រើប្រាស់ធនធាន ដែលមានរបស់ខ្លួន ដូចជាចំណាយមិនបានគ្រោងទុកឱ្យទៅក្រសួងអាទិភាព។
- រួមបញ្ចូលការពិពណ៌នាលម្អិត ដែលពន្យល់ហេតុផលជំរុញឱ្យមានការបែងចែកថវិកា ដែលមាននៅក្នុងសេចក្តីព្រាងច្បាប់ថវិកាដល់សមាជិកសភា និងដែលអនុញ្ញាតឱ្យអ្នកវិភាគ ស្វែងយល់ពីវត្ថុបំណងគោលនយោបាយ ដែលស្តែងចេញតាមរយៈតួលេខនៃខ្ទង់ថវិកាដែលមាននៅក្នុងសេចក្តីព្រាងច្បាប់ថវិកាជាតិ។
- ជាមួយនឹងការពិពណ៌នានេះដែរសេចក្តីព្រាងច្បាប់ថវិកាជាតិ គួរពន្យល់ពីទំនាក់ទំនងនៃការបែងចែកថវិកាទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម(២០០៩-២០១៣) ដែលត្រូវរៀបចំឡើងដោយស្ថិតនៅក្រោមការដឹកនាំរបស់ក្រសួងផែនការ មានសក្តានុពលក្នុងការបញ្ចូល គ្នារវាងថវិការជាតិ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២។ ការបែងចែកគម្រោងចំណាយនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មតាមវិស័យ ដូចដែលបានប្រកាសនៅក្នុងសារាចរណែនាំ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម (ខែឧសភា ឆ្នាំ ២០០៩) គួរតែពិពណ៌នានៅក្នុងសេចក្តីព្រាងច្បាប់ថវិកានាពេលអនាគត ដោយសារតែវាអាចឱ្យសមាជិកសភាធ្វើការវាយតម្លៃឱ្យកាន់តែប្រសើរចំពោះ ភាពបន្សុីគ្នារវាងច្បាប់ថវិកា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២។
- លើសពីនេះទៀត ច្បាប់ថវិកាអាចត្រូវធ្វើឱ្យបានលម្អិតជាងនេះលើសពីវិភាជន៍ដុលជារួមសម្រាប់ក្រសួងនីមួយៗ ដើម្បីឱ្យសមាជិកសភាមានការជជែកវែកញែកលម្អិតជាងនេះទៀត។ លើសពីនេះទៀត រាជរដ្ឋាភិបាល ដាក់បញ្ចូលតួឡេន (តារាង)

ស្តីពីការអនុវត្តថវិកាប៉ាន់ស្មានសម្រាប់ឆ្នាំសារពើពន្ធបច្ចុប្បន្ន ចំពោះថវិកាមូលធន និងតួរលេខថវិកាចរន្តប៉ាន់ស្មាន ដែលភ្ជាប់ជាមួយ និងតួលេខផ្សេងៗទៀតដូចដែលមានបង្ហាញនៅក្នុងសេចក្តីសង្ខេបថវិកានៅឆ្នាំកន្លងមក (២០០៧ និង២០០៨) ពីព្រោះថាតួលេខទាំងពីរនេះនឹងផ្តល់ជាព័ត៌មានទៅដល់សមាជិក សមាជិការដ្ឋសភា អំពីស្ថានភាពការអនុវត្តថវិកាក្នុងឆ្នាំបច្ចុប្បន្ន។

- ជាចុងក្រោយ ការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ ឬកិច្ចប្រជុំពិភាក្សាជាសាធារណៈ[១១] ដាច់ដោយឡែករវាងសមាជិកសភា ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលអាចធ្វើឱ្យថវិកាជាតិមានការឆ្លើយតបកាន់តែប្រសើរឡើង ថែមទៀតចំពោះតម្រូវការរបស់ប្រជាពលរដ្ឋកម្ពុជា។

## ព័ត៌មានទំនាក់ទំនង

**សម្រាប់ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងអត្ថបទនេះ សូមទំនាក់ទំនង:**

**លោក វ៉ា សុធី មន្ត្រីគម្រោងថវិកាជាតិ**

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**

អាសយដ្ឋាន: អគារលេខ ៩-១១, ផ្លូវ ៤៧៦, សង្កាត់ទួលទំពូង១ ខណ្ឌចំការមន ភ្នំពេញ

ប្រអប់សំបុត្រលេខ ២២៩៥

ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១៤ ៤២៩

ទូរសារលេខ: (៨៥៥) ២៣ ៩៩៤ ០៦៣

អ៊ីម៉ែល: ngoforum@ngoforum.org.kh

គេហទំព័រ: www.ngoforum.org.kh

[១១] ចាប់ពីឆ្នាំ២០០៧រហូតដល់ពេលបច្ចុប្បន្នគណៈកម្មការទីពីរនៃរដ្ឋសភាជាតិបានសហការជាមួយនឹងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាក្នុងការរៀបចំនូវសិក្ខាសាលាសភាចំនួនបីលើកដែលផ្តោតលើការវិភាគ និងពិភាក្សាលើការវិភាជន៍ថវិកាក្នុងសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំ។ ទោះបីជាយ៉ាងណា ក៏ដោយសិក្ខាសាលា ពិភាក្សា ឬពិគ្រោះយោបល់នេះ គួរតែមានការពង្រីកឱ្យបានទូលំទូលាយ បន្ថែមទៀតដោយការរួមបញ្ចូលនូវអង្គការសង្គមស៊ីវិល និង សាធារណៈជន។

# លំហូរជំនួយនៃកម្មវិធីសម្បទានបរទេស ចំពោះប្រទេសកម្ពុជា

## សេចក្តីផ្តើម

ប្រទេសកម្ពុជានៅតែជាប្រទេសបន្តពឹងផ្អែកខ្លាំងលើជំនួយពីម្ចាស់ជំនួយដែលជិតពាក់កណ្តាលនៃថវិកាជាតិប្រចាំឆ្នាំរបស់ខ្លួនផ្តល់ហិរញ្ញប្បទានដោយម្ចាស់ជំនួយ (ពហុភាគី និងទ្វេភាគី) ដែលភាគច្រើនសម្រាប់គាំទ្រដល់ចំណាយមូលធន ឬ វិនិយោគសាធារណៈ។ ក្នុងអំឡុងពេលពីឆ្នាំ១៩៩២ ដល់ឆ្នាំ២០០៩ចំណាយហិរញ្ញប្បទានសហប្រតិបត្តិការសរុបផ្តល់មកកម្ពុជាមានចំនួន ៩,៧៩ ពាន់លានដុល្លារអាមេរិក។ គួរកត់សំគាល់ថាតួលេខទាំងអស់ខាងក្រោមត្រូវបានគិតជារូបិយប័ណ្ណដុល្លារអាមេរិក។ ចំណែកនៃជំនួយអភិវឌ្ឍន៍ផ្លូវការ ឬហិរញ្ញប្បទានសហប្រតិបត្តិការសរុបដែលទទួលបានពីដៃគូអភិវឌ្ឍន៍នីមួយៗពីឆ្នាំ១៩៩២ ដល់ឆ្នាំ២០០៩ រួមមានចំនួន ២,២៧ ពាន់លានដុល្លារ(ឬ២៣,២%)បានពីបណ្តាប្រទេសជាសមាជិកសហគមន៍អឺរ៉ុបនិងគណៈកម្មការអឺរ៉ុប ១,៨៣ ពាន់លានដុល្លារ(ឬ១៨,៧%)បានពីប្រទេសជប៉ុន ០,៩៨ពាន់លានដុល្លារ(ឬ១០%)បានពីធនាគារអភិវឌ្ឍន៍អាស៊ី ០,៨៦ពាន់លានដុល្លារ(ឬ៨,៨%)ផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាល (ជាធនធានផ្ទាល់របស់អង្គការមិនមែនរដ្ឋាភិបាល) ០,៨ពាន់លានដុល្លារ(ឬ៨,២%)បានពីអង្គការសហប្រជាជាតិ (មូលនិធិផ្ទាល់របស់អង្គការសហប្រជាជាតិ) ០,៦៦ពាន់លានដុល្លារ (ឬ៦,៨%) បានពីសហរដ្ឋអាមេរិក ០,៦៤ពាន់លានដុល្លារ(ឬ៦,៦%)បានពីធនាគារពិភពលោក ០,៥១ពាន់លានដុល្លារ (ឬ៥,៣%) បានពីប្រទេសចិន ០,៣៩ពាន់លានដុល្លារ(ឬ៤%)បានពីប្រទេសអូស្ត្រាលី និង ០,៨៣ពាន់លានដុល្លារ(ឬ៨,៥%)បានពីមូលនិធិសកលមូលនិធិរូបិយវត្ថុអន្តរជាតិម្ចាស់ជំនួយទ្វេភាគីដទៃទៀត(ដូចជាកូរ៉េខាងត្បូង) និងប្រភពផ្សេងទៀត។ នៅពេលធ្វើការចាត់ថ្នាក់ប្រភេទនៃម្ចាស់ជំនួយតាមក្រុមម្ចាស់ជំនួយទ្វេភាគីបានផ្តល់ចំណែកនៃជំនួយច្រើនជាងគេចំនួន ៣៩% បន្ទាប់មក មានអង្គការសហប្រជាជាតិ និងគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិបានផ្តល់ចំនួន ២៩% សហគមន៍អឺរ៉ុបបានផ្តល់ចំនួន ២៣% និងអង្គការមិនមែនរដ្ឋាភិបាល (ធនធានផ្ទាល់របស់អង្គការមិនមែនរដ្ឋាភិបាល)បានផ្តល់ចំនួន ៩%។

**រូបភាពទី ១:ជំនួយអភិវឌ្ឍន៍ផ្លូវការសរុបដែលបានទទួលពីឆ្នាំ ១៩៩២-២០០៩ មានចំនួន ៩,៧៩ ពាន់លានដុល្លារ**




*ប្រភព: របាយការណ៍ប្រសិទ្ធភាពជំនួយ ឆ្នាំ២០១០ ទំព័រ ៩*

ដោយមើលឃើញពីតួនាទីដ៏សំខាន់នៃជំនួយនៅកម្ពុជា វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាបានផ្តួចផ្តើមគម្រោងប្រសិទ្ធភាពជំនួយមួយក្នុងគោលបំណងប្រមូលផ្តុំការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាលក្នុងគ្រប់វិស័យដើម្បីលើកកំពស់កិច្ចសហប្រតិបត្តិការលើការត្រួតពិនិត្យនិងតស៊ូមតិពីបញ្ហាជំនួយបរទេស។ គំរោងនេះបានចាប់ផ្តើមតាំងពីឆ្នាំ២០០៨ ហើយបានអនុវត្តសកម្មភាពរបស់ខ្លួនជាលំដាប់ដោយធ្វើការងារយ៉ាងសកម្មលើបញ្ហាជាច្រើនលើការតស៊ូមតិជាមួយរាជរដ្ឋាភិបាល និងម្ចាស់ជំនួយដើម្បីសំរេចបានដោយជោគជ័យលើការអនុវត្តការប្តេជ្ញាចិត្តរបស់ខ្លួននៅក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស និងរបៀបវារៈក្រុងអាក្រាដើម្បីសកម្មភាព។ គោលដៅចុងក្រោយបំផុតរបស់គម្រោងនេះ គឺសំដៅជួយគាំទ្រគោលនយោបាយ និងការប្រតិបត្តិរបស់រាជរដ្ឋាភិបាល និងម្ចាស់ជំនួយដើម្បីធានាបាននូវប្រសិទ្ធភាពជំនួយ និងលទ្ធផលវិជ្ជមាននៃការអភិវឌ្ឍន៍។ គោលបំណងសំខាន់គឺតស៊ូមតិចំពោះការតឹមផលប្រយោជន៍ដែលបានពីជំនួយបរទេសសម្រាប់ជាគុណប្រយោជន៍ដល់វិស័យអាទិភាពដែលឆ្លើយតបទៅនឹងតំរូវការចាំបាច់របស់ប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះ(ដែលរួមទាំងស្ត្រី និងកុមារ)។

ព្រឹត្តិបត្រព័ត៌មាននេះ[១] ផ្តល់ការវិភាគពីល័ក្ខខ័ណ្ឌនៃជំនួយ[២] ដោយធ្វើការប្រៀបធៀបតាមម្ចាស់ជំនួយផ្អែកលើអត្រាការប្រាក់ប្រចាំឆ្នាំ រយៈពេលអនុគ្រោះ និង រយៈពេលសងរំលោះប្រាក់ដើមលើគ្រប់គម្រោងកម្ចីសម្បទានទាំងអស់។ ព្រឹត្តិបត្រព័ត៌មាននេះត្រូវបានរៀបរៀងឡើងដើម្បីផ្តល់ព័ត៌មានឱ្យកាន់តែប្រសើរឡើងអំពីនិន្នាការ និងល័ក្ខខ័ណ្ឌជំនួយនៃកម្ចីសម្បទាន បរទេសរបស់ម្ចាស់ជំនួយផ្សេងៗគ្នានៅកម្ពុជា។ ប៉ុន្តែគេគួរគប្បីកត់សំគាល់ថា វិសាលភាពនៃព្រឹត្តិបត្រព័ត៌មាននេះគ្របដណ្តប់ លើគម្រោងកម្ចីសម្បទានចំនួនត្រឹមតែ ១០៤[៣] ប៉ុណ្ណោះនៃគម្រោងជំនួយហិរញ្ញប្បទានសរុបទាំងអស់ចំនួន១.៣៣៧។ ទាំងនេះ មិនរាប់បញ្ចូលគម្រោងហិរញ្ញប្បទានដែលជាជំនួយឥតសំណងចំនួន១២៣០ និងគម្រោងកម្ចីមិនមែនសម្បទានចំនួន ៣ (ដែលជាគម្រោងមិនទាន់អនុម័តដែលមានតម្លៃសរុប ៣៩ លានដុល្លារ) ដែលត្រូវបានកត់ត្រានៅក្នុងទិន្នន័យជំនួយអភិវឌ្ឍន៍ផ្លូវការរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដែលត្រូវបានទាញយកនៅថ្ងៃទី៣ ខែមិថុនា និងត្រូវបានផ្ទៀងផ្ទាត់ម្តងទៀតនៅខែកក្កដា ឆ្នាំ២០១០។ ជាក់ស្តែងការរៀបចំព្រឹត្តិបត្រព័ត៌មាននេះជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួន ដូចជាទិន្នន័យគំរូតូច (ចំនួនគម្រោងតិចនៃម្ចាស់ជំនួយមួយចំនួន) និងព័ត៌មានមិនពេញលេញនៃគម្រោងខ្លះ (ពោលគឺអត្រាការប្រាក់រយៈពេលអនុគ្រោះ និងរយៈពេលសងរំលោះប្រាក់ដើម)។ ក្រៅពីនេះក៏មានការលំបាកក្នុងការគណនាពីរូបិយប័ណ្ណផ្សេងៗគ្នាតាមរយៈរយៈពេលនៃគម្រោងមួយចំនួន (ពោលគឺ ប្រាក់យេន យ៉ាន់ និងអឺរ៉ូ) ទៅជាដុល្លារអាមេរិកតែមួយ។ បញ្ហាប្រឈមទាំងអស់នេះអាចជះឥទ្ធិពលខ្លះដែរលើរបកគំហើញ និងអាចនាំឱ្យមានលទ្ធផលផ្សេងគ្នា ប្រសិនបើប្រៀបធៀបទៅនឹងរបាយការណ៍ប្រសិទ្ធភាពជំនួយឆ្នាំ២០១០។

បញ្ហាប្រឈមទាំងនេះបណ្តាលមកពីការលំបាកក្នុងការផ្តុំគម្រោងតាមវិស័យរបស់ម្ចាស់ជំនួយខ្លះដូចជា ធនាគារពិភពលោក ធនាគាអភិវឌ្ឍន៍អាស៊ី និងជប៉ុន។ អត្រាការប្រាក់ចំពោះគម្រោងទាំងនេះគឺមានលក្ខណៈផ្សេងគ្នាតាមវិស័យនីមួយៗ លើកលែងតែគម្រោងរបស់ប្រទេសចិនដែលភាគច្រើនផ្តល់មូលលិធិគាំទ្រដល់ការអភិវឌ្ឍន៍វិស័យហេដ្ឋារចនាសម្ព័ន្ធ។

---

[១] បន្ថែមលើកម្មវត្ថុចំបងខាងលើ ព្រឹត្តបត្រព័ត៌មាននេះ ក៏ជាប្រភពព័ត៌មានសំរាប់ការវិភាគស្រាវជ្រាវ និងសម្រាប់ការតាមដានលើល័ក្ខខ័ណ្ឌ លំអិតបន្ថែមទៀតដែលមាននៅក្នុងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ (ឬម្ចាស់ជំនួយ)។

[២] ការវិភាគនេះ ផ្តោតជាសំខាន់ទៅលើព័ត៌មានដែលប្រមូលបានពីទិន្នន័យជំនួយ អភិវឌ្ឍន៍ផ្លូវការដែលមានផ្សព្វផ្សាយ នៅក្នុងគេហទំព័ររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ប៉ុន្តែ ចំពោះព័ត៌មានអំពីល័ក្ខខ័ណ្ឌផ្សេងទៀត ក្រៅពីល័ក្ខខ័ណ្ឌខាងលើ ដែលភ្ជាប់ជាមួយនឹងកិច្ចព្រមព្រៀងនៃគម្រោងកម្ចីសម្បទានទាំងនេះ ដែលមួយផ្អែកចូលរួមចំណែកទៅក្នុងការសម្រេចចិត្តរបស់រាជរដ្ឋាភិបាល ទៅលើកម្ចីសម្បទានមិនមាននៅលើគេហទំព័រទេ។

[៣] ព័ត៌មានពីគម្រោងនីមួយៗត្រូវបានប្រមូលក្នុងកំឡុងខែមករា ដល់ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១០ ព្រមទាំងបានផ្ទៀងផ្ទាត់ម្តងទៀតក្នុងខែកក្កដា ឆ្នាំ២០១០ ដើម្បីធានាភាពជឿជាក់នៃព័ត៌មាន។

### សាវតារ

ទិន្នន័យជំនួយអភិវឌ្ឍន៍ផ្លូវការនៃប្រទេសកម្ពុជា គឺជាមូលដ្ឋាន ឬប្រព័ន្ធកត់ត្រាទិន្នន័យតែមួយគត់នៃជំនួយអភិវឌ្ឍន៍ផ្លូវការទាំងអស់សំរាប់ប្រទេសកម្ពុជា។ ប្រព័ន្ធទិន្នន័យនេះ ក៏ជាឧបករណ៍មានប្រសិទ្ធភាពសម្រាប់ជម្រុញ និងតាមដានការតម្រឹមជំនួយអភិវឌ្ឍន៍ផ្លូវការទៅនឹងអាទិភាពនានាដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ក្នុងនោះក៏រួមបញ្ចូលគោលការណ៍គ្រប់គ្រងជំនួយ ដែលមាននៅក្នុងផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និង លទ្ធផល (H-A-R Action Plan) របស់រាជរដ្ឋាភិបាលកម្ពុជា។ មូលដ្ឋានទិន្នន័យនេះផ្តល់លទ្ធភាពទទួលបានព័ត៌មានស្តីពីហិរញ្ញប្បទានគម្រោងជំនួយ និងគាំទ្រមុខងារចែករំលែកព័ត៌មាន ការរាយការណ៍ជាទៀងទាត់ និងសម្របសម្រួលព័ត៌មាន ដើម្បីជំរុញឱ្យមានការពិភាក្សា និងការអភិវឌ្ឍន៍ការអនុវត្តន៍ការគ្រប់គ្រងជំនួយឱ្យកាន់តែមានប្រសិទ្ធភាព ទាំងនៅកម្រិតវិស័យ និងក្រុមការងារបច្ចេកទេស។ ប្រព័ន្ធនេះបានក្លាយទៅជាផ្នែកដ៏សំខាន់ពេញលេញមួយដែលបានធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធជាតិសំរាប់ការគ្រប់គ្រងជំនួយដែលធានាឱ្យបាននូវអភិក្រមផ្អែកលើភស្តុតាង ឆ្ពោះទៅការជម្រុញប្រសិទ្ធភាពជំនួយ និងសម្រាប់ការតាមដានការចូលរួមចំណែកនៃជំនួយចំពោះការសម្រេចបានលទ្ធផលអភិវឌ្ឍន៍ដែលត្រូវបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ[៦]។

### ទិដ្ឋភាពរួមអំពីជំនួយដែលបានចំណាយសរុប ( កម្ចី និងជំនួយឥតសំណង) នៅកម្ពុជា

**រូបភាពទី ២: ជំនួយឬហិរញ្ញប្បទានសហប្រតិបត្តិការដែលបានចំណាយពីឆ្នាំ២០០១ ដល់ ២០០៩**




*ប្រភព: របាយការណ៍ប្រសិទ្ធភាពជំនួយនៃប្រទេសកម្ពុជា ឆ្នាំ ២០០៨ និង ២០១០*

រូបភាពទី ២ បង្ហាញពីនិន្នាការកំណើននៃចំណាយហិរញ្ញប្បទានសហប្រតិបត្តិការសរុបក្នុងរយៈពេលមួយទសវត្សចុងក្រោយ ។ កំណើនហិរញ្ញប្បទានសហប្រតិបត្តិការ ឬជំនួយសរុបកើនឡើងចំនួន ១៣៨លានដុល្លារចន្លោះឆ្នាំ២០០១ ដល់ ២០០៥។ កំណើនទឹកប្រាក់ជំនួយនេះបានកើនឡើងជិតពីរដងស្មើនឹង ៣៧៩លានដុល្លារ ពីឆ្នាំ២០០៥ ដល់ ២០០៩។ ទឹកប្រាក់ជំនួយឥតសំណងស្ថិតនៅថេរពីឆ្នាំ២០០១ ដល់២០០៤ គិតជាមធ្យម ៣៥៩លានដុល្លា មុននឹងកើនឡើងដល់ជិតប្រហែល ៧០០លានដុល្លារក្នុងឆ្នាំ២០០៩។ តួលេខទាំងនេះក៏បង្ហាញពីការធ្លាក់ចុះនៃជំនួយឥតសំណងចំនួន ១៩លានដុល្លារក្នុងឆ្នាំ២០០៧ ធៀបនឹងឆ្នាំ២០០៦។ ក្នុងរូបភាពដដែលចំណាយជាក់ស្តែងនៃកម្ចីសម្បទានបានកើនឡើងចំនួន ៥៨,៣លានដុល្លារ ក្នុងឆ្នាំ២០០២ ធៀបនឹងឆ្នាំ២០០១ ហើយមានការប្រែប្រួលឡើងចុះក្នុងរយៈពេលបួនឆ្នាំចុងក្រោយ មុនពេលមានការថយចុះចុងក្រោយចំនួន ៣៦,៩ លានដុល្លារ ក្នុងឆ្នាំ២០០៦ ហើយក្រោយមកបានកើនឡើងជាលំដាប់ដល់ ២៩០,៣ លានដុល្លារ ក្នុងឆ្នាំ២០០៩។ ប៉ុន្តែ

---

[៦] សៀវភៅណែនាំស្តីពីការប្រើប្រាស់មូលដ្ឋានទិន្នន័យជំនួយអភិវឌ្ឍន៍ផ្លូវការនៃប្រទេសកម្ពុជា ឆ្នាំ ២០០៧, កំណែ ២.១, http://cdc.khmer.biz ។

គេគប្បីកត់សម្គាល់ថា កំណើនជំនួយ(កម្ចី និងជំនួយឥតសំណង) មានកំរិតតិចតួចជាងការរំពឹងទុកពីឆ្នាំ២០០៨ ដល់ឆ្នាំ២០០៩ ប្រហែលជាដោយសារឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ចពិភពលោកដែលប៉ះពាល់ដល់ម្ចាស់ជំនួយទាំងនោះ។ ជារួមជំនួយសរុបដែលត្រូវបានផ្តល់ដល់ប្រទេសកម្ពុជានៅក្នុងទសវត្សចុងក្រោយនេះមានចំនួន ៦,១៤ពាន់លានដុល្លារ ក្នុងនោះមាន ១,៧៥ពាន់លានដុល្លារ (២៩%) គឺជាកម្ចីខណៈដែលជំនួយចំនួន ៤,៣៩ពាន់លានដុល្លារ (៧១%) គឺជាជំនួយឥតសំណង។ ក្នុងចន្លោះពេលនេះដែរភាគរយនៃជំនួយឥតសំណងធៀបនឹងជំនួយសរុបប្រចាំឆ្នាំដែលទទួលបានគិតជាមធម្យម បានធ្លាក់ចុះពី ៧៤%ក្នុងឆ្នាំ២០០១ ទៅ ៧១% ក្នុងឆ្នាំ២០០៩ ខណៈដែលភាគរយនៃកម្ចីធៀបនឹងជំនួយសរុបប្រចាំឆ្នាំគិតជាមធ្យម មាននិន្នាការកើនឡើងក្នុងរយៈពេលដូចគ្នាពី២៦% ក្នុងឆ្នាំ២០០១ ដល់ ២៩% ក្នុងឆ្នាំ២០០៩។

## ការវិភាគលើល័ក្ខខ័ណ្ឌជំនួយនៃគម្រោងឥណទានប្រាក់កម្ចីសម្បទាន

សូមយោងទៅលើតួលេខដែលបង្ហាញនៅក្នុងតារាងទី១ ខាងក្រោមដែលមានចំណងជើងថា ការវិភាគពីល័ក្ខខ័ណ្ឌជំនួយនៃកម្ចីសម្បទានតាមម្ចាស់ជំនួយដែលផ្តល់ដល់ប្រទេសកម្ពុជា។ នៅក្នុងតារាងនេះ គេឃើញថាអត្រាការប្រាក់ទាបបំផុតនៃកម្ចីសម្បទាន គឺ ០,០១% ក្នុង១ឆ្នាំ ដែលផ្តល់ដោយប្រទេសជប៉ុន ខណៈដែលអត្រាការប្រាក់ខ្ពស់បំផុតគឺ ២% ដែលផ្តល់ដោយប្រទេសចិន។ ប្រាក់កម្ចីសម្បទានមានចំនួនសរុបប្រមាណ ២,៥ពាន់លានដុល្លារ[៥] ជាមួយអត្រាការប្រាក់គិតជាមធ្យម ០,៩២% លើកម្ចីសម្បទាន គិតជាមធ្យមក្នុងមួយគម្រោង ប្រហែល ២៣.៧លានដុល្លារ។ តាមរយៈព័ត៌មានខាងក្រោមធនាគារអភិវឌ្ឍន៍អាស៊ីមានចំនួនគម្រោងក៏ដូចជាកម្ចី សម្បទានច្រើនជាងម្ចាស់ជំនួយផ្សេងទៀត។ គំរោងកម្ចីសម្បទាននេះមានចំនួនជិតស្មើពាក់កណ្តាលនៃចំនួនគម្រោងកម្ចីសម្បទាន សរុប(៥០គម្រោង) និង មានទំហំជាងមួយភាគបីនៃចំនួនប្រាក់កម្ចីសម្បទានសរុប (ជិត ១ពាន់លានដុល្លារ)។ តាមរយៈយន្តការនេះ ម្ចាស់ជំនួយភាគច្រើនផ្តល់អត្រាការប្រាក់ថេរចំពោះគម្រោងកម្ចីសម្បទានភាគច្រើនរបស់ពួកគេ។

ប្រទេសជប៉ុនគឺជាម្ចាស់ជំនួយឧបតោភាគីនៃប្រទេសកម្ពុជាដែលយកអត្រាការប្រាក់ត្រឹមតែ ០,០៣%ក្នុង១ឆ្នាំ សម្រាប់គម្រោងបីដែលមានទំហំទឹកប្រាក់កម្ចីសម្បទានចំនួន ៦៧ លានដុល្លារ និង ០,៩% សម្រាប់គម្រោង២ផ្សេងទៀតដែលមានទំហំប្រាក់កម្ចីជិត៧០លានដុល្លារ។ នេះជារបកគំហើញដ៏សំខាន់មួយ ពីព្រោះវាបង្ហាញថាជប៉ុនបានផ្តល់អត្រាការប្រាក់ទាបបំផុតមួយចំពោះគម្រោងរបស់ខ្លួនធៀបនឹងម្ចាស់ជំនួយផ្សេងទៀតនៅកម្ពុជា។ ជារួម ប្រទេសជប៉ុនផ្តល់កម្ចីសម្បទានដែលមានល័ក្ខខ័ណ្ឌជំនួយមានលក្ខណៈអនុគ្រោះច្រើនដោយយកអត្រាការប្រាក់ជាមធ្យម ០,៣៦% ក្នុងមួយឆ្នាំ ភ្ជាប់ជាមួយនឹងការផ្តល់រយៈពេលអនុគ្រោះ ១០ ឆ្នាំ និង រយៈពេលសងរំលោះកម្ចី ៣០ ឆ្នាំសម្រាប់គម្រោងកម្ចីសម្បទានទាំងអស់របស់ខ្លួន។

ប្រទេសកូរ៉េខាងត្បូង គឺជាម្ចាស់ជំនួយថ្មីមួយដែលបានចាប់ផ្តើមផ្តល់កម្ចីសម្បទានដល់ប្រទេសកម្ពុជាក្នុងឆ្នាំ២០០៦។ ប្រទេសនេះបានផ្តល់អត្រាការប្រាក់ ទាបបំផុត០,០១%ក្នុង១ឆ្នាំចំពោះគម្រោងដែលមានទំហំកម្ចីសម្បទានចំនួន ៦០លានដុល្លារ។ អត្រាការប្រាក់សម្រាប់គម្រោងផ្សេង ទៀតក៏មានកម្រិតទាបដែរ ត្រឹមអត្រាការប្រាក់ ០,៥% លើកម្ចីសម្បទានចំនួនជិត២៧ លានដុល្លារ និង អត្រាការប្រាក់ ១% លើកម្ចីសម្បទានចំនួន ១៧លានដុល្លារ។ ជាទូទៅប្រទេសកូរ៉េខាងត្បូងផ្តល់អត្រាការប្រាក់ទាប(០,៣៨%)ស្ទើរតែស្មើគ្នានឹងប្រទេសជប៉ុន(០,៣៦%)។ ប្រទេសកូរ៉េខាងត្បូងបានផ្តល់រយៈពេលអនុគ្រោះ ១០ឆ្នាំ និង រយៈពេលសងរំលោះ ២០ឆ្នាំ ដល់គម្រោងដែលមានអត្រាការប្រាក់ទាបស្រាប់ ដោយផ្អែកលើគម្រោង ២ ដែលមានទិន្នន័យសម្រាប់ការវិភាគនេះ។

---

[៥] គិតត្រឹមឆ្នាំ ២០០៩ ប្រាក់កម្ចីសរុប(ទាំងកម្ចីសម្បទាន និងមិនមែនសម្បទាន)ដែលកម្ពុជាខ្ចីពីម្ចាស់ជំនួយបរទេសមានចំនួនប្រហែល ៣ ពាន់លានដុល្លារអាមេរិក (២២៣ ដុល្លារសំរាប់មនុស្សម្នាក់ធៀបនឹងចំនួនប្រជាពលរដ្ឋ ១៣.៣៩៥.៦៨២) ដែលប្រកាសដោយឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងកំឡុងកិច្ចពិភាក្សា និងអនុម័តរបស់រដ្ឋសភាជាតិ លើសេចក្តីព្រាងច្បាប់ថវិកាឆ្នាំ២០១១ កាលពីខែវិច្ឆិកា ឆ្នាំ២០១០ ព្រមទាំងចុះផ្សាយដោយកាសែតរស្មីកម្ពុជានៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១០។ នេះមានន័យថា ប្រហែល៨៣% នៃកម្ចីសរុបផ្តល់កម្ពុជាគឺជាកម្ចីសម្បទាន ហើយការវិភាគពីនិរន្តរភាពនៃបំណុលដែលធ្វើរួមគ្នារវាងមូលនិធិហិរញ្ញវត្ថុអន្តរជាតិ និងធនាគារពិភពលោកឆ្នាំ ២០០៩ បានបង្ហាញប្រទេសកម្ពុជាមានហានិភ័យវិបត្តិបំណុលនៅមានកំរិតទាបនៅឡើយ។

## តារាង ១៖ ការវិភាគលើល័ក្ខខ័ណ្ឌជំនួយនៃកម្ចីសម្បទានបរទេសចំពោះប្រទេសកម្ពុជា

វិសាលភាព៖ មានគម្រោងកម្ចីសម្បទានចំនួនតែ ១០៤ ប៉ុណ្ណោះដែលអាចរកបាននៅក្នុងប្រព័ន្ធទិន្នន័យជំនួយអភិវឌ្ឍន៍ផ្លូវការ ។ ស្ថានភាពនៃបច្ចុប្បន្នភាពរបស់ទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ៖ គិតត្រឹមថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១០ ។

| ដៃគូអភិវឌ្ឍន៍ (គិតជា%នៃប្រាក់កម្ចីសរុប) | ទំហំប្រាក់កម្ចីសម្បទាន (ដុល្លារអាមេរិក) | អត្រាការប្រាក់ (%) | ចំនួនគម្រោង | រយៈពេលអនុគ្រោះ | | រយៈពេលសងរំលោះ | | ប្រភេទអត្រាការប្រាក់ (ចំនួនគម្រោង) | |
|---|---|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ | គម្រោង | ឆ្នាំ | គម្រោង | មិនប្រែប្រួល | ប្រែប្រួល |
| ជប៉ុន | ៦៧.៣៧១.៧៥៨ | 0,0១ | ៣ | ១០ ឆ្នាំ | ៥ | ៣០ ឆ្នាំ | ៥ | ៧ | |
| | ៦៩.៩២៤.៩០៨ | 0,៩ | ២ | | | | | | |
| (១0%) | ១១១.៨៣១.០១៧ | គ្មានទិន្នន័យ | ២ | | | | | | |
| | ២៤៩.១២៧.៦៨៤ | 0,៣៦** | ៧ | គ្មានទិន្នន័យ | ២ | គ្មានទិន្នន័យ | ២ | | |
| កូរ៉េខាងត្បូង | ៥៩.៩៦0.000 | 0,0១ | ២ | ១០ ឆ្នាំ | ២ | ២០ ឆ្នាំ | ២ | ៧ | |
| | ២៦.៧00.000 | 0,៥ | ១ | | | | | | |
| (៧%) | ១៧.0៥0.000 | ១,00 | ១ | ១៥ ឆ្នាំ | ១ | ២៥ ឆ្នាំ | ២ | | |
| | ៨៤.៩១៥.៩១៨ | គ្មានទិន្នន័យ | ៤ | | | | | | |
| | ១៨៨.៦២៥.៩១៨ | 0,៣៨** | ៨ | គ្មានទិន្នន័យ | ៥ | គ្មានទិន្នន័យ | ៤ | គ្មានទិន្នន័យ | ១ |
| សហគមន៍អឺរ៉ុប/គណៈកម្មការអឺរ៉ុប | ១៤.៧១៨.៣១៨ | 0,0២ | ១ | ១ ឆ្នាំ | ១ | ៥ ឆ្នាំ | ១ | ៧ | ៣ |
| | ២៥.៤៨៧.៧៨២ | 0,៧៥ | ២ | ៤ ឆ្នាំ | ១ | ១០ ឆ្នាំ | ១ | | |
| | ៥៣.៤៤៥.២៣០ | គ្មានទិន្នន័យ | ៧ | ១០ ឆ្នាំ | ២ | ៤០ ឆ្នាំ | ២ | | |
| (៣%) | ៩៣.៦៥១.៣៣០ | 0,៥** | ១០ | គ្មានទិន្នន័យ | ៦ | គ្មានទិន្នន័យ | ៦ | | |
| ធនាគារពិភពលោក | ៥.000.000 | 0,៧៥ | ១ | ១០ ឆ្នាំ | ១៥ | ៤០ ឆ្នាំ | ១៥ | ១៤ | |
| | ១៩៣.000.000 | ១,២៥ | ៩ | | | | | | |
| (១២%) | ៨៨.៦១0.000 | គ្មានទិន្នន័យ | ៥ | | | | | | |
| | ២៨៦.៦១0.000 | ១,២** | ១៥ | | | | | គ្មានទិន្នន័យ | ១ |
| ធនាគារអភិវឌ្ឍន៍អាស៊ី | ៤៤៧.១៧0.១00* | ១ | ២៤ | ៨ ឆ្នាំ | ២៨ | ២៤ ឆ្នាំ | ៧ | ៤៣ | ៧ |
| | ៤១៩.៧៦0.000 | ១,៥ | ២១ | | | ៣២ ឆ្នាំ | ២0 | | |
| (៣៨%) | ៨៣.៣00.000 | គ្មានទិន្នន័យ | ៥ | ១០ ឆ្នាំ | ១ | ៤០ ឆ្នាំ | ២ | | |
| | ៩៥0.២៣0.១00 | ១,២៣** | ៥0 | គ្មានទិន្នន័យ | ២១ | គ្មានទិន្នន័យ | ២១ | | |
| ចិន (៣0%) | ១៣៧.៩២៥.000 | ១,២៥ | ២ | ៧ ឆ្នាំ | ១១ | ១៣ ឆ្នាំ | ១១ | ១៣ | |
| | ៦0.៣៩៨.៣៥៦ | ១,៧៥ | ១ | ១០ ឆ្នាំ | ១ | | | | |
| | ៥0២.២៧៥.២៥0*** | ២ | ១០ | ២០ ឆ្នាំ | ១ | ២០ ឆ្នាំ | ៣ | | |
| | ៧00.១៩៨.៦0៥ | ១,៨៦** | ១៤ | គ្មានទិន្នន័យ | ១ | | | គ្មានទិន្នន័យ | ១ |
| សរុប | ២.៤៦៨.៤៤៣.៦៣៧ | 0,៩២ | ១០៤ | គ្មានទិន្នន័យ | ៣៥ | គ្មានទិន្នន័យ | ៣៣ | គ្មានទិន្នន័យ | ៣ |

**កំណត់សម្គាល់:**

* ចំនួនសរុបនៃប្រាក់កម្ចីសម្រាប់គម្រោងចំនួន ២៣ លើកលែងតែគម្រោងទី ២៤ ដោយសារមិនមានទិន្នន័យទំហំប្រាក់កម្ចី

** អត្រាការប្រាក់ជាមធ្យមត្រូវបានគណនាតាមរយៈការចែកទឹកប្រាក់កម្ចីសម្បទានសរុបនឹងចំនួននៃគម្រោងសរុបរបស់ម្ចាស់ជំនួយនីមួយៗ

*** ចំនួនសរុបនៃប្រាក់កម្ចីរបស់ប្រទេសចិនមានត្រឹមតែ ៩ គម្រោងប៉ុណ្ណោះ ដោយសារគម្រោងមួយមិនមានទិន្នន័យ ។

- ប្រទេសចិនមានចំនួន ១៤គម្រោងនៃកម្ចីសម្បទាន (អត្រាការប្រាក់គម្រោងមួយនៃគម្រោងទាំងអស់មិនមានទិន្នន័យបញ្ជាក់)
- ការកត់ត្រាប្រាក់កម្ចីក្រៅពីប្រាក់ដុល្លារអាមេរិកត្រូវបានប្តូរដោយផ្អែកលើអត្រាប្តូរប្រាក់ នៅឆ្នាំចាប់ផ្តើមគម្រោងលើកលែងតែគម្រោងដែលគេមិនដឹងដោយផ្អែកលើអត្រាប្តូរប្រាក់ក្នុងឆ្នាំ ២០១០ ដោយសារគម្រោងភាគច្រើនគឺមានអត្រាថេរ ។ អត្រាប្តូរប្រាក់នេះត្រូវបានគណនាតាមរយៈគេហទំព័រ: _http://www.bankofcanada.ca/en/rates/exchform.html_
- គ្មានទិន្នន័យ: មានន័យថាមិនអាចរកបាននៅក្នុងប្រព័ន្ធទិន្នន័យអភិវឌ្ឍន៍ផ្លូវការក្នុងគេហទំព័ររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាឬមិនអាចកំណត់បាន
- អត្រាការប្រាក់គិតជាមធ្យម ០,៩២% សម្រាប់ទឹកប្រាក់កម្ចីជាមធ្យម ២៣.៧ លានដុល្លារអាមេរិកក្នុង១ គម្រោង

សហគមន៍អឺរ៉ុបយកអត្រាការប្រាក់ទាប 0.0២%ក្នុង១ឆ្នាំ ចំពោះគម្រោងកម្ចីសម្បទានមួយដែលមានទឹកប្រាក់ជិត ១៥ លានដុល្លារ និងអត្រាការប្រាក់ ០,៧៥% ចំពោះគម្រោងពីរដែលមានទឹកប្រាក់សរុបចំនួន២៥លានដុល្លារ ។ ទោះបីជាយ៉ាងណាក៏ដោយ អត្រាការប្រាក់របស់គម្រោងចំនួនប្រាំមួយផ្សេងទៀតដែលមានចំនួនទឹកប្រាក់សរុប ៥៥ លានដុល្លារ មិនត្រូវបានកត់ត្រានៅក្នុងប្រព័ន្ធទិន្នន័យជំនួយអភិវឌ្ឍន៍ផ្លូវការទេ។ អត្រាការប្រាក់របស់សហគមន៍អឺរ៉ុបមានកំរិតខ្ពស់ជាងប្រទេសជប៉ុន និង ប្រទេសកូរ៉េខាងត្បូង ដែលមានអត្រាការប្រាក់ជាមធ្យមចំនួន០,៥% ។ ទោះបីជាមានអត្រាការប្រាក់ទាប បើប្រៀបធៀបជាមួយ នឹងម្ចាស់ជំនួយផ្សេងទៀតក៏ដោយ(លើកលែងប្រទេសជប៉ុន និងកូរ៉េខាងត្បូង) សហគមន៍អ៊ឺរ៉ុបផ្តល់រយៈពេលខ្លីបំផុតសម្រាប់រយៈពេលអនុគ្រោះ (១ឆ្នាំទៅ៤ឆ្នាំ)និងរយៈពេលសងរំលោះ(៩ឆ្នាំទៅ១០ឆ្នាំ) ។ ករណីនេះយោងទៅលើគម្រោងតែពីរប៉ុណ្ណោះ។ ស្រដៀងគ្នានេះដែរ ធនាគារពិភពលោក និងសហគមន៍អឺរ៉ុបផ្តល់រយៈពេលអនុគ្រោះចំនួន ១០ឆ្នាំ និងរយៈពេលសងរំលោះ ៤០ឆ្នាំសម្រាប់គម្រោងពីរផ្សេងទៀត ។ ដោយសារមានម្ចាស់ជំនួយទ្វេភាគីផ្សេងៗគ្នានៅក្នុងសហគមន៍នេះ ករណីនេះមិនតំណាងឱ្យក្រុមប្រទេសនៅក្នុងសហគមន៍អឺរ៉ុបជារួមបានឡើយ ។

នៅក្នុងចំណោមគម្រោងចំនួន ១៥របស់ធនាគារពិភពលោក មានតែគម្រោង ១ ប៉ុណ្ណោះដែលមានកម្ចីសម្បទានស្មើនឹង ៥ លានដុល្លារ ដែលធនាគារនេះបានយកអត្រាការប្រាក់ ០,៧៥% ក្នុង១ឆ្នាំខណៈដែលគម្រោងចំនួន ៩ ដែលមានតម្លៃជាទឹកប្រាក់ចំនួន ១៩៣លានដុល្លារ ត្រូវបានយកអត្រាការប្រាក់ ១,២៥%។ អត្រាការប្រាក់របស់ធនាគារពិភពលោក សម្រាប់គម្រោងចំនួន ៥ ផ្សេងទៀតដែលមានទំហំទឹកប្រាក់កម្ចីសម្បទានចំនួន ៨៩ លានដុល្លារ មិនត្រូវបានយកមកវិភាគនៅក្នុងឯកសារនេះទេ ដោយសារព័តិមានស្តីពីអត្រាការប្រាក់មិនអាចរកបាន។ ទោះបីជាយ៉ាងណាក៏ដោយ តាមរយៈទិន្នន័យដែលមាន អត្រាការប្រាក់ជាមធ្យមរបស់ធនាគារពិភពលោកគឺ១,២%។ ម្យ៉ាងទៀត ធនាគារពិភពលោក និងប្រទេសជប៉ុន ហាក់ដូចជាមានការកំរិតនូវបទដ្ឋានផ្ទាល់ខ្លួនសម្រាប់រយៈពេលអនុគ្រោះ ១០ ឆ្នាំ និង រយៈពេលសងរំលោះ ៤០ ឆ្នាំ និង ៣០ឆ្នាំ រៀងគ្នា។

ក្នុងចំណោមគម្រោងសរុបចំនួន ៤៩ ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់កម្ចីសម្បទានជូនប្រទេសកម្ពុជាចំនួន ៤៤៧ លានដុល្លារ សម្រាប់គម្រោងចំនួន ២៣ ជាមួយអត្រាការប្រាក់ ១%ក្នុង១ឆ្នាំ និង ចំនួន ៤២០ លានដុល្លារ ជាមួយអត្រាការប្រាក់ ១,៥% លើគម្រោងចំនួន ២១។ ចំណែកឯអត្រាការប្រាក់នៃគម្រោងចំនួន ៥ទៀត ដែលមានតំលៃជិត ៨៤ លានដុល្លារ មិនអាចរកបាននៅក្នុងប្រព័ន្ធទិន្នន័យឡើយ។ ជាមធ្យម អត្រាការប្រាក់ដែលយកដោយធនាគារអភិវឌ្ឍន៍អាស៊ីមានអត្រា ១,២៣%។ ធនាគារអភិវឌ្ឍន៍អាស៊ីផ្តល់រយៈពេលអនុគ្រោះ ៨ ឆ្នាំ និង រយៈពេលសងរំលោះ ៣២ ឆ្នាំ។

ប្រព័ន្ធទិន្នន័យជំនួយអភិវឌ្ឍន៍ផ្លូវការបានកត់ត្រាគម្រោងចំនួនត្រឹមតែ១៤ ដែលប្រទេសចិនបានផ្តល់ប្រាក់កម្ចីសម្បទានជូនប្រទេសកម្ពុជា។ គម្រោងទាំងនេះមានទឹកប្រាក់ចំនួន ៥០២ លានដុល្លារដែលអត្រាការប្រាក់ស្មើ២%ក្នុង ១ឆ្នាំ។ ទន្ទឹមនឹងនេះ គម្រោងចំនួន ២ផ្សេងទៀត ដែលមានទំហំទឹកប្រាក់កម្ចីសម្បទានចំនួន ១៣៨ លានដុល្លារ ត្រូវបានយកការប្រាក់ ១,២៥% និង

គម្រោងមួយ ផ្សេងទៀតដែលមានទឹកប្រាក់ប្រហែល ៦០ លានដុល្លារ ត្រូវបានយកអត្រាការប្រាក់ ១,៧៥%។ ប្រទេសចិនបានយកអត្រាការប្រាក់ ខ្ពស់ជាងគេបំផុតនៅក្នុងបរិបទនៃការប្រៀបធៀបនេះដែលយកអត្រាការប្រាក់ជាមធ្យម១,៨៦%។ លើសពីនេះទៀត កម្ចីសម្បទានរបស់ចិនដែលផ្តល់ភាគច្រើនក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ ជាមធ្យមផ្តល់អត្រាការប្រាក់ ១,៨៧%ក្នុង១ឆ្នាំ ដោយផ្អែកលើព័ត៌មានអំពីគម្រោងដែលមាន។ អត្រានេះនៅមានកំរិតខ្ពស់ បើប្រៀបធៀបជាមួយនឹងម្ចាស់ជំនួយផ្សេងទៀតដែលផ្តល់ជំនួយ ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធដូចគ្នាដែលមានល័ក្ខខ័ណ្ឌជំនួយមានលក្ខណៈអនុគ្រោះជាងរួមមាន ធនាគារអភិវឌ្ឍន៍អាស៊ី(១,២៣%) ធនាគារពិភពលោក(១,២%) ប្រទេសជប៉ុន(០,៣៧%) និងសាធារណៈរដ្ឋកូរ៉េ ឬកូរ៉េខាងត្បូង(០,៣៨%)។ លើសពីនេះទៀត ល័ក្ខខ័ណ្ឌជំនួយប្រទេសចិនក៏នៅមានលក្ខណៈអនុគ្រោះមានកំរិតទាបនៅឡើយ ដែលមានរយៈពេលអនុគ្រោះ ៧ឆ្នាំ និង រយៈពេលសងរំលោះមានចំនួន ១៣ឆ្នាំ ដោយមិនរាប់បញ្ចូលនូវគម្រោងចំនួន ២ ដែលយកអត្រាការប្រាក់ ២% ដោយមានរយៈពេលសងរំលោះដល់ ២០ឆ្នាំ។ ជារួម ដោយផ្អែកលើស្ថានភាពជាក់ស្តែង និងការប្រៀបធៀបខាងលើ គេឃើញថាប្រទេសចិនផ្តល់នូវ ល័ក្ខខ័ណ្ឌជំនួយដែលមានលក្ខណៈអនុគ្រោះតិចជាងគេទៅលើកម្ចីសម្បទានដែលផ្តល់មកកម្ពុជា។

ក្រៅពីការពិភាក្សាទៅលើល័ក្ខខ័ណ្ឌជំនួយ គម្រោងកម្ចីសម្បទានសហប្រតិបត្តិការចំនួន៣៣នៃគម្រោងសរុបចំនួន១០៤ ដែលបានដាក់បញ្ចូលនៅក្នុងតារាងខាងលើមិនមានព័ត៌មានបញ្ជាក់អំពីរយៈពេលអនុគ្រោះ ឬក៏រយៈពេលសងរំលោះ ខណៈដែលគម្រោងចំនួន ២ផ្សេងទៀតមានតែព័ត៌មានលើរយៈពេលអនុគ្រោះ (ជារួមមានចំនួន ៣៥ គម្រោង ឬក៏ស្មើនឹង៣៤%)។ ក្នុងចំណោមគម្រោងចំនួន ៣៣ នេះ មានគម្រោងចំនួន ២៣ ក៏មិនមានព័ត៌មានស្តីពីអត្រាការប្រាក់ផងដែរ ខណៈដែលមានតែគម្រោងចំនួន ៣ប៉ុណ្ណោះ មិនមានព័ត៌មានទៅលើប្រភេទអត្រាការប្រាក់របស់ពួកគេ។ គួរកត់សំគាល់ថា គម្រោងកម្ចីសម្បទានទាំង១០៤នេះមានទំហំទឹកប្រាក់សរុបចំនួន ២,៤៧ ពាន់លានដុល្លារ ដែលមានចំនួន ០,៧២ ពាន់លានដុល្លារច្រើនជាងកម្ចីដែលកម្ពុជាបានទទួលពីឆ្នាំ២០០១-២០០៩ (១,៧៥ពាន់លានដុល្លារ) ដែលកត់ត្រានៅក្នុងរបាយការណ៍ប្រសិទ្ធិភាពជំនួយ ឆ្នាំ២០០៨ និង២០១០។ ការវិភាគនេះមិនអាចផ្តល់ព័ត៌មានជាក់លាក់ពីកាលបរិច្ឆេទនៃគម្រោងកម្ចីសម្បទាន ដែលផ្តល់មកកម្ពុជា ដោយសារតែគម្រោងចំនួន ២២នៃគម្រោងសរុប១០៤ មិនមានព័ត៌មានពីកាលបរិច្ឆេទចាប់ផ្តើម និងបញ្ចប់របស់ខ្លួនឡើយ។

**រូបភាពទី ៣: ភាគរយនៃកម្ចីសម្បទានតាមម្ចាស់ជំនួយ គិតត្រឹមខែមិថុនា ឆ្នាំ២០១០**




*ប្រភព: ការវិភាគលើ ១០៤គម្រោងដែលបានដកស្រង់ពីមូលដ្ឋានទិន្នន័យជំនួយអភិវឌ្ឍន៍ផ្លូវការនៃក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍន៍កម្ពុជា*

យោងទៅលើរូបភាពទី៣ ខាងលើបង្ហាញថា ធនាគារអភិវឌ្ឍន៍អាស៊ី គឺជាម្ចាស់ជំនួយដ៏ធំបំផុតទីមួយ គឺស្មើនឹង ៣៨,៥% នៃកម្ចីសម្បទានសរុប និងប្រទេសចិនជាម្ចាស់ជំនួយដ៏សំខាន់លំដាប់ទី២ ដែលផ្តល់រហូតដល់ ២៨,៤% ហើយម្ចាស់ជំនួយទាំងពីរនេះផ្តល់កម្ចីសម្បទានសរុបចូលគ្នាជិត ៧០% នៃកម្ចីសម្បទានសរុប ដល់ប្រទេសកម្ពុជាផ្អែកលើទិន្នន័យ ដែលមានធនាគារពិភពលោក និងប្រទេសជប៉ុនផ្តល់កម្ចីសម្បទាននេះស្មើតែប្រហាក់ប្រហែលគ្នាគឺ ១១,៦% និង១០,១%រៀងគ្នា ចំណែកឯសហគមន៍អឺរ៉ុបវិញ ផ្តល់តែ ៣%ប៉ុណ្ណោះ។

## សេចក្តីសន្និដ្ឋាន

ការវិភាគនេះ បានគូសបញ្ជាក់យ៉ាងសំខាន់ចំពោះការគិតពិចារណាទៅលើល័ក្ខខ័ណ្ឌនៃកម្ចីសម្បទានដែលកំពុងតែផ្តល់មកប្រទេសកម្ពុជា។ ប្រទេសជប៉ុន កូរ៉េខាងត្បូង និងសហគមន៍អឺរ៉ុបបានផ្តល់ប្រាក់កម្ចីជាមួយអត្រាការប្រាក់តិចជាង ០,៥%។ អត្រានេះគឺមានកម្រិតប្រហែលមួយភាគបីនៃអត្រាការប្រាក់របស់ធនាគារពិភពលោក (១,២%) និង ធនាគារអភិវឌ្ឍន៍អាស៊ី (១,២៣%) ខណៈដែលប្រទេសចិនយកអត្រាការប្រាក់ខ្ពស់ជាងគេបំផុត (១,៨៦%) ដែលស្ទើរតែស្មើនឹងប្រាំដងខ្ពស់ជាងអត្រាការប្រាក់ដែលផ្តល់ដោយប្រទេសជប៉ុន និងកូរ៉េខាងត្បូង និងស្ទើរតែស្មើនឹងបួនដងខ្ពស់ជាងប្រភពហិរញ្ញប្បទានដែលបានមកពីសហគមន៍អឺរ៉ុប។ នៅក្នុងចំណោមម្ចាស់ជំនួយទាំងអស់ ប្រទេសចិនផ្តល់នូវល័ក្ខខ័ណ្ឌជំនួយដែលមានលក្ខណៈអនុគ្រោះតិចជាងគេបំផុត ដែលយកអត្រាការប្រាក់ ២%ក្នុង១ឆ្នាំលើគម្រោងកម្ចីភាគច្រើនរបស់ខ្លួន។

ទន្ទឹមនឹងនេះ ប្រទេសចិនត្រូវបានគេកត់សម្គាល់ថាផ្តល់រយៈពេលអនុគ្រោះ និងរយៈពេលសងរំលោះខ្លីបំផុត ខណៈដែលសហគមន៍អឺរ៉ុបក៏ឆ្លុះបញ្ចាំងនិន្នាការដូចគ្នាដែរ ប៉ុន្តែអត្រាការប្រាក់របស់សហគមន៍អឺរ៉ុបនៅតែទាបជាងប្រទេសចិន។ ធនាគារអភិវឌ្ឍន៍អាស៊ីក៏ដូចជាប្រទេសជប៉ុនដែរ ផ្តល់រយៈពេលអនុគ្រោះដែលមានលក្ខណៈអនុគ្រោះប្រសើរជាងប្រទេសចិន និងផ្តល់រយៈពេលសងរំលោះក្នុងរយៈពេល៣០ឆ្នាំដូចគ្នាចំពោះគម្រោងភាគច្រើនរបស់ខ្លួន។ ធនាគារពិភពលោកហាក់បីដូចជាមានបទដ្ឋានកំរិតរយៈពេលអនុគ្រោះ១០ឆ្នាំ និងរយៈពេលសងរំលោះ ៤០ឆ្នាំ។

ជារួម គេអាចកត់សម្គាល់បានថា រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តនូវអភិក្រមដ៏ល្អមួយក្នុងការទទួលបានកម្ចីសម្បទានដោយការធ្វើពិពិធភាវូបនីយកម្មប្រភពនៃកម្ចីសម្បទានដើម្បីពិចារណាទៅលើភាពចំរុះនៃម្ចាស់ជំនួយច្រើនប្រភេទដែលសមស្របបំផុតដែលមានអត្រាការប្រាក់ផ្សេងៗគ្នាអាស្រ័យទៅលើទំហំ និងលក្ខណៈរបស់គម្រោង។ វិធីសាស្ត្រនេះអនុញ្ញាត្តិឱ្យរាជរដ្ឋាភិបាលកម្ពុជាធ្វើសេចក្តីសម្រេចចិត្តមួយដែលមានការដឹងលឺពីប្រជាពលរដ្ឋ និងក៏អនុញ្ញាតិឱ្យប្រជាជនកម្ពុជាអាចស្វែងយល់កាន់តែច្បាស់ថាតើម្ចាស់ជំនួយមួយណាដែលផ្តល់កម្ចីសម្បទានដែលមានលក្ខណៈអនុគ្រោះជាងគេដល់កម្ពុជា។ ដោយការសំលឹងមើលទៅខាងមុខ សារៈសំខាន់នៃការវិភាគនិងស្វែងយល់នេះ នឹងជួយឱ្យប្រជាជនកម្ពុជាវាយតម្លៃពីស្ថានភាពបច្ចុប្បន្នថា តើប្រាក់កម្ចីសម្បទានចំនួនប៉ុន្មានដែលប្រទេសកម្ពុជានឹងត្រូវទូទាត់សងត្រឡប់ទៅវិញ ព្រោះថា ពួកគេគឺជាអ្នកបង់ពន្ធ ឬរងបន្ទុកពន្ធចុងក្រោយក្នុងការសងរំលោះបំណុលទាំងនេះ (ព្រោះប្រាក់ពន្ធទាំងនេះនឹងត្រូវប្រើប្រាស់សម្រាប់សងរំលោះបំណុលនាថ្ងៃអនាគត)។ ដូច្នេះ ដោយទទួលស្គាល់នូវបញ្ហាប្រឈម និងភាពស្មុគស្មាញដែលមាន នៅក្នុងការគ្រប់គ្រងប្រព័ន្ធទិន្នន័យជំនួយអភិវឌ្ឍន៍ផ្លូវការ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា សូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ (ឬសហគមន៍ម្ចាស់ជំនួយ) ធ្វើការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានទាំងអស់ដែលមានពាក់ព័ន្ធទៅនឹងល័ក្ខខ័ណ្ឌជំនួយនៃកម្ចីសម្បទានដែលផ្តល់ជូនប្រទេសកម្ពុជាឱ្យកាន់តែសំបូរបែប និងគ្រប់ជ្រុងជ្រោយថែមទៀត ព្រោះតាមរយៈនេះប្រជាជនកម្ពុជានឹងទទួលបានព័ត៌មានច្បាស់លាស់ និងសុក្រឹតអំពីចំណាយពិតប្រាកដនៃជំរើសកម្ចីសម្បទានពាក់ព័ន្ធនឹងម្ចាស់ជំនួយទាំងនេះ។

## ពន្យល់ពាក្យគន្លឹះ

**១-ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ (ODA):** ជាហិរញ្ញប្បទានឥតសំណង ឬជាកម្ចីសម្បទានដែលផ្តល់ដល់ប្រទេសទាំងឡាយដែលមានឈ្មោះនៅក្នុងផ្នែកទី១ នៃបញ្ជីឈ្មោះប្រទេសទទួលជំនួយរបស់គណៈកម្មាធិការជំនួយអភិវឌ្ឍន៍ (ប្រទេសកំពុងអភិវឌ្ឍន៍) និងដែល :

ក-ផ្តល់ឱ្យវិស័យផ្លូវការ ។

ខ-មានគោលដៅចម្បងគឺការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសុខុមាលភាពសង្គម ។

គ-ហិរញ្ញប្បទានមានលក្ខណៈសម្បទាន (ប្រសិនបើជាកម្ចី ត្រូវរួមមានសមាសធាតុឥតសំណងយ៉ាងតិចបំផុតស្មើ ២៥% នៃកម្ចី) ។

ក្រៅពីលំហូរហិរញ្ញប្បទាន កិច្ចសហប្រតិបត្តិការបច្ចេកទេសក៏ត្រូវរាប់បញ្ចូល ជាហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ដែរ ។ ហិរញ្ញប្បទាន ទាំងឥតសំណងនិងកម្ចីសម្រាប់គោលដៅយោធា មិនត្រូវបានរាប់បញ្ចូលជាហិរញ្ញប្បទានសហប្រតិបត្តិការ អភិវឌ្ឍន៍ឡើយ ។

**២-ហិរញ្ញប្បទានឥតសំណង (Grant):** ការផ្ទេរហិរញ្ញប្បទានជាសាច់ប្រាក់ ទំនិញ ឬសេវាកម្ម ដោយពុំមានការទាមទារឱ្យសងវិញឡើយ ។

**៣-កម្ចី , ឥណទាន (Loan/credits):** ជាការផ្តល់ធនធានទាំងឡាយ (ដោយមិនរាប់បញ្ចូលម្ហូបអាហារ និងឧបករណ៍ប្រើប្រាស់ផ្សេងៗ) ក្នុងគោលបំណងជួយសង្គ្រោះ ឬសម្រាប់គោលដៅអភិវឌ្ឍន៍ ដោយរួមបញ្ចូលទាំងកម្មវិធីលទ្ធកម្មដែលត្រូវតែសងវិញទៅតាមល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងកម្ចី ឬតាមការព្រមព្រៀងណាមួយក្រោយទៀត ។

**៤-កម្ចីសម្បទាន (Concessional Loan):** ជាការផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ក្នុងទម្រង់ជាកម្ចីដែលក្នុងនោះ មានហិរញ្ញប្បទានឥតសំណងយ៉ាងតិចស្មើនឹង ២៥% ។ កម្ចីសម្បទានក៏ជាហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការដែរ ។ កម្ចីសម្បទានអាចកំណត់ថាជាកម្ចី "ទន់" ផងដែរ ហើយអត្រាការប្រាក់ទាបជាងទីផ្សារ ។

**៥-រយៈពេលសងរំលោះ (Grace Period):** គឺជារយៈពេលមួយដែលត្រូវសងតែការប្រាក់ប៉ុណ្ណោះ ប៉ុន្តែមិនមានការកំណត់លើការទូទាត់ឡើងវិញនូវប្រាក់ដើមឡើង ។

**៦-រយៈពេលទូទាត់ (Repayment period):** គឺជារយៈពេលដែលកម្ចីត្រូវទូទាត់ ។

**៧-រយៈពេលកាលវសាន្ត (Maturity Period):** គឺបន្សំនៃរយៈពេលសងរំលោះ និងទូទាត់ ។

### ព័ត៌មានទំនាក់ទំនង

**សម្រាប់ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងអត្ថបទនេះ សូមទំនាក់ទំនង:**

**លោក ជា តឹមសុង អ្នកគ្រប់គ្រងកម្មវិធីបញ្ហាអភិវឌ្ឍន៍**
**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**
អាសយដ្ឋាន: អគារលេខ ៩-១១, ផ្លូវ ៤៧៦, សង្កាត់ទួលទំពូង១ ខណ្ឌចំការមន ភ្នំពេញ
ប្រអប់សំបុត្រលេខ ២២៩៥
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១៤ ៤២៩
ទូរសារលេខ: (៨៥៥) ២៣ ៩៩៤ ០៦៣
អ៊ីម៉ែល: ngoforum@ngoforum.org.kh
គេហទំព័រ: www.ngoforum.org.kh

# ផលប៉ះពាល់នៃការធ្លាក់ចុះសេដ្ឋកិច្ចនៅលើគ្រួសារ និងសហគមន៍ និងតម្រូវការចាំបាច់នូវគោលនយោបាយឆ្លើយតប[១]

ការធ្លាក់ចុះសេដ្ឋកិច្ចដែលមានប្រភពនៅសហរដ្ឋអាមេរិកនៅចុងឆ្នាំ២០០៨ បានធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចនៃបណ្ដាប្រទេសនានានៅជុំវិញពិភពលោក។ មូលដ្ឋានសេដ្ឋកិច្ចចំបងរបស់កម្ពុជាបានរង្គោះរង្គើ ដោយសារភាពពឹងផ្អែកជាខ្លាំងលើតម្រូវការទីផ្សារ និងទុនបរទេសដែលមិនអាចឱ្យកម្ពុជាអាចគេចផុតពីការរងផលប៉ះពាល់ពីវិបត្តិនេះឡើយ។ វិស័យសំខាន់ៗដែលរងផល ប៉ះពាល់ពីការធ្លាក់ចុះសេដ្ឋកិច្ចនៅកម្ពុជារួមមាន៖ វិស័យកាត់ដេរ សម្លៀកបំពាក់ វិស័យសំណង់ និងទីផ្សារអចលនទ្រព្យ វិស័យ ទេសចរណ៍ និងវិស័យកសិកម្មសម្រាប់មុខទំនិញមួយចំនួន ដូចជា កៅស៊ូ និងដំឡូងមីជាដើម។ ក្នុងចន្លោះខែកញ្ញា ឆ្នាំ២០០៨ ដល់ ខែឧសភា ឆ្នាំ២០០៩ ការធ្លាក់ចុះនៃការនាំចេញសម្លៀកបំពាក់ស្ដែងឱ្យឃើញតាមរយៈការបញ្ឈប់ការងារកម្មករចំនួន ៦៣.០០០នាក់ ហើយជាមួយគ្នានេះដែរផលប៉ះពាល់លើវិស័យអចលនទ្រព្យ និងសំណង់បានធ្វើឱ្យបាត់បង់ការងារចំនួន ១០០.០០០នាក់ (ឬបីភាគដប់នៃការងារ)។ ការធ្លាក់ចុះនូវការមកដល់នៃភ្ញៀវទេសចរណ៍ និងការធ្លាក់ចុះនៃការចំណាយរបស់ ទេសចរណ៍ធ្វើឱ្យបុគ្គលិកកម្មករជាច្រើននាក់គ្មានការងារធ្វើ និងធ្វើឱ្យសកម្មភាព សេដ្ឋកិច្ចនានាពាក់ព័ន្ធនឹងវិស័យទេសចរណ៍ជួប ការលំបាក ដូចជា ភោជនីយដ្ឋាន សេវាសិប្បកម្ម និងវត្ថុអនុស្សាវរីយ៍ជាដើម។

ក្នុងការពិចារណាអំពីផលប៉ះពាល់អវិជ្ជមានទាំងនេះមកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងដើម្បីបន្ថែមគុណតម្លៃឱ្យបានច្រើនបំផុត ការសិក្សានេះផ្ដោតលើផលប៉ះពាល់នៃការធ្លាក់ចុះសេដ្ឋកិច្ចមកលើមនុស្ស និងគ្រួសារនៅកម្រិតសហគមន៍។ ការសិក្សានេះបានធ្វើអង្កេតលើគ្រួសារចំនួន១.០៧០ និងបានធ្វើកិច្ចសម្ភាសន៍ជាមួយតំណាងក្រុមគោលដៅគឺ ជាមួយស្ត្រី និងអ្នកផ្ដល់ព័ត៌មានសំខាន់ៗនៅក្នុងភូមិចំនួន១៥ នៅទូទាំងប្រទេសកម្ពុជា (ចាប់ពីថ្ងៃទី១៤ ដល់ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩) ដែលក្នុងនោះភូមិចំនួន ១៤ ធ្លាប់ត្រូវបានធ្វើអង្កេតកាលពីមួយឆ្នាំមុនដើម្បីប៉ាន់ប្រមាណអំពីផលប៉ះពាល់នៃការ កើនឡើងខ្ពស់នៃថ្លៃស្បៀងអាហារ (ខែមិថុនា ឆ្នាំ២០០៨)។ ភូមិថ្មីមួយគឺជាភូមិទី ១៥ ដែលមានទីតាំងនៅ ខេត្តសៀមរាបត្រូវបានបន្ថែមដើម្បីពិនិត្យមើលផលប៉ះពាល់មកលើភូមិដែលពឹងផ្អែកលើវិស័យទេសចរណ៍។ អាស្រ័យហេតុ នេះ យើងបានប្រើប្រាស់អង្កេតឆ្នាំ២០០៨ ជាមូលដ្ឋានដើម្បីពិនិត្យមើលការប្រែប្រួលចាប់ពីពេលនោះមក។ ការសិក្សានេះ បានពិនិត្យមើល ការប្រែប្រួលចំពោះ ទ្រព្យសម្បត្តិ ប្រាក់ចំណូល ប្រភពប្រាក់ចំណូលរបស់គ្រួសារ និងការលំបាកនានាដែល គ្រួសារបានជួបប្រទះ និងពិនិត្យមើលការឆ្លើយតប ឬយុទ្ធសាស្ត្រសម្របខ្លួនជាមួយវិបត្តិដែលគ្រួសារនានាបានប្រកាន់យក ដើម្បីទប់ទល់នឹងជីវភាពប្រចាំថ្ងៃរបស់ពួកគាត់។

ភស្តុតាងពីការអង្កេតគ្រួសារនៅខែកក្កដា ឆ្នាំ២០០៩ បានបង្ហាញថាការធ្លាក់ចុះសេដ្ឋកិច្ចបានធ្វើឱ្យមានផលប៉ះពាល់យ៉ាងច្រើនមកលើគ្រួសារ និងប្រជាពលរដ្ឋនៅតាមសហគមន៍ ពិសេសគឺនៅតាមតំបន់ក្រីក្រតាមទីប្រជុំជន ក៏ដូចជាភូមិឋាននានាដែលពឹងផ្អែកលើវិស័យទេសចរណ៍ និងភូមិឋានដែលផលិតកសិផលដើម្បីលក់។ គេឃើញផលប៉ះពាល់ជាក់ច្បាស់ តាមរយៈការបាត់បង់ការងារ ការកាត់បន្ថយប្រាក់បញ្ញើទៅកាន់ក្រុមគ្រួសារ ការធ្លាក់ចុះនូវប្រាក់ចំណូល និងការធ្លាក់ចុះនៃថ្លៃ ទំនិញកសិកម្ម ដូចជាស្រូវវស្សា ពោត និងដំឡូងមីជាដើម។

## ផលលំបាកដែលគ្រួសារតាមសហគមន៍បានជួបប្រទះក្នុងអំឡុងពេលនៃការធ្លាក់ចុះសេដ្ឋកិច្ច

ជារួម ៨៩ ភាគរយនៃគ្រួសារដែលបានធ្វើអង្កេត បានប្រឈមមុខនឹងការលំបាកកាលពីប្រាំមួយខែមុន ហើយនៅតែប្រឈមមុខខ្លាំងធៀបនឹងឆ្នាំ២០០៨ ពេលដែលអតិផរណាមានកំរិតខ្ពស់ក្នុងឆ្នាំនោះ។ ទោះជាយ៉ាងណាក្ដី ប្រភេទនៃការលំបាក

[១] អត្ថបទនេះដកស្រង់ពីរបាយការណ៍ស្ដីពី "ផលប៉ះពាល់នៃការធ្លាក់ចុះសេដ្ឋកិច្ចលើគ្រួសារ និងសហគមន៍នៅកម្ពុជា" ដែលត្រូវបានអង្កេតដោយ សមាគមសេដ្ឋកិច្ច កម្ពុជា កាលពីខែកក្កដា ឆ្នាំ២០០៩ សហការក្នុងភាពជាដៃគូជាមួយអង្គការអុកស្វាម និងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្ដីពីកម្ពុជា។

ដែលគ្រួសារនានាបានជួបប្រទះមានការប្រែប្រួល ហើយមានចំនួនគ្រួសារកាន់តែច្រើនឡើងនៅក្នុងតំបន់ក្រីក្រ និងភូមិឋានដែលផលិតកសិផលដើម្បីលក់បានរងនូវការលំបាក។ នៅឆ្នាំ២០០៨ ថ្លៃទំនិញឡើងខ្ពស់គឺជាការលំបាក ចំបងសម្រាប់គ្រួសារ ហើយស្ទើរតែគ្មានគ្រួសារណាមួយនៃគ្រួសារដែលបានធ្វើអង្កេតបានបាត់បង់ការងារ ឬរកប្រាក់ចំណូល បានតិចជាងមុនឡើយ។ នៅពេលដែលការចំណាយលើការឃើថ្លាត់ ឬចំណាយលើសុខភាពដែលធ្លាប់ជាការលំបាកចំបង ចំពោះគ្រួសារ នៅឆ្នាំ២០០៨ បញ្ហានេះនៅតែបន្តប៉ះពាល់ដល់គ្រួសារក្នុងឆ្នាំ២០០៩ ដែលការបាត់បង់ការងារ ឬការធ្លាក់ ចុះនូវប្រាក់ចំណូល និងអសមត្ថភាពក្នុងការសងបំណុល គឺជាការលំបាកពីរធំបំផុតដែលបណ្តាលមកពីការធ្លាក់ចុះសេដ្ឋកិច្ច។ ភាគរយនៃគ្រួសារដែលមានប្រាក់ ចំណូលធ្លាក់ចុះមានកម្រិតខ្ពស់បំផុតនៅតំបន់ក្រីក្រតាមទីប្រជុំជន (៦១%) និងភូមិ ពឹងផ្អែកលើវិស័យទេសចរណ៍ (៥០%) ខណៈដែលភាគរយនៃគ្រួសារដែលរាយការណ៍អំពីការលំបាក ក្នុងការសងបំណុល មានកម្រិតខ្ពស់បំផុតនៅភូមិដែលផលិតកសិផលដើម្បីលក់ (២១%)។

អង្កេតនេះបានរកឃើញថា គ្រួសារបានរងផលប៉ះពាល់តាមរយៈសមាជិកគ្រួសាររបស់ខ្លួនបានបាត់បង់ការងារ ឬការងាររបស់ពួកគេបានរងផលប៉ះពាល់ដោយសារការធ្លាក់ចុះនៃសេដ្ឋកិច្ច។ ក្នុងចំណោមគ្រួសារដែលបានអង្កេតទាំងនោះ ៣៣% បានរាយការណ៍ថាការងាររបស់សមាជិកគ្រួសារបានរងផលប៉ះពាល់ ហើយសមាជិកគ្រួសារចំនួន ៣,៧% បានបាត់បង់ការងារកាលពី៩ខែមុន។ ការងាររបស់គ្រួសារនៅតំបន់ក្រីក្រតាមទីប្រជុំជន (៧៧%) និងគ្រួសារដែលពឹងផ្អែកលើវិស័យទេសចរណ៍ (៦៩%) បានរង ផលប៉ះពាល់ខ្លាំងបំផុត ខណៈដែលគ្រួសារ ៩% ក្នុងចំណោមគ្រួសារក្រីក្របំផុតនៅតាមបណ្តាភូមិក្រីក្របំផុតនៅជនបទ និងតំបន់ ក្រីក្រតាមទីប្រជុំជនបានបាត់បង់ការងារច្រើនជាងគេបំផុត។

កសិករដាំពោត និងដាំដំឡូងមី រងផលប៉ះពាល់ខ្លាំងដោយសារការធ្លាក់ចុះនូវប្រាក់ចំណេញ។ ទោះបីជា កសិករទាំងនេះនៅតែអាចរកប្រាក់ចំណេញបានពីការដាំដំណាំកសិផលក្តី ក៏ប្រាក់ចំណេញទាំងនោះមានចំនួនតិចជាង ប្រាក់ចំណេញដែលពួកគេរកបានកាលពីឆ្នាំមុន(២០០៨)។ ប្រាក់ចំណេញពីការដាំពោតក្នុងមួយហិកតាមានចំនួន ៣៨៤ ដុល្លារ ក្នុងឆ្នាំ២០០៩ ដែល ៥៦%តិចជាងឆ្នាំ២០០៨ ខណៈដែលប្រាក់ចំណេញពីការដាំដំឡូងមីបានធ្លាក់ចុះ ១០៦ ដុល្លារ (៣៦%)ក្នុងមួយហិកតា។ ប្រាក់ចំណេញចំពោះកសិករធ្វើស្រែវស្សាក៏ធ្លាក់ចុះ ៦៨ ដុល្លារ (៣២%)ផងដែរ។ មានតែ កសិករធ្វើស្រែប្រាំងប៉ុណ្ណោះដែលអាចបង្កើនប្រាក់ចំណេញរបស់ខ្លួនធៀបនឹងឆ្នាំ ២០០៨។

គ្រួសារភាគច្រើនបានរាយការណ៍ថា ប្រាក់ចំណូលដែលពួកគេបានទទួលពីប្រភពផ្សេងៗបានធ្លាក់ចុះធៀបនឹងឆ្នាំមុន ពិសេសគឺប្រាក់ចំណូលពីផ្អែកកាត់ដេរសម្លៀកបំពាក់ ការងារសំណង់ ការធ្វើអាជីវកម្មដោយខ្លួនឯង និងពីការលក់សិប្បកម្ម ឬ វត្ថុអនុស្សាវរីយ៍ចំពោះភូមិដែលពឹងផ្អែកលើវិស័យទេសចរណ៍។ គេឃើញគ្រួសារតិចតួចដែលរកបានប្រាក់ចំណូលតិចតួច ពីការលក់ស្រូវ បន្លែ និងលក់បសុសត្វ មានន័យថាផលប៉ះពាល់មកលើប្រាក់ចំណូលគ្រួសារពីប្រភពទាំងនេះ មិនសូវធ្ងន់ធ្ងរ ដូចជាភូមិធ្វើស្រែ វស្សាស្រែប្រាំង និងភូមិដែលមានដីធ្លីច្រើនឡើយ។ ចំពោះភូមិនេសាទវិញ គ្រួសារចំនួន ៧៤% បានរាយការណ៍ថាប្រាក់ចំណូលរបស់ពួកគេពីការនេសាទបានធ្លាក់ចុះធៀបនឹងឆ្នាំមុន។ ទោះជាយ៉ាងណាក្តី ការធ្លាក់ចុះនៃប្រាក់ចំណូលនោះបណ្តាលមកពីការធ្លាក់ចុះនូវផលនេសាទដែលគ្រួសារអាចរកបានពីសកម្មភាពនេសាទរបស់ខ្លួន។

គ្រួសារមួយចំនួនមានលទ្ធភាពរក្សាប្រាក់ចំណូលពីប្រាក់ឈ្នួល និងប្រាក់បញ្ញើពីបរទេស។ ប្រាក់ចំណូលពីការលក់ពលកម្ម និងប្រាក់បញ្ញើពីបរទេសគ្មានការប្រែប្រួលឡើយ ប៉ុន្តែគ្រួសារបានទទួលប្រាក់ចំណូលតិចជាងមុន ពីប្រាក់បញ្ញើក្នុងស្រុក។ នៅពេលដែលអតិផរណាមានកម្រិតខ្ពស់នៅឆ្នាំ២០០៨ (២២.៣%[២]) ពលរដ្ឋក្រីក្ររកបានប្រាក់ចំណូលច្រើនជាងមុនពីការលក់ពលកម្ម (របរស៊ីឈ្នួល) ព្រោះថាប្រាក់ឈ្នួលបានកើនឡើងប្រហែល៥០% ធៀបនឹងឆ្នាំ២០០៧។ ចាប់ពីឆ្នាំ ២០០៨ ដល់ឆ្នាំ២០០៩មក ប្រាក់ឈ្នួល ស៊ឹងតែគ្មានការប្រែប្រួលឡើយ។ ពលករដែលធ្វើការងារប្រចាំថ្ងៃនៅតែបានទទួលប្រាក់ឈ្នួលដដែល ដូចដែលពួកគេបានទទួលពីឆ្នាំមុន លើកលែងតែការងារកសិកម្ម។ ក្នុងនោះប្រាក់ឈ្នួលចំពោះការធ្វើស្មៅទំនងជាធ្លាក់ចុះ ១៧% ធៀបនឹងឆ្នាំ២០០៨។

[២] វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។

## យុទ្ធសាស្ត្រសម្របខ្លួនរបស់គ្រួសារ

សភាពតានតឹងដោយសារការបាត់បង់ប្រាក់ចំណូលបានធ្វើឱ្យគ្រួសារបាត់បង់លទ្ធភាពក្នុងការសងបំណុល កាត់បន្ថយការចំណាយលើការថែទាំសុខភាព និងលើមុខចំណាយមិនមែនស្បៀង ព្រមទាំងកាត់បន្ថយការបរិភោគម្ហូបអាហារ (បរិភោគតិចជាងមុន ឬទិញម្ហូបអាហារដែលមិននិយមបរិភោគ ឬម្ហូបអាហារថោកៗ) ដែលបន្តគម្រាមកំហែងដល់ស្ថានភាព អាហារូបត្ថម្ភដែលកំពុងខ្វះខាត ដែលបានរងផលប៉ះពាល់ដោយការឡើងថ្លៃស្បៀងអាហារខ្ពស់កាលពីឆ្នាំមុន។ ស្ត្រីទទួលទាន អាហារតិច និងមិនសមាមាត្រជាមួយសមាជិកគ្រួសារដទៃទៀតឡើយ ដោយសារពួកគេបានចែករំលែកចំណែករបស់ខ្លួនឱ្យប្តី និងកូនៗពួកគេ។ ក្រៅពីការស្វែងរកការងារបន្ថែម ឬការងារដទៃ និងបានបង្កើនចំនួនសមាជិកគ្រួសារធ្វើចំណាកស្រុក ទៅរកការងារធ្វើ គ្រួសារបានសម្របខ្លួនជាមួយការចិញ្ចឹមជីវិតលំបាកលំបិនរបស់ពួកគេដោយការប្រមូលទ្រព្យសម្បត្តិលក់ និងដោយការខ្ចីបុល។ ការបញ្ឈប់កូនលែងឱ្យទៅរៀន ត្រូវបានរកឃើញថាមិនមានច្រើនករណីទេ ដែលសឱ្យឃើញថា ផលប៉ះពាល់មកលើការអប់រំមិនទាន់មកដល់នៅឡើយទេ ទោះបីជាករណីនេះអាចត្រូវបានបកស្រាយថាការចំណាយ ក្រៅផ្លូវការនៅសាលារៀន មិនមែនជាបញ្ហាដែលកើតមានជាទូទៅនៅតាមបណ្តាភូមិដែលបានធ្វើអង្កេតក្តី ឬក៏របកគំហើញពុំ មានលក្ខណៈតំណាងដោយសារដែនកំណត់នៃអង្កេតដែលបានប្រព្រឹត្តទៅនៅឆមាសទីពីរ(ខែកក្កដា) នៃឆ្នាំ២០០៩ ដែលជា ចុងឆ្នាំសិក្សា។

**តារាងទី១: ភាគរយនៃគ្រួសារដែលអនុវត្តយុទ្ធសាស្ត្រសម្របខ្លួនទៅនឹងផលប៉ះពាល់នៃវិបត្តិនៅឆ្នាំ២០០៨ និង ២០០៩**

| ល.រ | យុទ្ធសាស្ត្រសម្របខ្លួនដែលគ្រួសារបានអនុវត្តកាលពី៣ខែកន្លងទៅ | មិថុនា ២០០៨ | កក្កដា ២០០៩ | បំរែបំរួល ២០០៩/២០០៨ |
|---|---|---|---|---|
| | **យុទ្ធសាស្ត្រទាក់ទងនឹងការចំណាយលើម្ហូបអាហារ** | | | |
| ១ | បរិភោគអាហារដែលមិននិយមចូលចិត្តឬអាហារថោក | ៦២.៨ | ៧៥.៦ | ១២.៨ |
| ២ | កាត់បន្ថយរបបអាហារប្រចាំថ្ងៃ | ៤៤.១ | ៥១.៨ | ៧.៧ |
| ៣ | បន្ថយរបបទទួលទានចំពោះមនុស្សធំដើម្បីទុករបបខ្លះឱ្យក្មេងៗ | ៣៧.៤ | ៣២.០ | -៥.៥ |
| ៤ | ម្តាយឬបងស្រីកាត់បន្ថយការបរិភោគរបស់ខ្លួន ដើម្បីទុកម្ហូបអាហារខ្លះឱ្យសមាជិកគ្រួសារដទៃបរិភោគ | ៣២.១ | ៣៨.៦ | ៦.៥ |
| | **យុទ្ធសាស្ត្រទាក់ទងនឹងបំណុល** | | | |
| ៥ | ខ្ចីបុលស្បៀងអាហារ ឬពឹងផ្អែកលើការជួយជ្រោមជ្រែងពីមិត្តភក្តិ ឬពីសាច់ញាតិ | ៣៩.៧ | ៤២.៧ | ៣.១ |
| ៦ | ទិញស្បៀងអាហារជឿ | ៥៧.៥ | ៦៦.២ | ៨.៧ |
| ៧ | ខ្ចីលុយគេ | - | ៦៨.០ | ០ |
| | **សកម្មភាពរកប្រាក់ចំណូល** | | | |
| ៨ | រកការងារផ្សេងទៀត ឬការងារបន្ថែមដើម្បីធ្វើ | ៣០.១ | ៣៧.០ | ៦.៩ |
| ៩ | បញ្ជូនសមាជិកគ្រួសារបន្ថែមធ្វើចំណាកស្រុកទៅរកការងារធ្វើ | ៧.១ | ១៤.២ | ៧.១ |
| ១០ | បង្កើនសកម្មភាពនេសាទត្រី | ១៧.៣ | ១៩.៧ | ២.៥ |
| ១១ | បង្កើនសកម្មភាពរានព្រៃ | | ៦.២ | ៦.២ |
| | **ទ្រព្យសម្បត្តិរបស់គ្រួសារ** | | | |
| ១២ | លក់ទ្រព្យសម្បត្តិក្នុងផ្ទះ ដូចជា សង្ហារឹម ជាដើម | ០.៨ | ៣.៨ | ៣.០ |
| ១៣ | លក់មធ្យោបាយផលិតកម្ម ដូចជា ឧបករណ៍កសិកម្ម ម៉ាស៊ីនដេរ ម៉ូតូជាដើម | ០.៦ | ៣.២ | ២.៦ |

| | | | | |
|---|---|---|---|---|
| ១៤ | លក់ដី | ១.៣ | ១.៨ | ០.៥ |
| ១៥ | លក់គ្រឿងអលង្ការ | ៣.៣ | ១១.២ | ៧.៩ |
| | **ផ្សេងៗ** | | | |
| ១៦ | បរិភោគគ្រាប់ពូជដែលរក្សាទុកសម្រាប់ដាំដុះនៅរដូវខាងមុខ | ៤.១ | ៩.១ | ៤.៩ |
| ១៧ | កាត់បន្ថយចំណាយលើជី ថ្នាំសម្លាប់សត្វល្អិត ចំណីសត្វ ។ល។ | ៥.០ | ៦.៥ | ១.៥ |
| ១៨ | កាត់បន្ថយចំណាយលើការថែទាំសុខភាព | ១៨.៩ | ៣៤.៦ | ១៥.៧ |

*ប្រភព: អង្កេត ១០៧០គ្រួសារដោយសមាគមសេដ្ឋកិច្ចកម្ពុជានៅភូមិគោលដៅចំនួន ១៥ (កក្កដា ២០០៩)និងអង្កេត ៩៩១ គ្រួសារដោយ វបសអ នៅភូមិ គោលដៅចំនួន ១៤ (មិថុនា ២០០៨)*

គ្រួសារជាច្រើនមានសមាជិកធ្វើចំណាកស្រុក (២៤%នៃចំនួនគ្រួសារដែលបានធ្វើអង្កេតមានសមាជិកគ្រួសារ ធ្វើចំណាកស្រុកជាចំនួនមួយដែលកើនឡើងពី ១៥% កាលពីឆ្នាំ២០០៨)។ ចំណាកស្រុកបានកើនឡើងនៅបណ្តាភូមិដទៃទៀត លើកលែងតែបណ្តាភូមិដែលធ្វើស្រែប្រាំង។ ទោះជាយ៉ាងណាក៏ដោយ កំណើនចំណាកស្រុកនៅតាមបណ្តាភូមិ ដែលមានដីធ្លីច្រើនភាគច្រើនគឺបណ្តាលមកពីការអូសបន្លាយនៃគ្រោះរាំងស្ងួត ហើយម្យ៉ាងវិញទៀតគឺ ដោយសារតែមានឱកាសការងារនៅតាមតំបន់ដីសម្បទានសេដ្ឋកិច្ចនៅបណ្តាខេត្តជិតខាង។ ទោះជាយ៉ាងណាក្តី មានការរាយការណ៍ថា ៦២% នៃចំណាកស្រុក គឺជាយន្តការសម្របខ្លួនដើម្បីដោះស្រាយចំពោះការធ្លាក់ចុះនូវប្រាក់ចំណូលគ្រួសារ ហើយនៅឆ្នាំ២០០៨ អ្នកផ្តល់ចម្លើយចំនួន ៣៣% បានប្រាប់ឱ្យដឹងថាចំណាកស្រុក គឺជាមធ្យោបាយមួយដើម្បីទប់ទល់ជាមួយការលំបាកចំពោះ ការចិញ្ចឹមជីវិត។ គោលដៅចំបងៗនៃចំណាកស្រុកនៅតែជាតំបន់ទីប្រជុំជន និងតំបន់ជនបទនៅកម្ពុជា គឺមិនមានការ ប្រែប្រួលឡើយធៀបនឹងឆ្នាំ២០០៨។ ទោះជាយ៉ាងណាក្តី សមាមាត្រនៃចំណាកស្រុកទៅកាន់តំបន់ជនបទ នៅកម្ពុជានៅតែ គ្មានការប្រែប្រួល ហើយគេឃើញចំណាកស្រុកមកកាន់តំបន់ទីប្រជុំជនធ្លាក់ចុះខណៈពេលដែលចំណាកស្រុកទៅកាន់តំបន់ជនបទប្រទេសថៃបានកើនឡើងទ្វេដង។ អ្វីដែលគួរឱ្យកត់សម្គាល់ គឺថាចំណាកស្រុកជាមធ្យោបាយពេញនិយមសម្រាប់គ្រួសារក្រីក្រ។

**រូបភាព ១: គោលដៅនៃចំណាកស្រុក ( %នៃគ្រួសារដែលមានសមាជិកធ្វើចំណាកស្រុក)**




*ប្រភព: អង្កេត ១០៧០គ្រួសារដោយសមាគមសេដ្ឋកិច្ចកម្ពុជានៅភូមិគោលដៅចំនួន ១៥ (កក្កដា ២០០៩)និងអង្កេត ៩៩១ គ្រួសារដោយ វបសអ នៅភូមិគោលដៅចំនួន ១៤ (មិថុនា ២០០៨)*

អត្រាភាគរយនៃគ្រួសារដែលខ្ចីបុលគេបានកើនឡើង ហើយអសមត្ថភាពរបស់គ្រួសារក្នុងការសងបំណុលកាន់តែមានសភាពធ្ងន់ធ្ងរ។ ក្នុងចំណោមគ្រួសារដែលបានអង្កេតទាំងអស់មានគ្រួសារ ៧១% ដែលបានខ្ចីបុលគេ ជាចំនួនមួយ ដែលកើនឡើងធៀបនឹង៦២%ឆ្នាំមុន។ ក្នុងចំនួនប្រាក់កម្ចីដែលបានខ្ចីសរុបនេះ ៧០% ជាប្រាក់ដែលគេបានខ្ចីក្នុងចន្លោះ ខែមករា និងខែកក្កដា ឆ្នាំ២០០៩។ សមាមាត្រខ្ពស់បំផុតគឺនៅភូមិនេសាទ(៩១%) បន្ទាប់មកគឺនៅតាមបណ្ដាភូមិ ដែលមាន ដីច្រើន(៧៩%) និងភូមិដាំដំណាំកសិកម្ម និងជាភូមិក្រីក្របំផុតនៅជនបទ(៧២%)។ ទោះជាយ៉ាងណាក្ដី កំណើនមាន កម្រិតខ្ពស់បំផុតនៅភូមិដាំដំណាំកសិកម្ម (កើន ២៥% ធៀបនឹងឆ្នាំ២០០៨) បន្ទាប់មកគឺបណ្ដាភូមិនៅតាមតំបន់ក្រីក្រ ក្នុងទីប្រជុំជន (១៥% ខ្ពស់ជាងឆ្នាំ២០០៨) ហើយអត្រាខ្ពស់បំផុតនៃគ្រួសារដែលបានអង្កេតបានរាយការណ៍នូវប្រការ ដែលគួរឱ្យព្រួយបារម្ភ អំពីបញ្ហាប្រឈមចំបង គឺការសងបំណុលនៅភូមិដាំដំណាំកសិកម្ម (២១%) បន្ទាប់មកគឺភូមិនេសាទ (១៩%) និងភូមិដែលមានដីច្រើន(១៥%)។

សមាមាត្រខ្ពស់នៃប្រាក់កម្ចីដែលបានកើតឡើង គឺត្រូវបានយកទៅប្រើប្រាស់សម្រាប់គោលដៅដែលមិនមាន ផលិតភាព ហើយក្នុងចំណោមប្រាក់កម្ចីទាំងអស់នោះមានតែប្រាក់កម្ចីចំនួន ៣៤% ប៉ុណ្ណោះដែលត្រូវបានរាយការណ៍ ថាបានជួយឱ្យគ្រួសារបានធូរធារ។ ក្នុងចំណោមប្រាក់កម្ចីសរុប ៥២%ត្រូវបានរាយការណ៍ថា ខ្ចីដើម្បីយកទៅពង្រីកអាជីវកម្ម និងយកទៅធ្វើផលិតកម្មកសិកម្ម ខណៈដែលកសិកម្មរបស់ពួកគេមួយផ្នែកធំពឹងផ្អែកលើកត្តាធម្មជាតិ។ សមាមាត្រខ្ពស់បំផុតនៃគ្រួសារដែលបានខ្ចីបុលដើម្បីផលិតកម្មកសិកម្ម គឺក្នុងភូមិដាំដំណាំកសិផលដើម្បីលក់(៥០%) និងដើម្បីពង្រីកអាជីវកម្មមាននៅក្នុងភូមិនេសាទ(៧៩%)។ ចំណែកប្រាក់កម្ចី ៤៨%ទៀត ភាគច្រើនត្រូវបានប្រើប្រាស់សម្រាប់ទិញស្បៀងអាហារ ចំណាយផ្នែកសុខភាព សងបំណុល និងសង់ផ្ទះ។ ការខ្ចីប្រាក់ដើម្បីចំណាយលើម្ហូបអាហារ និងចំណាយផ្នែកសុខភាព មានចំណែកធំជាងគេបំផុតចំពោះភូមិក្រីក្របំផុតនៅជនបទ ភូមិក្រីក្រនៅតាមទីប្រជុំជន និងនៅតាមភូមិនេសាទ។

## វិសាលភាពនៃការទទួលបានជំនួយពីខាងក្រៅ

ទោះបីជាមានបញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុក្ដី មានគ្រួសារតិចជាងមុនដែលបានរាយការណ៍ថាបានទទួលប្រាក់ឧបត្ថម្ភពីប្រភពខាងក្រៅដូចជាពីរាជរដ្ឋាភិបាលអង្គការមិនមែនរដ្ឋាភិបាល ប៉ុន្តែការផ្ដល់ជំនួយឧបត្ថម្ភត្រូវបានផ្ដល់ចំគោលដៅជាងមុន។ មានគ្រួសារដែលបានអង្កេតត្រឹមតែ ៣០% ប៉ុណ្ណោះដែលបានទទួលជំនួយឧបត្ថម្ភកាលពីប្រាំមួយ ខែមុនដែល កាលពីឆ្នាំមុនមានចំនួន ៤៨%។ គេឃើញការផ្ដល់ជមនួយ ឧបត្ថម្ភបានប្ដូរទិស។ ការធ្លាក់ចុះនៃចំនួនគ្រួសារដែលបានទទួលជំនួយនៅភូមិធ្វើស្រែវស្សា និងនៅភូមិដាំដំណាំលក់ តំណាងឱ្យ ការកើនឡើងនូវចំនួនគ្រួសារដែលទទួលជំនួយនៅ បណ្ដាភូមិដែលមានដីច្រើន។ ជាក់ស្ដែង ភាគរយនៃចំនួនគ្រួសារដែលពឹងផ្អែកលើជំនួយឧបត្ថម្ភនៅតាមភូមិក្រីក្របំផុត នៅជនបទនៅតែមានចំនួនខ្ពស់បំផុត(៧៣%) ហើយគ្មានការប្រែប្រួលឡើយធៀបជាមួយឆ្នាំមុន។ ជាមួយគ្នានេះផងដែរ សមាមាត្រគ្រួសារនៅតំបន់ក្រីក្រនៅទីប្រជុំជន និងនៅតាមភូមិនេសាទដែលបានទទួលជំនួយឧបត្ថម្ភនៅឆ្នាំ២០០៩ មានសណ្ឋានដូចគ្នាទៅនឹងស្ថានភាពនៅឆ្នាំ២០០៨ដែរ ប៉ុន្តែមានគ្រួសារកាន់តែច្រើនដែលបានទទួលជំនួយឧបត្ថម្ភនៅភូមិធ្វើស្រែប្រាំង ទោះជាភូមិទាំងនោះមិនសូវរងផលប៉ះពាល់ពីការធ្លាក់ចុះសេដ្ឋកិច្ចក្ដី។

**រូបភាពទី ២៖ ភាគរយនៃគ្រួសារដែលជួបការលំបាក និងបានទទួលជំនួយឧបត្ថម្ភក្នុងរយៈពេលប្រាំមួយខែកន្លងទៅ (ខែកុម្ភៈ ដល់ខែកក្កដា ឆ្នាំ២០០៩)**




*ប្រភព៖ អង្កេត ១០៧០គ្រួសារដោយសមាគមសេដ្ឋកិច្ចកម្ពុជានៅភូមិគោលដៅចំនួន ១៥ (កក្កដា ២០០៩)*

ក្នុងចំណោមគ្រួសារដែលបានទទួលជំនួយឧបត្ថម្ភទម្រង់នៃការឧបត្ថម្ភជាទូទៅក្នុងរយៈពេលប្រាំមួយខែមុន គឺការទទួលបានសេវាថែទាំសុខភាពដោយឥតគិតថ្លៃ(៣៦%) អាហារនៅសាលារៀន(២៦%) មីក្រូឥណទាន(១៤%) និង ស្បៀងពលកម្ម (១០%)។ ជំនួយឧបត្ថម្ភពីរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលច្រើនតែបំពេញឱ្យគ្នាទៅវិញទៅមក។ ឧទាហរណ៍ នៅពេលដែលអង្គការមិនមែនរដ្ឋាភិបាលផ្តល់អាហារនៅតាមសាលារៀន និងស្បៀងពលកម្មចំពោះភូមិក្រីក្របំផុតនៅជនបទ ជំនួយឧបត្ថម្ភពីរាជរដ្ឋាភិបាលត្រូវបានផ្តល់តាមរយៈសេវាថែទាំសុខភាពដោយឥតគិតថ្លៃ ហើយនៅពេលដែលជំនួយឧបត្ថម្ភរបស់រាជរដ្ឋាភិបាលមានតិចតួចចំពោះភូមិក្រីក្រនៅទីប្រជុំជន អង្គការមិនមែនរដ្ឋាភិបាល ផ្តល់សេវាថែទាំ សុខភាពដោយឥតគិតថ្លៃនៅក្នុងសហគមន៍ទាំងនេះ។ ជាងនេះទៀតនោះ ទោះបីជាបានទទួលជំនួយឧបត្ថម្ភទាំងនេះក្តី គ្រួសារនៅតែបញ្ជាក់ឱ្យដឹងនូវក្តីប្រាថ្នាយ៉ាងជ្រាលជ្រៅរបស់ពួកគេក្នុងការទទួលបានជំនួយឧបត្ថម្ភ ដូចជាការថែទាំសុខភាព មីក្រូឥណទាន ការចែកស្បៀង និងចំណីសត្វ ឬការចិញ្ចឹមសត្វ។ ប្រភេទជំនួយឧបត្ថម្ភដទៃទៀតដែលពួកគេចង់បានគឺ ជី (សម្រាប់ភូមិធ្វើស្រែវស្សា) កត្តាផលិតកម្មកសិកម្ម និងជំនាញ (សម្រាប់ភូមិធ្វើស្រែវស្សា និងភូមិធ្វើស្រែប្រាំង) និងឧបករណ៍នេសាទ និងដីធ្លី (សម្រាប់ភូមិនេសាទ)។

អង្កេតគ្រួសារចំពោះភូមិចំនួន ១៥ (កក្កដា ២០០៩)បានឱ្យដឹងថាការធ្លាក់ចុះសេដ្ឋកិច្ចបានធ្វើឱ្យមានផលប៉ះពាល់ជាខ្លាំងមកលើប្រជាជន និងគ្រួសារនៅតាមសហគមន៍។ សហគមន៍ដែលរងផលប៉ះពាល់ខ្លាំងជាងគេពីការធ្លាក់ចុះសេដ្ឋកិច្ច រួមមានបណ្តាភូមិដែលដាំដំណាំលក់ ភូមិស្ថិតនៅតំបន់ក្រីក្រនៅទីប្រជុំជន និងភូមិដែលពឹងផ្អែកលើវិស័យទេសចរណ៍ ព្រោះថាប្រភពប្រាក់ចំណូលចំបងនៃគ្រួសារនានានៅតាមភូមិទាំងនោះប្រឈមមុខជាមួយនឹងតម្រូវការនិងទីផ្សារពីខាងក្រៅ។ នៅក្នុងសហគមន៍ទាំងនេះ គេឃើញផលប៉ះពាល់បានធ្វើឱ្យធ្លាក់ចុះប្រាក់ចំណូល ដោយសារការធ្លាក់ចុះនូវប្រាក់ចំណេញពីដំណាំកសិផលដែលបណ្តាលមកពីការធ្លាក់ថ្លៃ ក៏ដូចជាការថយចុះការងារនៅក្នុងវិស័យកាត់ដេរ សំណង់ សិប្បកម្ម និងអាជីវកម្មដោយខ្លួនឯង ដែលទាំងអស់នេះសុទ្ធតែរងផលប៉ះពាល់ និងធ្វើឱ្យបាត់បង់ការងារ។ នៅតាមភូមិក្រីក្រនៅទីប្រជុំជន ២៥% និង ២៧%នៃគ្រួសារដែលបានអង្កេតពឹងផ្អែក លើការងារនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និងវិស័យសំណង់រៀងៗខ្លួន ខណៈដែល ៦៨%ចិញ្ចឹមជីវិតពីការធ្វើអាជីវកម្មដោយខ្លួនឯង ដូចជារត់ម៉ូតូឌុបជាដើម។ នៅក្នុងភូមិដែលពឹងផ្អែកលើវិស័យទេសចរណ៍វិញ គ្រួសារ ៦៥%ពឹងអាស្រ័យលើអាជីវកម្មដោយខ្លួនឯង ៣៨%ប្រកបរបរចិញ្ចឹមជីវិតដោយលក់វត្ថុសិប្បកម្ម ឬវត្ថុអនុស្សាវរីយ៍ ហើយ ២០% ទៀតចិញ្ចឹមជីវិតដោយការធ្វើជាពលករ។

សហគមន៍ដទៃទៀតដែលរងផលប៉ះពាល់ជាខ្លាំងដោយសារការធ្លាក់ចុះសេដ្ឋកិច្ចដែរនោះគឺ បណ្ដាភូមិក្រីក្របំផុតនៅជនបទ និងភូមិដែលមានដីច្រើន។ គេឃើញមានចំនួនគ្រួសារកាន់តែច្រើននៅក្នុងសហគមន៍ទាំងនេះ ពឹងផ្អែកលើការងារនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និងប្រាក់បញ្ញើក្នុងស្រុក ព្រមទាំងផលិតផលព្រៃឈើ។ ទោះបីជានៅភូមិធ្វើស្រែប្រាំង និងភូមិធ្វើស្រែវស្សា ក៏រងផលប៉ះពាល់ដោយសារការពឹងផ្អែករបស់ពួកគេលើប្រភពប្រាក់ចំណូលនានា ដូចជា ប្រាក់ចំណូលពីវិស័យកាត់ដេរ សំណង់ និងពីអាជីវកម្មផ្ទាល់ខ្លួនក្ដី ពួកគេទំនងជាមិនសូវរងផលប៉ះពាល់ធ្ងន់ធ្ងរពីការធ្លាក់ចុះសេដ្ឋកិច្ចឡើយ ដោយសារថ្លៃអង្ករដែលពួកគាត់ផលិតនៅតែមានកម្រិតខ្ពស់។ ភូមិដែលធ្វើស្រែប្រាំងទំនងជារងផលប៉ះពាល់ពីការធ្លាក់ចុះ សេដ្ឋកិច្ចតិចជាងភូមិធ្វើស្រែវស្សា ព្រោះថាកសិករធ្វើស្រែប្រាំងអាចបានទទួលប្រាក់ចំណេញពីផលិតកម្ម ស្រូវរបស់ខ្លួនខ្ពស់ជាងឆ្នាំ២០០៨ ខណៈដែលកសិករស្រូវវស្សារកប្រាក់ចំណូលបានតិចជាង។

ការចិញ្ចឹមជីវិតរបស់គ្រួសារនៅក្នុងភូមិនេសាទ ជួបការលំបាកកាន់តែខ្លាំងធៀបនឹងឆ្នាំ២០០៨ ដោយសារពួកគេគ្មានចំណូលពីប្រភពដទៃ។ ទោះជាយ៉ាងនេះក្ដី ការលំបាករបស់ពួកគេកាន់តែមានសភាពធ្ងន់ធ្ងរបន្ថែមទៀត ពីឥទ្ធិពលនៃការធ្លាក់ចុះសេដ្ឋកិច្ច។ ពួកគេពឹងផ្អែកជាខ្លាំងលើការនេសាទ ខណៈដែលផលនេសាទរបស់ពួកគេក្នុងមួយគ្រួសារបន្តធ្លាក់ចុះ ជារៀងរាល់ឆ្នាំ។ ហេតុនេះ សមាមាត្រខ្ពស់បំផុតរបស់គ្រួសារនៅក្នុងភូមិនេះគឺជំពាក់បំណុលគេ ហើយការខ្ចីបុលច្រើនបំផុត(៧៩%) ត្រូវបានគេយកទៅប្រើក្នុងអាជីវកម្មនេសាទ ក្រៅពីនេះ គ្រួសារអ្នកនេសាទបានឱ្យដឹងថា ការលួចឧបករណ៍នេសាទ គឺជាកង្វល់ចំបងមួយរបស់ពួកគេ។ ហេតុនេះ ប្រាក់កម្ចីប្រមាណជា ៨%នៅក្នុងភូមិនេះ គឺខ្ចីដើម្បីយកទៅសងបំណុល ចំណែកឯគ្រួសារ ១៩% បានរាយការណ៍ថាពួកគេគ្មានប្រាក់គ្រប់គ្រាន់ដើម្បីសងបំណុល ហើយនេះគឺជាការលំបាកចំបងរបស់ ពួកគាត់ក្នុងរយៈពេលប្រាំមួយ ខែមុន។ ក្រៅពីនេះ មូលហេតុចំបងទីពីរចំពោះការខ្ចីបុល គឺខ្ចីដើម្បីទិញស្បៀងអាហារ។ ប្រាក់កម្ចីជាងពាក់កណ្ដាលនៅក្នុងភូមិនេះ ត្រូវបានចំណាយលើស្បៀងអាហារ ដែលប្រការនេះបញ្ជាក់ច្បាស់អំពីការលំបាករបស់ពួកគេ។

ក្រោយពីមានផលប៉ះពាល់ពីការធ្លាក់ចុះសេដ្ឋកិច្ច គ្រួសារនានារកប្រាក់ចំណូលបានតិចជាងមុនតាមវិធីផ្សេងៗ។ ដើម្បីសម្របជាមួយការលំបាករបស់ខ្លួន គ្រួសារទាំងនោះបានចាប់ផ្ដើមកម្រិតការចំណាយលើការថែទាំសុខភាព និងលើមុខចំណាយមិនមែនស្បៀង ហើយកាត់បន្ថយរបបអាហារ (តាមរយៈការបរិភោគអាហារតិចជាងមុន ឬទិញម្ហូបដែលពួកគេ មិនសូវនិយមចូលចិត្ត ឬម្ហូបអាហារថោក) ដែលជាការគម្រាមកំហែងបន្ថែមទៀតចំពោះស្ថានភាពអាហារូបត្ថម្ភ។ ស្ត្រីបរិភោគអាហារតិចជាងបុរស ព្រោះពួកគេចង់ឱ្យប្ដី និងកូនៗរបស់ខ្លួនបានទទួលទានអាហារគ្រប់គ្រាន់។ ក្រៅពីនេះ បន្ថែមលើការស្វែងរកការងារបន្ថែម ឬការងារផ្សេង និងបញ្ជូនសមាជិកគ្រួសារកាន់តែច្រើនធ្វើចំណាកស្រុក ដើម្បីរកការងារធ្វើ គ្រួសារទាំងនេះ ដោះស្រាយការលំបាកលំបិនរបស់ពួកគេតាមរយៈការលក់ទ្រព្យសម្បត្តិ ខ្ចីប្រាក់ដើម្បីសងបំណុល និងខ្ចីប្រាក់ដើម្បីទិញស្បៀងអាហារ។ ការខ្ចីប្រាក់ ដែលមិនសំដៅយកទៅធ្វើផលិតកម្មបែបនេះ ទំនងជាជម្រុញគ្រួសារ ទាំងនោះឱ្យជំពាក់បំណុលគេកាន់តែច្រើនថែមទៀត។

## អនុសាសន៍

ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការធ្លាក់ចុះសេដ្ឋកិច្ចមកលើសហគមន៍ ចាំបាច់ត្រូវមានគោលនយោបាយឆ្លើយតបឱ្យបានកាន់តែទូលាយ និងមានប្រសិទ្ធិភាពបន្ថែមទៀត។ កម្មវិធីសំណាញ់សុវត្ថិភាពសង្គមគឺជាការឆ្លើយតបភ្លាមៗ ដែលមានប្រសិទ្ធិភាពចំពោះផលប៉ះពាល់បច្ចុប្បន្ន។ វិធានការនយោបាយរយៈពេលវែងមិនត្រឹមតែអាចជួយសម្រាលផលប៉ះពាល់វិបត្តិមកលើក្រុមពលរដ្ឋក្រីក្រ និងក្រុមពលរដ្ឋងាយរងគ្រោះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយជម្រុញកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពងាយរងគ្រោះរបស់កម្ពុជាចំពោះឥទ្ធិពលវិបត្តិពីខាងក្រៅផងដែរ។

[៣] អនុសាសន៍ទាំងនេះ ត្រូវបានដកស្រង់ចេញពីឯកសារគោលជំហររបស់អង្គការមិនមែនរដ្ឋាភិបាលចំពោះការអភិវឌ្ឍន៍ប្រទេសកម្ពុជា ក្នុងឆ្នាំ២០០៩-២០១០ សម្រាប់វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ (ខែឧសភា ឆ្នាំ២០១០)។ រហូតមកដល់ពេលនេះ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តនូវគោល នយោបាយឆ្លើយតបរបស់ខ្លួនមួយចំនួន ចំពោះផលប៉ះពាល់នៃការធ្លាក់ចុះសេដ្ឋកិច្ចមកលើកម្ពុជា ពិសេសប្រជាជនក្រីក្រ និងក្រុមជនរងគ្រោះ។

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា និងសមាជិកបណ្តាញអភិវឌ្ឍន៍សេដ្ឋកិច្ច សូមផ្តល់ជាអនុសាសន៍[៣] ទៅកាន់រាជរដ្ឋាភិបាលកម្ពុជាដោយមានការគាំទ្រដោយដៃគូអភិវឌ្ឍន៍ដូចខាងក្រោម៖

**អនុសាសន៍ផ្នែកគោលនយោបាយរយៈពេលខ្លី៖**

១. សូមឱ្យរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ពិនិត្យមើលឱ្យបានម៉ត់ចត់បន្ថែមទៀតចំពោះវិធានការបន្ទាន់ក្នុងការពង្រីកកម្មវិធីសំណាញ់សុវត្ថិភាពសង្គមដែលមានស្រាប់ ដោយផ្តោតការយកចិត្តទុកដាក់លើវិស័យអប់រំ សុខាភិបាល និងជំនួយស្បៀងសង្គ្រោះបន្ទាន់ ជាពិសេសក្រុមដែលប៉ះពាល់ដូចបានបង្ហាញក្នុងការអង្កេត។

២. បង្កើនការវិនិយោគសាធារណៈលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដែលអាចជួយបង្កើតការងារឱ្យពលរដ្ឋដែលបានបាត់បង់ការងារដោយសារវិបត្តិ។

៣. ពង្រីកកម្មវិធីបណ្តុះបណ្តាលជំនាញ ដើម្បីផ្តល់ឱកាសការងារផ្សេងៗចំពោះកម្មកររោងចក្រកាត់ដេរសម្លៀកបំពាក់ដែលបានបាត់បង់ការងារក្នុងពេលមានវិបត្តិ ក៏ដូចជាជម្រុញឱ្យមានឱកាសការងារចំពោះអ្នកដែលបាត់បង់ការងារដោយសារវិបត្តិ។

៤. សូមស្នើឱ្យរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ពិចារណាចំពោះការគាំទ្រក្នុងការផ្តល់កត្តាផលិតកម្ម ដល់កសិករតូចតាច ដើម្បីធ្វើយ៉ាងណាឱ្យពួកគេអាចផលិតស្បៀង និងធានាសន្តិសុខស្បៀង។

**អនុសាសន៍ផ្នែកគោលនយោបាយសម្រាប់រយៈពេលមធ្យម និងរយៈពេលវែង៖**

១. ផ្សារភ្ជាប់ក្រុមដែលរងគ្រោះខ្លាំងបំផុតជាមួយវិស័យកសិកម្មនិរន្តរភាពតាមរយៈការអភិវឌ្ឍកសិកម្មខ្នាតតូច ដើម្បីកសាងលទ្ធភាពងើបឡើងវិញរបស់ពួកគេពីផលប៉ះពាល់នៃវិបត្តិ ដើម្បីលើកកំពស់លទ្ធភាពរកប្រាក់ចំណូលរបស់ពួកគេ និងដើម្បីលើកកំពស់សន្តិសុខស្បៀងក្នុងរយៈពេលវែង និងឈានទៅរកការកាត់បន្ថយភាពក្រីក្រ។

២. ទទួលស្គាល់ថាការវិនិយោគលើគម្រោងស្រោចស្រពខ្នាតតូច សេវាផ្សព្វផ្សាយ និងខ្សែសង្វាក់តម្លៃកសិកម្ម គឺជាការចាំបាច់ក្នុងការឆ្លើយតបចំពោះសេចក្តីត្រូវការរបស់កសិករ។

៣. ទទួលស្គាល់ផងដែរថាគេត្រូវការជាខ្លាំងនូវឥណទានបន្ថែមការប្រាក់ទាប ក៏ដូចជាការបង្កើនការវិនិយោគនានាដែលផ្តល់អត្ថប្រយោជន៍ចំពោះកសិករខ្នាតតូច។

៤. សូមស្នើឱ្យរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ធ្វើការជាមួយគ្នា ដើម្បីបង្កើនសមត្ថភាពស្តុក កែច្នៃ និងនាំចេញតាមរយៈការពង្រឹង និងការបង្កើតបរិយាកាសអំណោយផល និងការគាំទ្រចំពោះវិស័យឯកជន (ឧ. កំចីជាមួយនឹងអត្រាការប្រាក់ទាប) ក្នុងការវិនិយោគលើវិស័យកសិកម្ម។

៥. យល់ថាលទ្ធភាពមានដី និងទឹកជាប្រការសំខាន់ជាខ្លាំង ដើម្បីធានាដល់ការផលិតស្បៀង ហេតុនេះការធានាបាននូវសិទ្ធិស្តីពីកម្មសិទ្ធិលើដីធ្លីរបស់កសិករគប្បីជាស្នូលនៃការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល។

**ព័ត៌មានទំនាក់ទំនង**

**សម្រាប់ព័ត៌មានបន្ថែមអំពីបញ្ហានានាដែលបានលើកឡើងក្នុងអត្ថបទនេះ សូមទាក់ទង៖**


**កញ្ញា ចាន់ សុខយ៉េង មន្ត្រីគម្រោងគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច**

**គម្រោងគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច និងបណ្តាញអភិវឌ្ឍន៍សេដ្ឋកិច្ច (EDN)**

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**

អាសយដ្ឋាន៖ អគារលេខ ៩-១១, ផ្លូវ ៤៧៦, សង្កាត់ទួលទំពូង១ ខណ្ឌចំការមន ភ្នំពេញ

ប្រអប់សំបុត្រលេខ ២២៩៥

ទូរស័ព្ទលេខ៖ (៨៥៥) ២៣ ២១៤ ៤២៩

ទូរសារលេខ៖ (៨៥៥) ២៣ ៩៩៤ ០៦៣

អ៊ីម៉ែល៖ ngoforum@ngoforum.org.kh

គេហទំព័រ៖ www.ngoforum.org.kh

# អ្នកផ្ទុកមេរោគអេដស៍ដែលត្រូវបង្ខំឱ្យទៅនៅភូមិទួលសំបូរៈ ការអំពាវនាវសុំជំនួយដើម្បីបន្តរស់

ប្រជាពលរដ្ឋសែសិបប្រាំមួយគ្រួសារដែលមានផ្ទុកមេរោគអេដស៍ហើយត្រូវបានបណ្តេញចេញពីបុរីកីឡា នៅកណ្តាលទីក្រុងភ្នំពេញកាលពីថ្ងៃទី ១៨ ខែមិថុនា ឆ្នាំ ២០០៩ ឱ្យទៅតាំងទីលំនៅថ្មីនៅភូមិទួលសំបូរ កំពុងរស់នៅដោយគ្មានទឹកភ្លើងនិងសេវាសុខភាពអ្វីទាំងអស់។ គ្រួសារទាំងនោះដែលបានបង្ខំឱ្យចាកចេញទៅរស់នៅក្នុងភូមិទទួលសំបូរ ដែលមានចំងាយ ២៥ គីឡូម៉ែត្រពីទីក្រុងភ្នំពេញបានបាត់បង់មុខរបរដែលអាចរកចំណូលប្រចាំថ្ងៃរបស់ខ្លួន ហើយកំពុងតែប្រឈមនឹងការលំបាកក្នុងការទទួលបានសេវាថែទាំសុខភាពសមស្រប ។

លក្ខខ័ណ្ឌរស់នៅរបស់គេនៅក្នុងភូមិទួលសំបូរបាន និងកំពុងប្រឈមមុខយ៉ាងគ្រោះថ្នាក់បំផុតសំរាប់គ្រួសាររបស់គេ។ ជាងនេះទៀត ចំងាយផ្លូវពីទួល សំបូរមកទទួលថ្នាំពន្យាជីវិត ការព្យាបាល និងការទទួលបាន សេវាវេជ្ជសាស្ត្រ នៅឯទីក្រុង ភ្នំពេញបានធ្វើឱ្យគេជួបប្រទះនូវការលំបាកយ៉ាងខ្លាំង។ គួរឱ្យសង្វេគបំផុត ការរស់នៅរបស់ពួកគេបានចុះដុនដាបទៅៗយ៉ាងលឿនជារៀងរាល់ថ្ងៃ។ គ្រួសារដែលរស់ នៅជាមួយមេរោគ អេដស៍ទាំងនោះស្ទើរតែទាំងអស់ នៅក្នុងសហគមន៍ នោះពុំមានអ្វីបរិភោគទេ។ គ្រួសារខ្លះពុំមានអង្ករសំរាប់ដាំបាយហូបផង។ នៅពេលដែល ពួកគេជំន្លៀសទៅដល់ដំបូងមានម្ចាស់ជំនួយមួយចំនួនបានផ្តល់ជារបបហូបចុក។ ទោះជាយ៉ាងនេះក្តីជំនួយទាំងនោះពុំបានគ្រប់គ្រាន់ក្នុងការចិញ្ចឹមសមាជិកគ្រួសាររបស់គេទេ ខណៈដែលភពចំណូលផ្សេងៗបានបាត់បង់អស់ចាប់ពីពេលដែលពួកគេទៅរសនៅទីនោះមក។

## ឃ្លានទៅរកជីវភាពតោកយ៉ាក

ពីដំបូង គ្រួសារនីមួយៗទទួលបានរបបអង្ករចំនួន ១៤ គីឡូក្រាមជារៀងរាល់ខែ ។ បន្ថែមពីលើរបបនេះ កុមារត្រូវបានផ្តល់អង្ករចំនួន ១០គីឡូក្រាម ថែមទៀត ។ ទោះជាយ៉ាងនេះក្តី របបអង្ករទាំងនេះ ពុំអាចចិញ្ចឹមគ្រួសារ ដែលមានសមាជិកចំនួន ៨ នាក់ គ្រប់គ្រាន់ទេ ។ កាន់តែយ៉ាប់ជាងនេះទៀតនោះ ម្ចាស់ជំនួយពុំបានផ្តល់ឱ្យពួកគាត់ដែលរស់នៅជាមួយមេរោគអេដស៍ ទាំងនោះឱ្យបានទៀងទាត់ថែមទៀត ។



"យើងពុំមានបាយហូបគ្រប់គ្រាន់ទេរាល់ថ្ងៃនេះ" ។ចាន់ ធីតា អាយុ ៣៦ ឆ្នាំ ហើយរស់នៅជាមួយ មេរោគអេដស៍ តាំងពីគាត់អាយុ ២៨ ឆ្នាំម្លេះ និយាយ។ ប្តីរបស់គាត់ ដែលរស់នៅជាមួយមេរោគ អេដស៍ដែរនោះ ធ្លាប់ធ្វើការជាកម្មករសំណង់ ដែល អាចរកចំណូលបានចំនួនពី ១០០០០ ទៅ ១២០០០រៀលក្នុងមួយថ្ងៃពេលដែលពួកគាត់រស់នៅបុរីកីឡា ។ " ជាមួយនឹងប្រាក់ ចំណូលនេះ ពួក យើងស្ទើរតែពុំអាចចិញ្ចឹមគ្រួសាររស់ផង" គាត់បន្ថែម ។ "ឥឡូវនេះ ប្តីរបស់ខ្ញុំពុំមានការងារធ្វើទេ តាំងពីពេល ដែលគ្រួសារយើងត្រូវបង្ខំឱ្យមករស់នៅទីនេះ" គាត់និយាយដោយអស់សង្ឃឹម ។

គាត់និយាយថា ប្តីរបស់គាត់នៅតែផ្ទះដោយពុំមាន ប្រាក់ ចំណូលអ្វី សំរាប់ផ្គត់ផ្គង់គ្រួសារទេ។ គ្រួសារដែលមានសមាជិក ៨នាក់មួយនេះរស់នៅក្នុងបន្ទប់ ៣, ៨ គុណនឹង ៤ ម៉ែត្រ ប្រក់ និងបិទបាំងដោយ សង្កសីពណ៌ខៀវ និងបង្អួចមួយ ដោយពុំមានមូលដ្ឋានចំណូលអ្វីទាំងអស់។ ពួកគាត់ពឹងអាស្រ័យទាំងស្រុង ទៅលើជំនួយអង្គការសប្បុរសជនពីខាងក្រៅដើម្បីរស់។ ជាងនេះទៀតនោះ គ្រួសារខ្លះពុំមានជំរកសមរម្យដើម្បីស្នាក់ទេ។ ពួកគាត់រស់នៅក្រោមសំយ៉ាបផ្ទះរបស់គ្រួសារផ្សេងទៀត ជាមួយនឹងគ្រែឈើមួយគត់។ ពួកគេស្ទើរតែពុំមានអ្វីហូបទាល់តែសោះលើកលែងតែបបរបន្តិចបន្តួចគ្រាន់ជីវិតរស់ប៉ុណ្ណោះ ។

" ខ្ញុំឆ្ងល់ ពួកគេចង់ឱ្យយើងរស់នៅឯកោនៅទីនេះ បែបនេះ ធ្វើដូចនេះ ពួកយើងនឹងស្លាប់កាន់តែលឿនថែមទៀត។ ប្រសិនបើពួកយើងឈឺនៅពេលយប់ ពួកយើង ពុំមានមធ្យោបាយធ្វើដំណើរទេ " ឈាង តូមា អាយុ ៤០ ឆ្នាំ ដែលរស់នៅជាមួយមេរោគអេដស៍និយាយទាំងទឹកភ្នែករលីងរលោង ។ ពីមុន គាត់ជាជាងជួសជុលម៉ូតូនៅបុរីកីឡា ។ " ប្រសិនបើ ពួកយើងឈឺនៅពេលថ្ងៃពុំអាចមានលទ្ធភាពជួល ម៉ូតូឌុបទៅគ្លីនីកនៅក្នុងទីក្រុងបានទេ "គាត់តូញត្អែរ ។

នៅក្នុងគ្រួសារទាំង៤៦នេះយ៉ាងតិចមានសមាជិកពីរនាក់ បានរស់នៅជាមួយមេរោគអេដស៍ ដែលត្រូវការថ្នាំពន្យាជីវិតដែលត្រូវបានផ្តល់ឱ្យដោយរដ្ឋា ភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ។ ជាងនេះទៀត អ្នករស់នៅជាមួយមេរោគអេដស៍ជាច្រើនទៀតមានជំងឺឱកាសនិយម ។

ជំនួយសប្បុរសជំនួយឧបត្ថម្ភពុំបានផ្តល់ឱ្យបានទៀតទាត់ទៅដល់ អ្នកដែលកំពុងត្រូវការនោះទេ ។ ពីមុនមន្ទីរពេទ្យព្រះសីហនុមជ្ឈមណ្ឌលនៃក្តីសង្ឃឹម បានផ្តល់សេវា ថែទាំតាមផ្ទះសំរាប់អ្នកដែលរស់នៅជាមួយមេរោគអេដស៍ ។ ឥឡូវនេះ សេវាទាំងនេះបានផ្ទេរទៅឱ្យអង្គការស្ត្រីដើម្បីសេដ្ឋកិច្ចទំនើបនិងការថែទាំជាអ្នកចាត់ចែងវិញ ។ លោក អ៊ី ឆាវលីត មន្ត្រីសំរបសំរួលគម្រោងនិងជាប្រធានក្រុមថែទាំតាមផ្ទះបាននិយាយថា មន្ទីរពេទ្យព្រះសីហនុមជ្ឈមណ្ឌលនៃក្តីសង្ឃឹមនៅបន្តផ្តល់ការគាំទ្រសេវាថែទាំតាមផ្ទះសំរាប់អ្នករស់នៅជាមួយមេរោគអេដស៍ម្តងម្កាល ហើយក៏នៅតែធ្វើការសហការគ្នាជាមួយអង្គការស្ត្រីក្នុងការគាំទ្រផ្នែកគ្លីនិកដល់អ្នកផ្ទុកនៅឡើយ ។" អង្គការស្ត្រីធ្វើការលើប្រព័ន្ធបញ្ជូន" លោក អ៊ី ឆាវលីត បញ្ជាក់ ។

គួរបញ្ជាក់ថាមានតែអង្គការស្បៀងអាហារពិភពលោកមួយប៉ុណ្ណោះបានសន្យាផ្តល់ស្បៀងដល់អ្នកផ្ទុកទាំងនោះ និងគ្រួសាររបស់គេសំរាប់រយៈពេលបីខែ។ ទោះជាយ៉ាងណាក៏ដោយកិច្ចសន្យាជួយផ្តល់ស្បៀងនេះ បានបញ្ចប់នៅក្នុងខែធ្នូ ឆ្នាំ ២០០៩ ។ ក្រៅពីអង្គការមជ្ឈមណ្ឌលនៃក្តីសង្ឃឹម អង្គការស្ត្រី និងអង្គការស្បៀងអាហារពិភពលោក នៅមានអង្គការលីកាដូ បានជួយផ្តល់ម្ហូបអាហារយូរៗម្តងដែរ នៅពេលគេចុះមកតាមដានការរស់នៅរបស់បងប្អូនទាំងនោះ ។

## ការតាំងទីលំនៅថ្មី

ផ្ទះនៅភូមិទួលសំបូរ ក្នុងខណ្ឌដង្កោធ្វើពីដែកប្រក់ សង្កសីហើយមានភាពខុសប្លែកពីផ្ទះនៅតំបន់ពាក់កណ្តាលក្រុងនេះតែម្តង។ នៅពេលក្រុមម៉េឌីញូស៍ ចុះទៅពិនិត្យនៅតំបន់នេះកាលពីខែតុលាកន្លងទៅអ្នកភូមិដែលរស់នៅជិតនោះនាំគ្នាហៅភូមិនោះថា " ភូមិអ្នកកើតអេដស៍ "។ផ្ទះដែលសង់ថ្មីនេះមិនត្រូវតាមបែបបទនៃជំរកបណ្តោះអាសន្ន ដែលគោរពទៅតាមទំហំ សុវត្ថិភាពភ្លើងនិងអនាម័យទេ។ នេះបើយោងទៅតាមការធ្វើអង្កេតរបស់អង្គការគ្រូពេទ្យគ្មានព្រំ ដែននៅក្នុងឆ្នាំ ២០០៨ ខណៈដែលជំរំស្នាក់នៅនេះទើបនឹងចាប់ផ្តើមសាងសង់។ ចន្លោះពីអគារមួយទៅអគារមួយទៀតនៅជិតគ្នាបំផុតខណៈដែលដីនិងអគារទៀត សោតពុំមានសុវត្ថិភាពទេ។ កន្លែងរស់នៅមានសភាពតូចចង្អៀត សំរាប់គ្រួសារដែលមានសមាជិកមធ្យម ហើយវាពុំមានបន្ទប់អ្វីទាំងអស់ខណៈដែលជញ្ជាំងពុំមានលក្ខណៈគត់មត់ល្អដែលអាចធានាសុវត្ថិភាពនោះ ។

ទីតាំងភូមិទួលសំបូរនេះពុំមានទឹកស្អាតប្រើប្រាស់នៅឡើយទេប៉ុន្តែគ្រាន់តែមានប្រព័ន្ធអនាម័យបណ្តោះអាសន្នតែប៉ុណ្ណោះ។ ផ្ទះប្រក់ពីសង្ក័សី ធ្វើឱ្យផ្នែកខាងក្នុងហប់ និង ក្តៅយ៉ាងខ្លាំង ខណៈដែលនៅខាងក្រៅផ្ទះស្ទើរតែពុំមានទីធ្លាសំរាប់ដើរ។ ប្រជាពលរដ្ឋ ៤៦ គ្រួសារដែលមានសមាជិកចំនួន ២៣០ នាក់កំពុងរស់នៅក្នុងភាពក្រីក្រតោកយ៉ាក យ៉ាងខ្លាំង តាំងពីពួកគេត្រូវបានបង្ខំឱ្យមករស់ទួល សំបូរនេះ នៅក្នុងខែមិថុនា ឆ្នាំ ២០០៩ មក។

## ការឆ្លើយតបរបស់រដ្ឋាភិបាល

ឯកឧត្តម វេជ្ជបណ្ឌិត តែង គន្ធី អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បាននិយាយថារដ្ឋាភិបាល បាននឹងកំពុងធ្វើការយ៉ាងជិតស្និទជាមួយដៃគូអភិវឌ្ឍន៍ ដៃគូសុខាភិបាលនានា និងអាជ្ញាធរមូលដ្ឋានក្នុងការកៀងគរមូលនិធិ ដើម្បីកែលំអផ្ទះសំរាប់អ្នកផ្ទុកមេរោគអេដស៍នៅទួលសំបូរនេះឡើងវិញ។ " អង្គការការីតាស នឹងត្រូវឱ្យចុះកិច្ចសន្យាកែលំអអគារទាំងនេះ

ឡើងវិញ ដើម្បីឱ្យត្រូវតាមបទដ្ឋានអប្បរមានៃជំរកស្នាក់នៅបណ្តោះអាសន្ន " ឯកឧត្តមបានបន្ថែម ។ គាត់និយាយថា: " គណ:កម្មការសំរាប់កៀងគរមូលនិធិ ត្រូវបានបង្កើតឡើង សំរាប់ធ្វើការកែលំអលំនៅដ្ឋានទាំងនោះ " ដោយគាត់ បន្ថែមថា ទោះជាយ៉ាងណាក៏ដោយ ធនធាននៅពុំទាន់ប្រមូលបាននៅឡើយទេនៅពេលនេះ ។ ជាងនេះទៀត អាជ្ញាធរជាតិ ប្រយុទ្ធនឹងជំងឺអេដស៍នឹងធ្វើការយ៉ាងជិតស្និទជាមួយនឹងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ដើម្បីបង្កើតមណ្ឌលធ្វើតេសឈាមមួយនៅក្នុងមណ្ឌលសុខភាពទាំងបីដែលមានស្រាប់ សំរាប់អ្នកផ្ទុក និងប្រជាជន នៅក្នុងភូមិទួលសំបូរនេះទាំងមូល ។ " ទោះជាយ៉ាងណាក៏ដោយកិច្ចការនេះត្រូវការការសិក្សាស៊ីជំរៅបន្ថែមទៀត" ឯកឧត្តម វេជ្ជបណ្ឌិត បញ្ជាក់បន្ថែម ។

សំខាន់ជាងនេះទៀត ឯកឧត្តមបានបន្តថា: " អ្នកផ្ទុកមេរោគអេដស៍នៅទួលសំបូរមានសំណាងជាង អ្នកក្រីក្រ និងក្រុមងាយរងគ្រោះដទៃទៀតនៅក្នុងប្រទេស ពីព្រោះអាជ្ញាធរមូលដ្ឋាន ដៃគូអភិវឌ្ឍន៍នានា និងអង្គការមិនមែនរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះពួកគាត់ ។ ពួកគាត់ត្រូវបានផ្តល់ឱ្យ នូវផ្ទះសមរម្យហើយកូនៗរបស់ពួកគេអាចមានឱកាសចូលសាលាដូចកូនអ្នកដទៃទៀតដែរ "។ គាត់បញ្ជាក់ទៀតថាការផ្លាស់ប្តូរអ្នកផ្ទុកមេរោគអេដស៍ ពីបុរីកីឡាមក ភូមិទួលសំបូរនេះមិនមានន័យថា អាជ្ញាធរមាន ការរើសអើងពួកគាត់ទេ ។ "ប៉ុន្តែយើង ពុំមានជំរើស។ យើងមិនអាចទិញផ្ទះឱ្យគាត់ម្នាក់មួយៗ នៅកណ្តាលក្រុងបានទេ ខណ:ដែលតំលៃផ្ទះថ្លៃកប់ពពកនោះ "។ ទោះជាយ៉ាងណាក៏ដោយ អ្នកផ្ទុកមេរោគអេដស៍មានផ្ទះផ្ទាល់ខ្លួនសំរាប់នៅដែរ " គាត់និយាយដោយមោទនភាព ។

## ជីវិតមុនការផ្លាស់ប្តូរទីលំនៅ

ពីមុនពួកគាត់អ្នកផ្ទុកប្រកបរបរចិញ្ចឹមជីវិតដោយរើសសំរាម ឬធ្វើជាអ្នកលីសែងនៅតាមផ្សារនៅជិត បុរីកីឡា ឬ ធ្វើជាកម្មករសំណង់ ដោយរកកំរៃបានពី ៦០០០ ទៅ ១០០០០ រៀល ។ពីភូមិទួលសំបូរទៅ កន្លែងធ្វើការក្នុងមួយថ្ងៃ ត្រូវចំណាយ ១៥០០០ រៀល ។ ដូច្នេះការបង្ខំឱ្យចាកចេញបានធ្វើឱ្យពួកគាត់ បាត់បង់មធ្យោបាយរកចំណូលនៅក្នុងទីក្រុងដែរ ។

យោងតាមការអះអាងរបស់លោក សុខ សុវណ្ណារ៉េត មន្ត្រី នៃមជ្ឈមណ្ឌល ជាតិប្រយុទ្ធ នឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បង្ហាញថា អត្រាឆ្លងអេដស៍ មានការធ្លាក់ចុះគួរឱ្យកត់សំគាល់នៅកម្ពុជា ចាប់ពី ១,២ % នៅក្នុង ចំណោមមនុស្សចាស់ អាយុចាប់ពី ១៥ ទៅ ៤៩ ឆ្នាំ នៅក្នុងឆ្នាំ ២០០៣ មកនៅត្រឹម ០,៩ % នៅក្នុងខែ មិថុនា ឆ្នាំ ២០០៦ ។ នេះបើយោងតាម អង្គការយូអិនអេដស៍ ។ " ចំនួនអ្នកផ្ទុកមេរោគអេដស៍នៅកម្ពុជាត្រូវបានប៉ាន់ប្រមាណថាមានចំនួន ៦៧០០០ " ។

រាជរដ្ឋាភិបាលមានកាតព្វកិច្ចធានាការផ្តល់ការថែទាំសុខភាពពេញលេញជូនប្រជាពលរដ្ឋគ្រប់រូបទាំងអស់ រួមទាំងការទទួលបានការព្យាបាល សំរាប់អ្នក ផ្ទុកមេរោគអេដស៍ ។ សេចក្តីណែនាំអន្តរជាតិ ស្តីពី ជំងឺអេដស៍និង សិទ្ធិមនុស្ស ក៏បានជំរុញថារដ្ឋទាំងអស់ត្រូវធានាជាសកលនៃការទទួលបានសេវានិងព័ត៌មាន និងថាសេវាទាំងនោះមិនត្រឹមតែអាចទទួលយកបាន និងមានគុណភាពទេ ប៉ុន្តែត្រូវធ្វើឱ្យអ្នកជំងឺត្រូវតែអាចទទួលយកបានផងដែរ " ។

អាជ្ញាធរសុខាភិបាលកម្ពុជា ដែលទទួលបាននូវការសាទរជាអន្តរជាតិ សំរាប់សមិទ្ធផលរបស់ខ្លួនក្នុងការឆ្លើយតបចំពោះមេរោគអេដស៍ បានផ្សារភ្ជាប់អភិក្រមនៃការថែទាំបន្ត ដែលស្វែងរកការឆ្លើយតបមិនត្រឹមតែបញ្ហាវេជ្ជសាស្ត្រទេ ប៉ុន្តែជាផលវិបាកសេដ្ឋកិច្ចសង្គម ចិត្តសាស្ត្រ និងច្បាប់ សំរាប់អ្នករស់នៅជាមួយមេរោគអេដស៍ ។ មាត្រាទី ៣៨ នៃច្បាប់ស្តីពីការការពារ និងទប់ស្កាត់ជំងឺអេដស៍ចែងថាពុំមាននរណាមួយត្រូវបានដាក់នៅកន្លែងដាច់ដោយឡែក តែឯងមិនឱ្យមានទីលំនៅ ឬបំបបង់ ដោយសារតែមានការសង្ស័យថា មានឆ្លងអេដស៍នោះទេ ។

បច្ចុប្បន្ននេះអ្វីដែលយើងត្រូវធ្វើបន្ទាប់នោះ គឺការទាមទារឱ្យមានការប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រែក្លាយអំណាចនៃសំដីនៃមាត្រាច្បាប់នេះ ឱ្យមកជាការពិតជាក់ស្តែង ។ ម៉េឌីញូស៍ បានប្រមូលសំឡេងរបស់អ្នកដែលរស់នៅជាមួយមេរោគអេដស៍ទាំងនោះ ដើម្បីធ្វើការអំពាវនាវឱ្យមានការផ្តល់ជំនួយ និងដើម្បីឱ្យមានការគាំពីរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍នានាបន្ថែមទៀត ។

## ព័ត៌មានទំនាក់ទំនង

**សម្រាប់ព័ត៌មានបន្ថែមអំពីបញ្ហានានាដែលបានលើកឡើងក្នុងអត្ថបទនេះ សូមទាក់ទង៖**

**លោក ហម ហាក់ ប្រធានកម្មវិធីទំនាក់ទំនង និងបោះពុម្ព**

**អង្គការ មេឌីខាំ**

ទូរស័ព្ទ: (៨៥៥)-១២ ៨៥០ ៦៦៥ / (៨៥៥)-២៣ ៨៨០ ២៩១ ភ្ជាប់បន្ត ១១៩

ទូរសារ: (៨៥៥)-២៣ ៨៨០ ២៩២

អាសយដ្ឋាន: ផ្ទះលេខ ៤ ផ្លូវលេខ ៥២២ រាជធានីភ្នំពេញ ប្រទេសកម្ពុជា ប្រអប់សំបុត្រ: ១១៦៤

អ៊ីម៉ែល : PCM@medicam-cambodia.org

គេហទំព័រ: www.medicam-cambodia.org